ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

# ផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល

# ២០២៣ - ២០២៧

## Digital Technology Strategic Plan 2023-2027



# អារម្ភកថា

បដិវត្តន៍ឧស្សាហកម្ម៤.០ បាននឹងកំពុងធ្វើដំណើរបោះជំហានទៅមុខក្នុងល្បឿនយ៉ាងលឿនលើសពីការរំពឹងទុក មានឥទ្ធិពលគ្របដណ្តប់ស្ទើរគ្រប់វិស័យនៃចរន្តសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់មនុស្សជាតិក្នុងសង្គមទូទាំងពិភពលោក ជាពិសេស នៅក្នុងបរិការណ៍នៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩។ ស្ថិតក្នុងស្ថានភាពនៃការរីករាតត្បាតនេះ ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងព័ត៌មាន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាបាននូវនិរន្តរភាពការងារ សកម្មភាពរស់នៅប្រចាំថ្ងៃក្នុងសង្គម ប្រតិបត្តិការសេដ្ឋកិច្ច និងធុរកិច្ច ដែលបានបង្ហាញពីសក្តានុពល និងអត្ថប្រយោជន៍ដ៏ធំធេងនៃប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងព័ត៌មាន ។ ការពង្រឹងសមត្ថភាពផ្នែកបច្ចេកវិទ្យា គឺជាកត្តាគន្លឹះកំណត់សម្រេចបាននូវទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បាននឹងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការធ្វើកំណែទម្រង់រដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីពង្រឹងប្រសិទ្ធភាពកិច្ចការងារនានារួមទាំងវិស័យសាធារណៈ និងសន្តិសុខជាតិ ឱ្យទទួលបានប្រសិទ្ធផលខ្ពស់ ជាពិសេសការអភិវឌ្ឍធនធានមនុស្ស ដើម្បីចូលរួមចំណែកក្នុងការអនុវត្តក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ។ ដូចនេះដើម្បីអាចសម្រេចបានផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថលមួយ កិច្ចការងារបណ្តុះបណ្តាលពង្រឹងសមត្ថភាពធនធានមនុស្សផ្នែកបច្ចេកវិទ្យា ត្រូវទទួលរ៉ាប់រងនូវភារកិច្ចយ៉ាងសំខាន់ក្នុងការកសាងកម្លាំងធនធានមនុស្សឱ្យមានសមត្ថភាពគ្រប់គ្រាន់ ព្រមទាំងមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាកម្រិតខ្ពស់ ដែលនេះគឺជាភារកិច្ចដ៏ចម្បង និងមានសារៈសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការឈានទៅសម្រេចគោលដៅកំណើនសេដ្ឋកិច្ច និងស្ថិរភាពសង្គមប្រកបដោយចីរភាព ។ ការអប់រំបណ្តុះបណ្តាលពង្រឹងសមត្ថភាពយុវជនបន្តវេនក្នុងសម័យកាលបដិវត្តកម្មឌីជីថល ៤.០ គឺជាកត្តាមិនអាចខ្វះបាន ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រ និងជំរុញឱ្យទទួលបាននូវចំណេះដឹង ចំណេះធ្វើ និងជំនាញបច្ចេកទេសជាមួយសមត្ថភាពពិតប្រាកដ ដើម្បីក្លាយខ្លួនទៅជាកម្លាំងធនធានមនុស្សពិតប្រាកដលើជំនាញបច្ចេកវិទ្យាឌីជីថលមួយច្បាស់លាស់ ។ ជាមួយគ្នានេះ ក្រសួងមហាផ្ទៃ បានគិតគូរនិងយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញព័ត៌មានវិទ្យា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅចូលរួមចំណែកអភិវឌ្ឍការងារគ្រប់គ្រង និងការដាក់ឲ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ជំរុញដំណើរការធ្វើបរិវត្តកម្មឌីជីថល និងដើម្បីប្រែក្លាយទៅជាក្រសួងដែលប្រើប្រាស់កម្មវិធីឌីជីថលមួយពេញលេញនៅពេលខាងមុខនេះ ។

ជាទីបញ្ចប់ ក្នុងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការ និងជាប្រធានក្រុមការងាររដ្ឋាភិបាលឌីជីថលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងមហាផ្ទៃ** ដែលបានខិតខំប្រឹងប្រែងដឹកនាំតម្រង់ទិសក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានព័ត៌មានវិទ្យា និងអគ្គនាយកដ្ឋានពាក់ព័ន្ធ លើការងាររៀបចំកសាងផែនការយុទ្ធសាស្ត្របច្ចេកវិទ្យា

ឌីជីថល ក្រសួងមហាផ្ទៃ ២០២៣-២០២៧ រហូតសម្រេចទទួលបានផែនការយុទ្ធសាស្ត្រមួយគ្រប់ជ្រុងជ្រោយ ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា និងតាមបរិបទនៃការវិវឌ្ឍន៍បច្ចេកវិទ្យាឌីជីថលនៅលើពិភពលោក ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល ២០២៣-២០២៧ នឹងក្លាយជាផែនការមេមួយដ៏រស់រវើក ជាត្រីវិស័យ តម្រង់ទិសលើការងារបច្ចេកវិទ្យាឌីជីថលដល់អគ្គនាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ យកទៅអនុវត្តឈានទៅសម្រេចបាននូវលទ្ធផលការងារផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដោយអាចបង្ស៊ីគ្នាជាមួយបណ្ដាប្រព័ន្ធបច្ចេកវិទ្យាឌីជីថលរបស់ក្រសួង ស្ថាប័ន រាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងទំនុកចិត្តលើសេវាកម្ម និងសន្តិសុខ ។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


អារម្ភកថា ........................................................................................................I

បញ្ជីពាក្យកាត់..................................................................................................VI

បញ្ជីរូបភាព ....................................................................................................VIII

## ជំពូកទី១

## សេចក្តីផ្តើម

១.១. យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា....................................... ២

១.២. គោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥................................. ៣

១.៣. គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ...........................................៥

១.៤. គោលនយោបាយជាតិស្តីពី វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន) ២០២០-២០៣០.......៦

## ជំពូកទី២

## បច្ចុប្បន្នភាពនៃការបណ្តុះបណ្តាល និងប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ក្រសួងមហាផ្ទៃ

២.១. កិច្ចការងាររដ្ឋបាល និងហិរញ្ញវត្ថុ..................................................................................៨

២.២. ស្ថានភាពក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងការផ្សព្វផ្សាយអប់រំ............................. ១១

២.៣. កិច្ចការងារផ្តល់សេវាសាធារណៈ ...............................................................................២១

## ជំពូកទី៣

## យុទ្ធសាស្រ្តបច្ចេកវិទ្យាឌីជីថល ក្រសួងមហាផ្ទៃ

៣.១. យុទ្ធសាស្រ្តបណ្តុះបណ្តាលធនធានមនុស្ស និងបញ្ជ្រាបចំណេះដឹង .....................................២៥

៣.១.១. យន្តការពង្រឹងប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាល និងកសាងធនធានមនុស្ស......................២៦

៣.១.១.១. យន្តការពង្រឹង និងកសាងធនធានមនុស្សផ្នែកបច្ចេកវិទ្យា ..........................................២៦

៣.១.១.២. យន្តការផ្តល់លទ្ធភាពគាំទ្រសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍមន្ត្រីជំនាញ និងគ្រូបង្គោល.....២៩

៣.១.១.៣. យន្តការផ្តល់លទ្ធភាពសិក្សាពេញលេញដល់សិក្ខាកាមអំឡុងពេលបណ្តុះបណ្តាល............២៩
៣.១.១.៤. យន្តការរៀបចំផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយអប់រំសមស្របតាមតម្រូវការ ............៣០
៣.១.១.៥. យន្តការបង្កើនកិច្ចសហការជាមួយដៃគូ និងគ្រឹះស្ថានអប់រំក្នុងបេសកកម្មបណ្តុះបណ្តាល.....៣០
៣.១.២. យន្តការពង្រឹងកិច្ចសហការដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាល.........................៣១
៣.២. យុទ្ធសាស្ត្រកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ក្រសួងមហាផ្ទៃ....................................... ៣២
៣.២.១. យន្តការពង្រឹងបណ្តាញហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ..................................................៣៣
៣.២.២. យន្តការពង្រឹងប្រសិទ្ធភាព នៃការគាំទ្រសេវាកម្មឌីជីថល.............................................. ៣៨
៣.២.៣. យន្តការគ្រប់គ្រង និងការធ្វើទំនើបកម្មឧបករណ៍បច្ចេកវិទ្យា.......................................... ៤២
៣.២.៤. យន្តការពង្រឹង និងលើកកម្ពស់នវានុវត្តន៍ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ...............................៤៤
៣.៣. យុទ្ធសាស្ត្រពង្រឹងសន្តិសុខ និងទប់ស្កាត់បទល្មើសបច្ចេកវិទ្យា ( Cyber Security and Cybercrime )
...................................................................................................................៤៨
៣.៣.១. យន្តការទប់ស្កាត់បទល្មើសបច្ចេកវិទ្យា ...........................................................................៤៩
៣.៣.២. យន្តការគ្រប់គ្រងសន្តិសុខបច្ចេកវិទ្យា.............................................................................. ៥០
៣.៣.២.១. យន្តការគ្រប់គ្រងប្រព័ន្ធសន្តិសុខព័ត៌មាន ( Information Security Management System ) ៥១
៣.៣.២.២. យន្តការសហប្រតិបត្តិការផ្នែកសន្តិសុខបច្ចេកវិទ្យា ..................................................៥១
៣.៤. យុទ្ធសាស្ត្រស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យា .....................................................៥២
៣.៤.១. យន្តការការពង្រឹងគោលការណ៍ផ្សព្វផ្សាយ RDI........................................................................៥២
៣.៤.២. យន្តការកសាងប្រព័ន្ធគ្រប់គ្រង RDI និងយន្តការផ្តល់មូលនិធិ .......................................៥៣
៣.៤.៣. យន្តការការលើកកម្ពស់ប្រសិទ្ធភាពនៃមជ្ឈមណ្ឌល RDI ...............................................៥៣
៣.៥. យុទ្ធសាស្ត្រពង្រឹងគុណភាពការងារ និងការផ្តល់សេវាសាធារណៈ.........................................៥៤
៣.៥.១. យន្តការគ្រប់គ្រង និងអភិវឌ្ឍកម្មវិធីសូហ្វវែរ...........................................................................៥៥
៣.៥.២. យន្តការពង្រឹងសេវារដ្ឋបាលឌីជីថល ..............................................................................៥៦
៣.៥.៣. យន្តការធ្វើឱ្យប្រសើរឡើងនូវសេវាច្រកចេញ ចូលតែមួយសម្រាប់ប្រជាពលរដ្ឋ...................៥៧

៣.៦. យុទ្ធសាស្ត្រអភិបាលកិច្ចបច្ចេកវិទ្យា ....... ៥៧
៣.៦.១. យន្តការពង្រឹងក្របខ័ណ្ឌបទដ្ឋានគតិយុត្ត ....... ៥៨
៣.៦.២. យន្តការអភិបាលកិច្ចបច្ចេកវិទ្យា....... ៥៩
៣.៦.៣. យន្តការតម្លើងអភិបាលកិច្ចបច្ចេកវិទ្យា....... ៦០
៣.៦.៤. យន្តការត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន ....... ៦១
៣.៦.៤.១. ប្រភេទនៃការត្រួតពិនិត្យផ្ទៃក្នុង....... ៦២
៣.៦.៤.២. ការវាយតម្លៃគោលបំណងនៃការត្រួតពិនិត្យហានិភ័យគន្លឹះ....... ៦២

## ជំពូកទី៤

## យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

៤.១. បច្ចេកទេសវិភាគ SWOT....... ៦៣
៤.២. ការរៀបចំរបាយការណ៍ ....... ៦៤

## ជំពូកទី៥

## ផែនការសកម្មភាព

ឧបសម្ព័ន្ធទី១៖ បច្ចុប្បន្នភាពប្រព័ន្ធបច្ចេកវិទ្យារបស់អគ្គនាយកដ្ឋាន ចំណុះក្រសួងមហាផ្ទៃ ឆ្នាំ២០២២..៧១
ឧបសម្ព័ន្ធទី២៖ សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងមហាផ្ទៃ....... ៧៧
ឧបសម្ព័ន្ធទី៣៖ សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារនៃលេខាធិការដ្ឋាន ចំណុះក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ....... ៨១
ពន្យល់ពាក្យគន្លឹះ ....... ៨៤

# បញ្ជីពាក្យកាត់

| ល.រ | ពាក្យកាត់ | ពាក្យពេញ |
|---|---|---|
| ១ | អ.ល | អគ្គលេខាធិការដ្ឋាន |
| ២ | អ.ន.ប | អគ្គស្នងការដ្ឋាននគរបាលជាតិ |
| ៣ | ភ.ហ.វ | អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ |
| ៤ | អ.រ.ប | អគ្គនាយកដ្ឋានរដ្ឋបាល |
| ៥ | អ.អ | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ៦ | អ.អ.ស | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៧ | ប.ន.ក | បណ្ឌិត្យសភានគរបាលកម្ពុជា |
| ៨ | អ.ព.គ | អគ្គនាយកដ្ឋានពន្ធនាគារ |
| ៩ | ក្រ.ប្រ.ន | ក្រុមប្រឹក្សានីតិកម្ម |
| ១០ | ស.ផ.ក | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ១១ | អ.ធិ | អគ្គាធិការដ្ឋាន |
| ១២ | ស.ជ.រ.ម | សាលាជាតិរដ្ឋបាលមូលដ្ឋាន ( Local School of Local Administration ) |
| ១៣ | ក.រ.ប.គ.ព | ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន |
| ១៤ | ប.គ.ព ( ICT ) | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន<br>( Information and Communication Technology ) |
| ១៥ | SIEM | ប្រព័ន្ធគ្រប់គ្រងសន្តិសុខ និងឧបទ្ទវហេតុ<br>( Security Incident and Event Management ) |
| ១៦ | IAM | ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណ ( Identity and Access Management ) |
| ១៧ | API | កម្មវិធីតភ្ជាប់ ( Application Programming Interface ) |
| ១៨ | SWOT | ចំណុចខ្លាំង ខ្សោយ ឱកាស និងការគំរាមកំហែង<br>( Strength, Weaknesses, Opportunities, and Threats ) |
| ១៩ | DB | ប្រព័ន្ធទិន្នន័យ ( Database ) |
| ២០ | SLA | កិច្ចសន្យាផ្តល់សេវា ( Service Level Agreement ) |
| ២១ | ISMS | ប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន<br>( Information Security Management System ) |
| ២២ | R&D | ស្រាវជ្រាវ និងអភិវឌ្ឍ ( Research and Development ) |

| | | |
|---|---|---|
| ២៣ | ITIL | បណ្ណាល័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន<br>( Information Technology Infrastructure Library ) |
| ២៤ | DMS | ប្រព័ន្ធគ្រប់គ្រងឯកសារ ( Document Management System ) |
| ២៥ | MIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ( Management Information System ) |
| ២៦ | OWSO | ការិយាល័យច្រកចេញចូលតែមួយ ( One Window Service Office ) |
| ២៧ | VTR | អត្រាមើលតាមរយៈ ( View-Through Rate ) |
| ២៨ | OWSM | យន្តការច្រកចេញចូលតែមួយ ( One Window Service Mechanism ) |
| ២៩ | PS | សេវាលិខិតឆ្លងដែន ( Passport Service ) |
| ៣០ | FMIS | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ<br>( Financial Management Information Systems ) |
| ៣១ | FPCS | ប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស<br>( Foreigners Present in Cambodia System ) |
| ៣២ | VPLS | សេវាបណ្តាញនិម្មិត ( Virtual Private LAN Service ) |
| ៣៣ | FTTx | វិធីសាស្រ្ត ( Fiber to the X ) |
| ៣៤ | MPLS | បណ្តាញតភ្ជាប់ ( Multiprotocol Label Switching ) |
| ៣៥ | VOIP | សេវាសម្លេងអ៊ិនធឺណិត ( Voice Over Internet ) |
| ៣៦ | COBIT | បទដ្ឋាន<br>( Control Objectives for Information and Related Technologies ) |
| ៣៧ | NIST | វិទ្យាស្ថានជាតិស្តង់ដារ និងបច្ចេកវិទ្យា<br>( National Institute of Standards and Technology ) |
| ៣៨ | CIS | មជ្ឈមណ្ឌលសន្តិសុខអ៊ិនធឺណិត ( Center for Internet Security ) |
| ៣៩ | VPN | បណ្តាញនិម្មិត ( Virtual Private Network ) |
| ៤០ | RFP | ការស្នើសុំសំណើ ( Request for proposal ) |
| ៤១ | APPs | បណ្តាកម្មវិធី ( Applications ) |
| ៤២ | CAPEX | ចំណាយដើមទុន ( Capital Expenditure ) |
| ៤៣ | OPEX | ចំណាយប្រតិបត្តិការ ( Operating Expense ) |
| ៤៤ | ERP | កម្មវិធីផែនការធនធានសហគ្រាស ( Enterprise Resource Planning ) |
| ៤៥ | GIS | ប្រព័ន្ធព័ត៌មានភូមិសាស្រ្ត ( Geographic Information System ) |
| ៤៦ | INTERPOL | នគរបាលអន្តរជាតិ ( International Criminal Police Organization ) |

# បញ្ជីរូបភាព


**រូបភាពទី១៖** ការធ្វើបរិវត្តកម្មបច្ចេកវិទ្យាឌីជីថលលើគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច និងសង្គម

**រូបភាពទី២៖** កម្រិតនៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល

**រូបភាពទី៣៖** យន្តការបណ្តុះបណ្តាលពង្រឹងប្រសិទ្ធភាពក្នុងការកសាងធនធានមនុស្សផ្នែកបច្ចេកវិទ្យា

**រូបភាពទី៤៖** យន្តការសហការលើកិច្ចការងារបណ្តុះបណ្តាលធនធានមនុស្សផ្នែកបច្ចេកវិទ្យា

**រូបភាពទី៥៖** លំហូរការងារគ្រប់គ្រង និងការតភ្ជាប់ប្រព័ន្ធបច្ចេកវិទ្យាក្របខណ្ឌក្រសួងមហាផ្ទៃ

**រូបភាពទី៦៖** មជ្ឈមណ្ឌលទិន្នន័យក្រសួងមហាផ្ទៃ និងការតភ្ជាប់បម្រើដល់ប្រព័ន្ធអេកូឡូហ្ស៊ីឌីជីថលថ្នាក់ជាតិ

**រូបភាពទី៧៖** លំហូរសេវាកម្មនៃបទដ្ឋាន ITIL និងអភិបាលកិច្ច COBIT

**រូបភាពទី៨៖** យន្តការពង្រឹងសន្តិសុខ និងទប់ស្កាត់បទល្មើសបច្ចេកវិទ្យា

**រូបភាពទី៩៖** មូលដ្ឋានសន្តិសុខបច្ចេកវិទ្យាព័ត៌មាន

**រូបភាពទី១០៖** ការគ្រប់គ្រងប្រព័ន្ធសន្តិសុខព័ត៌មាន ( Information Security Management System )

**រូបភាពទី១១៖** យន្តការសហប្រតិបត្តិការ និងភាពប្រទាក់ក្រឡានៃសន្តិសុខបច្ចេកវិទ្យា

**រូបភាពទី១២៖** យន្តការនៃការអភិវឌ្ឍកម្មវិធីសូហ្វវែរ

**រូបភាពទី១៣៖** លំហូរប្រព័ន្ធទិន្នន័យ API Gateway

**រូបភាពទី១៤៖** វត្ថុបំណងនៃអភិបាលកិច្ចបច្ចេកវិទ្យា

**រូបភាពទី១៥៖** យន្តការនៃការកសាងអភិបាលកិច្ចបច្ចេកវិទ្យាក្របខណ្ឌក្រសួងមហាផ្ទៃ

**រូបភាពទី១៦៖** យន្តការនៃការកសាងអភិបាលកិច្ចបច្ចេកវិទ្យាក្របខណ្ឌក្រសួងមហាផ្ទៃ

**រូបភាពទី១៧៖** យន្តការតាមដាន និងវាយតម្លៃ SWOT Analysis

**រូបភាពទី១៨៖** យន្តការគ្រប់គ្រងគម្រោងបច្ចេកវិទ្យាឌីជីថល

# ជំពូកទី១

## សេចក្តីផ្តើម

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ឱ្យក្លាយទៅជាប្រទេសមានចំណូលកម្រិតខ្ពស់ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការកែទម្រង់ប្រព័ន្ធគ្រប់គ្រងកិច្ចការងាររដ្ឋបាលតាមបែបប្រពៃណី ទៅជាប្រព័ន្ធគ្រប់គ្រងតាមបែបបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល ដើម្បីជំរុញប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពកិច្ចការងារទាំងឡាយក្នុងវិស័យសាធារណៈ និងសន្តិសុខជាតិឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ជាពិសេសការអភិវឌ្ឍធនធានមនុស្សដើម្បីចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលដោយរលូន។ ស្របពេលទន្ទឹមគ្នានេះបច្ចេកវិទ្យាភាវូបនីយ៍កម្ម ក៏ជាកត្តាមួយយ៉ាងសំខាន់សម្រាប់ព្រះរាជាណាចក្រកម្ពុជាក្នុងការទាញយកផលប្រយោជន៍ពីប្រព័ន្ធបច្ចេកវិទ្យាឌីជីថលដើម្បីធ្វើការអភិវឌ្ឍប្រទេសជាតិ និងតភ្ជាប់ប្រព័ន្ធជាលក្ខណៈសកល។

កត្តាជំរុញទាំងនេះបានធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវត្រៀមខ្លួនឱ្យបានរួចរាល់ជាមុន និងទាន់សភាពការណ៍វិវត្តន៍នៃបច្ចេកវិទ្យាឌីជីថលនៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មទី៤ ដោយបានរៀបចំបង្កើតនូវគោលនយោបាយពាក់ព័ន្ធបច្ចេកវិទ្យាឌីជីថលជាបន្តបន្ទាប់ ក្នុងនោះមានគោលនយោបាយធំៗចំនួន ៣ ដូចខាងក្រោម៖

- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥
- គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥
- គោលនយោបាយជាតិស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០២០-២០៣០

ផ្អែកលើយុទ្ធសាស្ត្រ និងគោលនយោបាយដ៏មុឺងម៉ាត់ប្រកបដោយចក្ខុវិស័យដ៏វែងឆ្ងាយខាងលើនេះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានជំរុញលើកទឹកចិត្តឱ្យអង្គភាពជំនាញធ្វើការរៀបចំពង្រឹងជំនាញបច្ចេកទេសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីជួយសម្រួលដល់ការបំពេញកិច្ចការងារផ្ទៃក្នុងរបស់អង្គភាព ក៏ដូចជាកិច្ចការងារជំនាញផ្សេងៗដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ ជាពិសេសការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយគុណភាព និងតម្លាភាព។ បន្ថែមពីលើកិច្ចការងារដែលបានណែនាំខាងលើ **សម្តេចក្រឡាហោម** ក៏បានដាក់ចេញនូវអនុសាសន៍ និងគាំទ្រលើការរៀបចំកសាងផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថលមួយ ដែលមានទស្សនវិស័យវែងឆ្ងាយគាំទ្រគោលនយោបាយជាតិនានាពាក់ព័ន្ធបច្ចេកវិទ្យា និងស្របតាមការរីកចម្រើនឥតឈប់ឈរនៃប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងតំបន់ និងសកលលោក ដើម្បីជំរុញប្រសិទ្ធភាពកិច្ចការងាររដ្ឋបាល កិច្ចការងារជំនាញនានា និងការផ្តល់សេវាសាធារណៈដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ ដោយផ្តោតលើយុទ្ធសាស្ត្រសំខាន់ៗចំនួន ០៦ ដូចខាងក្រោម៖

- យុទ្ធសាស្ត្របណ្តុះបណ្តាលធនធានមនុស្ស និងបញ្ញាបចំណេះដឹង
- យុទ្ធសាស្ត្រកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ក្រសួងមហាផ្ទៃ
- យុទ្ធសាស្ត្រពង្រឹងសន្តិសុខ និងទប់ស្កាត់បទល្មើសបច្ចេកវិទ្យា (Cyber Security and Cybercrime)
- យុទ្ធសាស្ត្រស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យា
- យុទ្ធសាស្ត្រពង្រឹងគុណភាពការងារ និងការផ្តល់សេវាសាធារណៈ
- យុទ្ធសាស្ត្រអភិបាលកិច្ចបច្ចេកវិទ្យា

## ១.១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញអំពីនិន្នាការធំៗ និងកាលានុវត្តន៍ភាពរបស់ប្រទេសកម្ពុជាលើផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឌីជីថល សម្រាប់ជាចលករប្រែក្លាយប្រទេសឱ្យឈានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដោយផ្តោតយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការធ្វើកំណែទម្រង់ការងារគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីពង្រឹងកិច្ចការងារនៅក្នុងវិស័យសាធារណៈរបស់រដ្ឋ និងសន្តិសុខជាតិប្រកបដោយគុណភាព តម្លាភាព និងទាន់សភាពការណ៍រីកចម្រើនយ៉ាងខ្លាំងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឌីជីថល។ ចរន្តនៃការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឌីជីថលដែលត្រូវបានគេហៅថា "បដិវត្តន៍ឧស្សាហកម្មទី៤ ឬ បដិវត្តន៍ឧស្សាហកម្ម៤.0" បានក្លាយទៅជាកត្តាគន្លឹះចម្បងមួយសម្រាប់កំណត់និន្នាការវិវត្តន៍នៃសង្គមជាតិ និងសេដ្ឋកិច្ចនៅគ្រប់ទិដ្ឋភាពដែលត្រូវបានបង្កើតឡើងទាំងកាលានុវត្តន៍ភាព និងបញ្ហាប្រឈមសម្រាប់សកលលោកទាំងមូល។ ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឌីជីថលនេះបាននឹងកំពុងធ្វើការជំរុញល្បឿន និងជម្រៅនៃស្វ័យប្រវត្តិកម្មដែលអាចជំនួសកម្លាំង និងបញ្ញារបស់មនុស្សជាតិនាពេលអនាគត។ ចរន្តនេះមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការកំណត់ឡើងវិញនូវកត្តាផលិតកម្ម ទំនាក់ទំនងនៃផលិតកម្ម ឥរិយាបថ ការប្រើប្រាស់ និងរចនាសម្ព័ន្ធសេដ្ឋកិច្ច។

ការអភិវឌ្ឍធនធានមនុស្ស ក៏ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាវិស័យអាទិភាពមួយនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយបានរំលេចនៅក្នុងមុំចំនួន០៤ ដូចខាងក្រោម៖

❖ **មុំទី១. ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**

➢ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺអភិវឌ្ឍ "ប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន" ដោយផ្តោតសំខាន់លើវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការតម្រង់ទិសសម្រាប់ទីផ្សារការងារនិងការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចជាតិ។

❖ **មុំទី២. ការបណ្តុះបណ្តាលជំនាញបច្ចេកទេស**

➢ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺសំដៅធានាថា "យុវជនម្នាក់ៗមានជំនាញច្បាស់លាស់មួយយ៉ាងតិចប្រចាំជីវិត" ពិសេសដើម្បីជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចឱ្យ

ឈានឡើងមួយកម្រិតទៀត។ ការបណ្តុះបណ្តាលជំនាញបច្ចេកទេសធ្វើឡើងក្នុងរូបភាពពីរ គឺធនធានមនុស្សនៅក្នុងប្រព័ន្ធអប់រំ និងធនធានមនុស្សនៅក្រៅប្រព័ន្ធអប់រំ ឬក្នុងទីផ្សារការងារដែលមានការផ្សារភ្ជាប់គ្នា។

- មុំទី៣. ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ
  - គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺសំដៅ "លើកកម្ពស់សុខភាពប្រជាជន និងអាហារូបត្ថម្ភ" ដើម្បីគាំទ្រការអភិវឌ្ឍធនធានមនុស្ស កំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គមប្រកបដោយវិរភាព។
- មុំទី៤. ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម
  - គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺការ "ពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម" ដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។

## ១.២. គោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

ការចង្អុលបង្ហាញនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក៏ដូចជាការត្រៀមខ្លួនឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ ព្រមជាមួយនឹងកត្តាទាំងឡាយដែលអាចឱ្យប្រទេសកម្ពុជាទាញយកសក្តានុពលពីដំណើរនៃការធ្វើបរិវត្តកម្មឌីជីថលផង "ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥" ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ជាអាទិភាពបំផុត និងត្រូវបានរៀបចំឡើងដោយផ្អែកលើតម្រូវការជាក់ស្តែង សក្តានុពល ធនធាន និងសមត្ថភាព ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន សម្រាប់តម្រង់ទិសការអភិវឌ្ឍ និងដំណើរការធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា។ បរិវត្តកម្មឌីជីថលនឹងនាំមកនូវបច្ច័យវិជ្ជមានសម្រាប់សេដ្ឋកិច្ចកម្ពុជា ពោលគឺជាជន្ទល់កំណើនថ្មីដែលមានភាពធន់ទៅនឹងការផ្លាស់ប្តូរជារចនាសម្ព័ន្ធនាពេលអនាគត ហើយក៏ជាចលករមួយក្នុងការជំរុញក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចដែលមានស្រាប់ផងដែរ ខណៈពេលបច្ចុប្បន្នក្បាលម៉ាស៊ីននៃកំណើននោះបានចាប់ផ្តើមមានសន្ទុះថមថយ និងរងផលប៉ះពាល់យ៉ាងខ្លាំងបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩។ ក្នុងន័យនេះ វិស័យបច្ចេកវិទ្យាឌីជីថលនឹងនាំមកនូវកាលានុវត្តន៍ភាពនៃប្រភពកំណើនថ្មី ព្រមទាំងការបង្កើននូវផលិតភាពសេដ្ឋកិច្ច ការជំរុញលើវិស័យសេដ្ឋកិច្ច និងការបង្កើតការងារសំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនៅក្នុងប្រទេសកម្ពុជាយើងមានការរីកចម្រើនយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់យ៉ាងខ្លាំង។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការចាប់យកវិស័យបច្ចេកវិទ្យាឌីជីថលនៅមានជួបប្រទះបញ្ហាប្រឈមជាច្រើនដូចជា ភាពនៅមានកម្រិត

នៃហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានគាំទ្រដល់វិស័យឌីជីថល ភាពជឿទុកចិត្ត ចំណេះដឹង ជំនាញ និងភាពជាអ្នកដឹកនាំឌីជីថល។ល។ មួយវិញទៀតប្រព័ន្ធអេកូឡូស៊ីធុរកិច្ចឌីជីថលនៅកម្ពុជា កំពុងស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើម និងមានការចូលរួមតិចតួចនៅក្នុងខ្សែសង្វាក់ផលិតកម្មក្នុងតំបន់ និងសកលលោកនៅឡើយ។ ទន្ទឹមនេះ គម្រោងផែនការអនុវត្តរដ្ឋាភិបាលឌីជីថលកម្ពុជាដែលមានតួនាទីស្នូលដឹកនាំនៅក្នុងដំណើការធ្វើបរិវត្តកម្មឌីជីថល ហាក់បីដូចជាមិនទាន់បានរៀបចំខ្លួនពេញលេញរួចរាល់ និងស៊ីជម្រៅនៅឡើយ។

ក្នុងស្មារតីនេះ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល បានដាក់ចេញនូវចក្ខុវិស័យច្បាស់លាស់មួយគឺ "ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបរិវត្តកម្មឌីជីថលគ្រប់តួអង្គសង្គម ទាំងរដ្ឋ ពលរដ្ឋ និងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ច និងលើកកម្ពស់សុខុមាលភាពសង្គមតាមគន្លងប្រក្រតីភាពថ្មី"។

- ❖ **វិធានការគោលនយោបាយជាក់លាក់ចំនួន៤៤ ត្រូវបានដាក់ចេញ ដើម្បីកសាងគ្រឹះចំនួន០២ គឺ៖**
  - ➢ **គ្រឹះទី១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល** ផ្តោតលើការតភ្ជាប់ឌីជីថល ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ការងារគ្រប់គ្រងភស្តុភារ (Logistics) និងការដឹកជញ្ជូនគោលដៅចុងក្រោយ។
  - ➢ **គ្រឹះទី២. ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល** ផ្តោតលើក្របខណ្ឌច្បាប់ ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងពង្រឹងការគ្រប់គ្រងសន្តិសុខឌីជីថល។
- ❖ **វិធានការគោលនយោបាយជាក់លាក់ចំនួន៨២ ត្រូវបានដាក់ចេញដើម្បីពង្រឹងសសរស្តម្ភទាំង ៣ គឺ៖**
  - ➢ **សសរស្តម្ភទី១. ការកសាងពលរដ្ឋឌីជីថល** ផ្តោតលើភាពជាអ្នកដឹកនាំឌីជីថល បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល និងពលរដ្ឋឌីជីថល។
  - ➢ **សសរស្តម្ភទី២. ការកសាងរដ្ឋាភិបាលឌីជីថល** ផ្តោតលើរដ្ឋាភិបាល និងសេវាសាធារណៈឌីជីថល គន្លឹះជំរុញការអនុវត្តឌីជីថល និងអភិបាលកិច្ចផ្អែកលើទិន្នន័យក្នុងវិស័យសាធារណៈ។
  - ➢ **សសរស្តម្ភទី៣. ការជំរុញធុរកិច្ចឌីជីថល** ផ្តោតលើបរិវត្តកម្មសហគ្រាស ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនិងធុរកិច្ចថ្មី និងខ្សែប្រវាក់តម្លៃឌីជីថល។

ក្របខណ្ឌគោលនយោបាយនេះក៏បានគិតគូរអំពីវិធានការចាំបាច់ចំនួន ១៣ ដើម្បីធានាបាននូវការចូលរួមនៅក្នុងវិស័យឌីជីថលប្រកបដោយបរិយាបន្នកម្ម ព្រមទាំងស្រូបយក កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់នានាដោយរបត់ថ្មីនៃបច្ចេកវិទ្យាឌីជីថលទៅលើសេដ្ឋកិច្ច និងសង្គម ដែលរួមមានការផ្លាស់ប្តូររចនាសម្ព័ន្ធ កម្លាំងពលកម្ម និងការងារ ការប្រែប្រួលរបត់ចំណូលពន្ធ កំណើនបន្ទុកចំណាយរដ្ឋ ផលប៉ះពាល់មកលើវប្បធម៌ប្រពៃណី និងការប្រាស្រ័យទាក់ទង ការបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន និងឧក្រិដ្ឋកម្មសាយប័រ (Cyber Crime)។




រូបភាពទី១៖ ការធ្វើបរិវត្តកម្មបច្ចេកវិទ្យាឌីជីថលលើគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច និងសង្គម

## ១.៣. គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥

ការចង្អុលបង្ហាញក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២២-២០៣៥ បានផ្តោតលើចក្ខុវិស័យកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលដ៏រស់រវើក ហើយដំណើរនៃការធ្វើបរិវត្តកម្មឌីជីថល ត្រូវបាននាំមុខដោយការកសាងរដ្ឋាភិបាលឌីជីថល ដែលជាសសរស្តម្ភសម្រាប់ជំរុញធុរជន និងប្រជាពលរដ្ឋ ឱ្យចាប់យកបច្ចេកវិទ្យាឌីជីថលប្រកបដោយភាពជឿទុកចិត្ត។ វឌ្ឍនភាពនៃការកសាងរដ្ឋាភិបាលឌីជីថលកម្ពុជា កំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ ដោយហេតុថា **ការធ្វើឌីជីថលនីយកម្មតាមក្រសួងស្ថាប័ន នៅពុំទាន់ធ្វើសមាហរណកម្មពេញលេញជាមួយគ្នានៅឡើយ**។ ប្រព័ន្ធភាគច្រើនផ្តោតសំខាន់លើការអភិវឌ្ឍកម្មវិធីសម្រាប់សម្រួលដល់ការបំពេញការងារជាក់ស្តែងប៉ុណ្ណោះ ពុំមានយុទ្ធសាស្ត្រសម្រាប់ការធ្វើបរិវត្តកម្មឌីជីថលរយៈពេលវែង ដែលគិតទៅដល់ប្រសិទ្ធភាព និងប្រសិទ្ធផលដែលអាចកើតចេញពីទិន្នន័យប្រមូលផ្តុំ។

នៅក្នុងអំឡុងពេលមាននិន្នាការធ្វើបរិវត្តកម្មឌីជីថល និងនវានុវត្តន៍នៃបច្ចេកវិទ្យាឌីជីថល ស្របពេលដែលពិភពលោកកំពុងបង្កើនល្បឿនទៅមុខយ៉ាងឆាប់រហ័ស ព្រះរាជាណាចក្រកម្ពុជាចាំបាច់ត្រូវរៀបចំខ្លួនឱ្យបានរួចជាស្រេចសម្រាប់ធ្វើការឆ្លើយតបទៅនឹងសន្ទុះនៃការវិវត្តន៍ឱ្យបានទាន់ពេលវេលា ក៏ដូចជាទាញយកនូវអត្ថប្រយោជន៍ឱ្យបានច្រើនបំផុត និងអស់ពីលទ្ធភាព ពីការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក៏ដូចជាបដិវត្តន៍ឧស្សាហកម្មទី៤។ ផ្អែកតាមការវិភាគអំពីភាពខ្លាំង ភាពខ្សោយ កាលានុវត្តន៍ភាព និងការគំរាមកំហែង (SWOT) នៃស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា ភាពខ្លាំងគឺជាឆន្ទៈនយោបាយដ៏មោះមុតរបស់ប្រមុខរាជរដ្ឋាភិបាល ដែលនឹងធ្វើឱ្យមានការសម្របសម្រួលជាធ្លុងមួយរវាងក្រសួងស្ថាប័នទាំងអស់នៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិនានា។

ចក្ខុវិស័យនៃគោលនយោបាយរដ្ឋាភិបាលឌីជីថល គឺការកសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់គុណភាពជីវិត និងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ឯកសារគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ១០ រួមមាន៖

- យុទ្ធសាស្ត្រ រៀបចំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល
- យុទ្ធសាស្ត្រ រៀបចំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ
- យុទ្ធសាស្ត្រ រៀបចំ និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល
- យុទ្ធសាស្ត្រ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេវាប្រៃសណីយ៍
- យុទ្ធសាស្ត្រ រៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល
- យុទ្ធសាស្ត្រ ធ្វើបរិវត្តន៍កម្មរដ្ឋាភិបាលឌីជីថល និងសេវាសាធារណៈ
- យុទ្ធសាស្ត្រ កសាងមូលធនមនុស្សឌីជីថល
- យុទ្ធសាស្ត្រ លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល
- យុទ្ធសាស្ត្រ រៀបចំសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល
- យុទ្ធសាស្ត្រ លើកកម្ពស់ធុរកិច្ចឌីជីថល




រូបភាពទី២៖ កម្រិតនៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល

## ១.៤. គោលនយោបាយជាតិស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន) ២០២០-២០៣០

គោលនយោបាយជាតិស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាការកំណត់នូវយុទ្ធសាស្ត្រ និងយុទ្ធវិធីដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់ សមស្របតាមបរិការណ៍ជាក់ស្តែងនៃប្រទេសជាតិសំដៅជំរុញ និងលើកកម្ពស់ចំណេះដឹងដែលទទួលបានពីការអប់រំឱ្យឈានដល់កម្រិតសេដ្ឋកិច្ចពុទ្ធិ ដើម្បីផ្តល់លទ្ធភាពដល់ការសម្រេចបាននូវរបៀបវារៈអភិវឌ្ឍជាតិ ស្របតាមចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ប្រកបដោយចីរភាព។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណង ដោយឈរលើក្របខណ្ឌទស្សនទានទទួលយកការសម្របសម្រួលបច្ចេកវិទ្យា និងនវានុវត្តន៍ ដោយការបន្ថែមនូវគោលដៅដែលត្រូវបានកំណត់ចំនួន ០៥ ដូចខាងក្រោម៖

- **គោលដៅទី១.** កសាង និងពង្រឹងធនធានមនុស្សឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ គុណភាព និងមានសីលធម៌វិជ្ជាជីវៈ ដោយពិនិត្យពិចារណាលើកត្តាសមភាពយេនឌ័រ។
- **គោលដៅទី២.** ផ្តល់លទ្ធភាពឱ្យធនធានមនុស្សផ្នែកផ្នែក វ.ប.ន បំពេញភារកិច្ចឈានមុខ ព្រមទាំងមានយន្តការសម្រាំង និងលើកទឹកចិត្តសមស្រប ដើម្បីទទួលបានធនធានមនុស្សផ្នែក វ.ប.ន ជាតិពោរពេញដោយសមត្ថភាព។
- **គោលដៅទី៣.** ផ្តល់លទ្ធភាពដល់សកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដោយផ្តោតលើការសម្របបច្ចេកវិទ្យាដែលទទួលបានទៅនឹងស្ថានភាពជាក់ស្តែងក្នុងស្រុក ជាមួយគ្នានោះត្រូវបង្កើនសមត្ថភាពស្រូបយកបច្ចេកវិទ្យាអន្តរជាតិ។
- **គោលដៅទី៤.** កសាង និងពង្រឹងប្រព័ន្ធអេកូនវានុវត្តន៍ឱ្យបានប្រកបដោយចីរភាព មានសមត្ថភាពសំយោគបច្ចេកវិទ្យា និងវិស្វកម្មធុរកិច្ចជាអាទិភាពជាតិ បម្រើឱ្យការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ ដើម្បីការអភិវឌ្ឍកាន់តែប្រសើរឡើង។
- **គោលដៅទី៥.** បណ្តុះឱ្យមានវប្បធម៌ វ.ប.ន នៅក្នុងសង្គមប្រកបដោយបរិយាបន្ន មានទំនុកចិត្ត និងជំនឿជាសាធារណលើផលិតផល និងសេវាបច្ចេកវិទ្យា ដោយទទួលបាននូវការពេញចិត្តនូវលទ្ធផលនៃការខិតខំ និងការវិនិយោគលើការអភិវឌ្ឍន៍ វ.ប.ន របស់ខ្លួនក៏ដូចជាការកែទម្រង់អភិបាលកិច្ចផ្នែក វ.ប.ន។

## ជំពូកទី២

## បច្ចុប្បន្នភាពនៃការបណ្តុះបណ្តាល និងប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ក្រសួងមហាផ្ទៃ

ដើម្បីមានមូលដ្ឋានសម្រាប់ធ្វើការកំណត់នូវយុទ្ធសាស្ត្រ និងយន្តការ ព្រមទាំងចង្អោមសកម្មភាព និង សកម្មភាពនៅក្នុងដំណើរការធ្វើបរិវត្តកម្មឌីជីថល ក្របខណ្ឌក្រសួងមហាផ្ទៃ ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន បានធ្វើបច្ចុប្បន្នភាពសម្រង់ស្ថិតិស្តីពីស្ថានភាពបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន តាមបណ្តាអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ ដោយបានធ្វើការបែងចែក និងផ្តោតលើកិច្ចការងារ សំខាន់ៗចំនួន ៣ ដូចខាងក្រោម៖

- កិច្ចការងាររដ្ឋបាល និងហិរញ្ញវត្ថុ
- ស្ថានភាពក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងផ្សព្វផ្សាយអប់រំ
- កិច្ចការងារផ្តល់សេវាសាធារណៈ

### ២.១. កិច្ចការងាររដ្ឋបាល និងហិរញ្ញវត្ថុ

ការធ្វើបច្ចុប្បន្នភាពសម្រង់ស្ថិតិស្តីពីស្ថានភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅតាមបណ្តា អគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ បានឆ្លុះបញ្ចាំងអំពីការគ្រប់គ្រងលំហូរការងាររដ្ឋបាល ការងារគ្រប់គ្រង បុគ្គលិក និងការងារគ្រប់គ្រងភស្តុភារ និងហិរញ្ញវត្ថុ ដែលភាគច្រើននៅបន្តអនុវត្តតាមបែបប្រពៃណីនៅឡើយ ទោះបីជាមានការប្រើប្រាស់កម្មវិធីកុំព្យូទ័រដូចជា Microsoft Office ( Word, Excel, Power Point... ) ជា ជំនួយក្តីក៏ដំណើរការនៃការគ្រប់គ្រងលំហូរការងាររដ្ឋបាល ការងារគ្រប់គ្រងបុគ្គលិក និងការងារគ្រប់គ្រងភស្តុភារ និងហិរញ្ញវត្ថុ នៅបន្តប្រើប្រាស់វិធីសាស្ត្របែបប្រពៃណី ដោយធ្វើឡើងតាមរយៈការបញ្ជូនឯកសារជាក្រដាសពី មួយដំណាក់កាលទៅមួយដំណាក់កាល និងធ្វើការរក្សាទុកនៅក្នុងក្រូណូ ដោយធ្វើការបែងចែកជាប្រភេទនៃ ឯកសារ និងតម្កល់រក្សាទុកនៅក្នុងរយៈពេលមួយដែលបានកំណត់ដោយអង្គភាពសាមីផ្ទាល់ ឬតាមទម្លាប់ដែល បានអនុវត្តបន្តពីរៀមច្បងមុនៗ មិនមានការកំណត់អំពីរយៈពេលដោយឯកសារគតិយុត្តដាក់លាក់សម្រាប់ជា ស្តង់ដាររួមដើម្បីធ្វើការរក្សាទុកនៅឡើយ។ ក្នុងពេលទន្ទឹមគ្នានេះ អង្គភាពមួយចំនួនបានខិតខំធ្វើទំនើបកម្មកិច្ច ការងារគ្រប់គ្រងលំហូរឯកសាររដ្ឋបាល ការងារគ្រប់គ្រងបុគ្គលិក និងការងារគ្រប់គ្រងភស្តុភារនិងហិរញ្ញវត្ថុទៅ ជាឌីជីថលផងដែរ ដោយបានធ្វើការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការងារគ្រប់គ្រងលំហូរឯកសាររដ្ឋបាល គ្រប់គ្រងបុគ្គលិក និងគ្រប់គ្រងភស្តុភារនិងហិរញ្ញវត្ថុ ទៅតាមលទ្ធភាពរៀងៗខ្លួនដោយប្រើប្រាស់ធនធានផ្ទៃក្នុង របស់អង្គភាពសាមីផ្ទាល់ ឬប្រើប្រាស់ក្រុមហ៊ុនឯកជនខាងក្រៅផ្សេងៗតាមរយៈកិច្ចសហប្រតិបត្តិការជាមួយ ដៃគូនានា ប៉ុន្តែការអភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យានៅតាមបណ្តាអង្គភាពទាំងនោះ គឺសម្រាប់ តែជួយសម្រួលដល់កិច្ចការងារផ្ទៃក្នុង ឬសម្រាប់បម្រើឱ្យកិច្ចការងារជំនាញរបស់អង្គភាពផ្ទាល់ខ្លួនតែប៉ុណ្ណោះ ទោះបីជាមានប្រព័ន្ធបច្ចេកវិទ្យាមួយចំនួន អាចធ្វើការចែករំលែកទៅឱ្យអង្គភាពដទៃផ្សេងទៀតប្រើប្រាស់បាន

ក៏ដោយ ក៏ការចែករំលែកឱ្យប្រើប្រាស់នៅមានកម្រិតទាប មិនបានទូលំទូលាយនៅឡើយ ដោយសារតែមានជួបប្រទះនូវឧបសគ្គមួយចំនួនដូចជា មិនមានកិច្ចសហការផ្ទៃក្នុងល្អប្រសើរ កង្វះខាតថវិកា និងបច្ចេកទេសក្នុងការពង្រីកវិសាលភាពប្រើប្រាស់ប្រព័ន្ធ និងការឯកភាពប្រើប្រាស់ជារួមនៅផ្ទៃក្នុងក្រសួងមហាផ្ទៃ។

អង្គភាពដែលបានអភិវឌ្ឍ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ជួយសម្រួលដល់កិច្ចការងារគ្រប់គ្រងលំហូរឯកសាររដ្ឋបាល គ្រប់គ្រងបុគ្គលិក គ្រប់គ្រងភស្តុភារនិងហិរញ្ញវត្ថុ មានដូចខាងក្រោម៖

**១.អគ្គលេខាធិការដ្ឋាន** (នាយកដ្ឋានព័ត៌មានវិទ្យា) កំពុងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងឯកសារ (Documents Management System - DMS) និងប្រព័ន្ធគ្រប់គ្រងបុគ្គលិក។ បច្ចុប្បន្នបានដាក់ឱ្យដំណើរការពេញលេញនៅផ្ទៃក្នុងនាយកដ្ឋានព័ត៌មានវិទ្យា និងត្រៀមដាក់ឱ្យដំណើរការនៅគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃទាំងមូលក្នុងពេលឆាប់ៗនេះ បន្ទាប់ពីក្រុមការងារបច្ចេកទេសបានធ្វើការកែសម្រួលរួចរាល់។

**២.អគ្គស្នងការដ្ឋាននគរបាលជាតិ** អង្គភាពចំណុះចំនួន០៣ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានជួយសម្រួលដល់ការងារគ្រប់គ្រងបុគ្គលិក និងលំហូរការងាររដ្ឋបាល ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាលទូទៅ នៃសេនាធិការដ្ឋាន បានធ្វើការអភិវឌ្ឍ និងប្រើប្រាស់កម្មវិធីគ្រប់គ្រងលំហូរការងាររដ្ឋបាល (លិខិតចេញ-ចូល-កំណត់បង្ហាញ និងតាមដានចំណារបស់ថ្នាក់ដឹកនាំ)
- នាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន ប្រើប្រាស់ប្រព័ន្ធ (Application) សម្រាប់គ្រប់គ្រងទិន្នន័យមន្ត្រីនគរបាលជាតិចំណុះអង្គភាព និងភ្នាក់ងារសន្តិសុខឯកជន
- នាយកដ្ឋានបុគ្គលិកកំពុងប្រើប្រាស់ទំនើបកម្មឌីជីថលបច្ចេកវិទ្យាព័ត៌មាន Web Application, Mobile Application, Data Storage Management System សម្រាប់គ្រប់គ្រងប្រព័ន្ធទិន្នន័យមន្ត្រីនគរបាលជាតិ (National Police Data Management System) ដែលប្រព័ន្ធគ្រប់គ្រងទិន្នន័យនេះមានសារៈប្រយោជន៍សំខាន់បម្រើដល់មន្ត្រីនគរបាលជាតិ ដើម្បីធានាក្នុងការផ្តល់ សេវាកម្មសុក្រឹត្យភាពឆាប់រហ័សក្នុងយុគ្គសម័យឌីជីថល រួមមានដូចជា៖
    - គ្រប់គ្រងបញ្ជីសំណុំឯកសារបទដ្ឋានគតិយុត្តនានារបស់មន្ត្រីនគរបាលជាតិ ដើម្បីឆ្លើយតបតម្រូវការផ្សេងៗក្នុងការស្រាវជ្រាវស្វែងរកនៅពេលអនាគត
    - គ្រប់គ្រង ធ្វើបច្ចុប្បន្នភាពទិន្នន័យសាវតាជាតិ ប្រវត្តិការងារឱ្យស្របតាមកាលៈទេសៈ
    - ពង្រឹងសក្តានុពល និងគ្រប់គ្រងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណនគរបាលជាតិដោយប្រព័ន្ធ QR Code ដែលបញ្ជាក់អំពីអត្តសញ្ញាណមន្ត្រីនគរបាលជាតិនៅតាមអង្គភាព-នាយកដ្ឋានបានត្រឹមត្រូវពិតប្រាកដ
    - គ្រប់គ្រងប្រព័ន្ធតាមដាន និងយកវត្តមានមន្ត្រីនគរបាលជាតិតាមប្រព័ន្ធបច្ចេកវិទ្យា (ប្រើប្រាស់អត្តសញ្ញាណប័ណ្ណនគរបាលជាតិ តាមរយៈការស្កេន QR Code)។

**៣.អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ** បានប្រើប្រាស់យន្តការ និងបច្ចេកទេសគ្រប់គ្រងប្រវត្តិរូបមន្ត្រីនគរបាលចំណុះអគ្គនាយកដ្ឋាននិងលំហូរឯកសាររដ្ឋបាលតាមប្រព័ន្ធ Web Application ដែលបានបង្កើតឡើង

និងប្រើប្រាស់ដោយនាយកដ្ឋានរដ្ឋបាល-សរុប តែមួយប៉ុណ្ណោះ។ ដោយឡែកអង្គភាពចំណុះដទៃទៀត នៅបន្តប្រើប្រាស់តាមបែបប្រពៃណី និងកត់ត្រារក្សាទុកទិន្នន័យនៅក្នុងកម្មវិធី Microsoft Word and Excel។

**៤.អគ្គនាយកដ្ឋានរដ្ឋបាល** តាមរយៈនាយកដ្ឋានបុគ្គលិកបានបង្កើតប្រព័ន្ធ Database ដោយសហការជាមួយក្រុមហ៊ុនឯកជន សម្រាប់គ្រប់គ្រងទិន្នន័យប្រវត្តិរូបមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដោយឡែកការគ្រប់គ្រងលំហូរឯកសាររដ្ឋបាល អង្គភាពក្រោមចំណុះទាំងអស់នៅបន្តអនុវត្ត តាមបែបប្រពៃណីនៅឡើយ ប៉ុន្តែមានគម្រោងអភិវឌ្ឍការគ្រប់គ្រងលំហូរឯកសាររដ្ឋបាល ទៅជាប្រព័ន្ធឌីជីថល។ ទន្ទឹមនេះ នាយកដ្ឋានមុខងារ និងធនធាន បានបង្កើតកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលចំនួន០២ថ្នាក់ រួមមាន៖ រដ្ឋបាលរាជធានី/ខេត្ត តាមរយៈអង្គភាពច្រកចេញចូលតែមួយ និងរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ តាមរយៈការិយាល័យច្រកចេញ ចូលតែមួយ។ ជាមួយគ្នានេះ នាយកដ្ឋានកំពុងដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធទូទាត់ថ្លៃសេវារដ្ឋបាល នៅរដ្ឋបាលរាជធានី/ខេត្ត ចំនួន០៨ តាមរយៈម៉ាស៊ីនបង់ប្រាក់ (Kios) និងបានបង្កើតកម្មវិធីទូរស័ព្ទដៃ "OWSM Cambodia" សម្រាប់អ្នកស្នើសុំសេវា តាមដានចរន្តឯកសារនៃការស្នើសុំសេវារដ្ឋបាលរបស់ខ្លួន។

**៥.អគ្គនាយកដ្ឋានពន្ធនាគារ** បានប្រើប្រាស់យន្តការ និងបច្ចេកទេសគ្រប់គ្រងទិន្នន័យបុគ្គលិកតាមប្រព័ន្ធ Database System និងត្រៀមរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យភស្តុភារ និងហិរញ្ញវត្ថុតាមប្រព័ន្ធ MIS (Management Information System)។ ដោយឡែក ការគ្រប់គ្រងលំហូរឯកសាររដ្ឋបាលនៅបន្តអនុវត្តតាមបែបប្រពៃណី និងប្រើប្រាស់តាមប្រព័ន្ធ Telegram ប៉ុណ្ណោះ។ នៅថ្ងៃអនាគត អគ្គនាយកដ្ឋានពន្ធនាគារស្នើសុំកម្មវិធីគ្រប់គ្រងចរន្តឯកសាររដ្ឋបាលបែបឌីជីថល ដែលផ្តល់ភាពងាយស្រួល និងឆាប់រហ័ស។

**៦.អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបញ្ចប់ដំណាក់កាលកសាងប្រព័ន្ធគ្រប់គ្រងចរន្តឯកសាររដ្ឋបាល និងគ្រប់គ្រងមន្ត្រីអន្តោប្រវេសន៍។ ដោយឡែកប្រព័ន្ធគ្រប់គ្រងការងារភស្តុភារនិងហិរញ្ញវត្ថុ ក៏ត្រូវបានធ្វើការសិក្សាជាបន្តបន្ទាប់ផងដែរ ដោយដាក់ឈ្មោះថា **ប្រព័ន្ធគ្រប់គ្រងឯកសារអន្តោប្រវេសន៍ឌីជីថល** ហៅកាត់ (e-GDI)។ បច្ចុប្បន្នប្រព័ន្ធ e-GDI នេះ ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងដើម្បីត្រួតពិនិត្យបញ្ហាបច្ចេកទេស និងចំណុចខ្វះខាតដែលនៅសេសសល់ផ្សេងៗសម្រាប់ធ្វើការកែសម្រួលឱ្យបានគ្រប់ជ្រុងជ្រោយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការបាននៅពេលខាងមុខឆាប់ៗនេះ។ ប្រព័ន្ធគ្រប់គ្រងឯកសារមន្ត្រីអន្តោប្រវេសន៍ មានទម្រង់ និងព័ត៌មានប្រហាក់ប្រហែលទៅនឹងទម្រង់ជីវប្រវត្តិរបស់មន្ត្រីនគរបាលជាតិ ដែលរៀបចំដោយនាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

**៧.បណ្ឌិត្យសភានគរបាលកម្ពុជា** បន្តអនុវត្តការងារគ្រប់គ្រងលំហូរឯកសាររដ្ឋបាល ការងារគ្រប់គ្រងបុគ្គលិក និងការងារគ្រប់គ្រងភស្តុភារនិងហិរញ្ញវត្ថុ តាមបែបប្រពៃណី (គ្រប់គ្រងដោយដៃ) នៅឡើយ។ ប៉ុន្តែបណ្ឌិត្យសភានគរបាលកម្ពុជាកំពុងរៀបចំ "**ផែនការបណ្ឌិត្យសភាឌីជីថល**" ដែលមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការដឹកនាំ និងគ្រប់គ្រង ដែលក្នុងនោះរួមមានការជួយសម្របសម្រួលការងារដល់អ្នកពាក់ព័ន្ធឱ្យបានឆាប់រហ័ស និងគ្រប់ជ្រុងជ្រោយ ការងារបណ្តុះបណ្តាលមានលក្ខណៈងាយស្រួល

ការរក្សាទុក និងទាញយកឯកសារពាក់ព័ន្ធមានភាពងាយស្រួល ឆាប់រហ័សសម្រាប់ការងារទំនាក់ទំនងនិងពិគ្រោះយោបល់ និងឆ្លើយតបបានទាន់ពេលវេលា។

៨.សាលាជាតិរដ្ឋបាលមូលដ្ឋាន មិនមានប្រព័ន្ធកម្មវិធីដោយឡែកសម្រាប់គ្រប់គ្រងកិច្ចការងាររដ្ឋបាល ការងារបុគ្គលិក និងការងារហិរញ្ញវត្ថុនៅឡើយទេ។ បច្ចុប្បន្ន សាលាជាតិរដ្ឋបាលមូលដ្ឋានកំពុងប្រើប្រាស់ប្រព័ន្ធកម្មវិធីដែលមានស្រាប់នៅលើទីផ្សារសម្រាប់ធ្វើការគ្រប់គ្រង និងរក្សាទុកទិន្នន័យពាក់ព័ន្ធនានា។ ដោយឡែកការគ្រប់គ្រងទិន្នន័យវគ្គបណ្តុះបណ្តាល សាលាជាតិរដ្ឋបាលមូលដ្ឋានកំពុងប្រើប្រាស់សាកល្បង **ប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាល** (Training Management System)។

## ២.២. ស្ថានភាពក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងការផ្សព្វផ្សាយអប់រំ

តម្រូវការធនធានមនុស្សក្នុងវិស័យបច្ចេកវិទ្យាឌីជីថល ជារឿងមួយដ៏សំខាន់នៅក្នុងការជំរុញប្រទេសកម្ពុជាឱ្យធ្វើដំណើរទាន់សន្ទុះនៃការរីកចម្រើនយ៉ាងគំហុកនៃបច្ចេកវិទ្យាឌីជីថលនានា ជាពិសេសដំណើរការធ្វើបរិវត្តកម្មឌីជីថលនៅទូទាំងសកលលោកក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្ម៤.០។ ការអភិវឌ្ឍធនធានមនុស្សដោយធ្វើការពង្រឹងចំណេះដឹងមូលដ្ឋានបច្ចេកវិទ្យា គឺជាកត្តាដ៏សំខាន់សម្រាប់គាំទ្រដល់ការពង្រឹង និងពង្រីកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអភិវឌ្ឍសង្គមជាតិ ជំរុញកំណើនសេដ្ឋកិច្ចប្រទេស និងត្រូវបានយកចិត្តទុកដាក់ដោយរាជរដ្ឋាភិបាលកម្ពុជាផងដែរ។ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចដាក់ចេញនូវគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ទ-ប.គ.ព) ឆ្នាំ២០២០ ឆ្ពោះទៅរកសន្តិភាព និងសកម្មភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ គោលនយោបាយនេះបានកំណត់ទិសដៅដែលត្រូវសម្រេចឱ្យបាន លើការពង្រឹងចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់មន្ត្រីរាជការក៏ដូចជាប្រជាពលរដ្ឋកម្ពុជាទូទៅ ដើម្បីត្រៀមខ្លួនទទួលយកនូវការវិនិយោគ និងដាក់ឱ្យប្រើប្រាស់នូវបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០២០ ដូចខាងក្រោម៖

| សន្ទស្សន៍មន្ត្រីរាជការ និងធនធានមនុស្សជំនាញបច្ចេកវិទ្យាព័ត៌មាន | អត្រាគោលដៅឆ្នាំ២០២០ |
|---|---|
| អត្រាមន្ត្រីរាជការថ្នាក់កណ្តាលដែលចេះប្រើប្រាស់សូហ្វវែរកម្មវិធីមូលដ្ឋាន | ៩៥% |
| អត្រាមន្ត្រីរាជការថ្នាក់មូលដ្ឋានដែលចេះប្រើប្រាស់សូហ្វវែរកម្មវិធីមូលដ្ឋាន | ៧៥% |
| អត្រាសិស្សដែលបញ្ចប់ការសិក្សាទុតិយភូមិទទួលបានការបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈផ្នែក ប.គ.ព | ១០០% |
| អត្រាធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈ ប.គ.ព ធៀបជាមួយជំនាញដទៃទៀត | ១៥% |
| អត្រានៃអ្នកបច្ចេកទេសក្នុងវិស័យ ប.គ.ព សម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ | ៣០ នាក់ក្នុង ១លាននាក់ |
| អត្រានៃអ្នកស្រាវជ្រាវក្នុងវិស័យ ប.គ.ព | ១០ នាក់ ក្នុង ១លាននាក់ |

*(គោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០)*

នៅក្នុងគោលនយោបាយ ទ-ប.គ.ព ឆ្នាំ២០២០ រាជរដ្ឋាភិបាលបានកំណត់ទិសដៅជំរុញឱ្យមន្ត្រីរាជការតាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់សារអេឡិចត្រូនិក (E-mail) ឱ្យបាន១០០% ធ្វើការស្វែងយល់អំពីការប្រើប្រាស់អ៊ីនធឺណិត ការប្រើប្រាស់វត្ថុតភ្ជាប់នឹងអ៊ីនធឺណិត (Internet of Things) បច្ចេកវិទ្យាពពក និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននានា ផងដែរ។

**តើអ្វីទៅជាចំណេះដឹងមូលដ្ឋាន ប.គ.ព. ?**

ចំណេះដឹងមូលដ្ឋាន ប.គ.ព. គឺជាសមត្ថភាពក្នុងការប្រើប្រាស់ផលិតផល សេវាកម្ម និងបច្ចេកវិទ្យា ប.គ.ព. ដែលមាននៅក្នុងសង្គមបច្ចុប្បន្ន ដើម្បីទទួលយក វិភាគ បង្កើត និងចែករំលែកព័ត៌មានទៅកាន់ជនណាម្នាក់ រឺជាក្រុម ក្នុងគោលបំណងសិក្សា បំពេញការងារអាជីវកម្ម និងជីវភាពរស់នៅប្រចាំថ្ងៃ។ និយមន័យនេះត្រូវបានដកស្រង់កែសម្រួលចេញពីឯកសារស្រាវជ្រាវ ឯកសារបោះពុម្ពផ្សាយរបស់ស្ថាប័នជំនាញមួយចំនួន។ នៅឆ្នាំ២០១១ វិទ្យាស្ថានសម្រាប់បច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ (IITE - Institute for Information Technologies in Education) របស់អង្គការយូណេស្កូបានកំណត់ថា ធាតុសំខាន់បំផុតនៃអក្ខរកម្មឌីជីថលសម្រាប់អ្នកប្រើប្រាស់កុំព្យូទ័រពេលអនាគត និងអ្នកជំនាញព័ត៌មានវិទ្យារួមមាន សមត្ថភាពប្រើប្រាស់ គ្រប់គ្រង វិភាគ វាយតម្លៃ រួមបញ្ចូល បង្កើត និងចែករំលែកព័ត៌មានជាលក្ខណៈបុគ្គល ឬជារួមនៅក្នុងបរិស្ថានមួយដូចជា បណ្តាញហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ (Network Infrastructure) ការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ គេហទំព័រ ក្នុងគោលបំណងរៀនសូត្រ ធ្វើអាជីវកម្ម និងជីវភាពរស់នៅប្រចាំថ្ងៃ។

និយមន័យចំណេះដឹងមូលដ្ឋាន ប.គ.ព. គួររួមបញ្ចូលនូវចំណេះដឹងមូលដ្ឋានលើការប្រើប្រាស់ផលិតផល និងសេវាកម្មនានាស្ថិតក្នុងប្រព័ន្ធ ប.គ.ព. លើបណ្តាញហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ដែលមានការវិវត្តន៍ទៅតាមសម័យកាល។ ការវិវត្តន៍យ៉ាងលឿននៃ ប.គ.ព. បានបង្កើតនូវបច្ចេកវិទ្យាទំនើបជាច្រើនដូចជា គេហទំព័រ កម្មវិធីសូហ្វវែរ (Software Program) សម្រាប់ប្រើប្រាស់ក្នុងឧបករណ៍ចល័ត (Mobile Application) បច្ចេកវិទ្យាបំពាក់ប្រព័ន្ធអ៊ីនធឺណិតក្នុងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ (IoTs) និងបច្ចេកវិទ្យាពពក ជាដើម។ បច្ចុប្បន្នមានស្ថាប័នអន្តរជាតិមួយគឺ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍវិស័យសេដ្ឋកិច្ច (OECD) បានធ្វើចំណាត់ថ្នាក់សម្ភារសូហ្វវែរ(Software) ព្រមទាំងសេវាកម្មដែលជាផលិតផល និងសេវាកម្មរបស់ ប.គ.ព. (ICT products and services) ដោយក្នុងនោះបានធ្វើការបែងចែកផលិតផល និងសេវាកម្ម ប.គ.ព. ជាចំណាត់ថ្នាក់ផ្សេងៗ។ និយមន័យ និងចំណាត់ថ្នាក់ ប.គ.ព. (ICT products and services) របស់ OECD នេះ ត្រូវបានប្រើប្រាស់សម្រាប់ការវាស់វែង ការវិភាគ ការស្រាវជ្រាវ ដោយអ្នកស្រាវជ្រាវ និងអ្នកសេដ្ឋកិច្ច ក្នុងវិស័យសេដ្ឋកិច្ចព័ត៌មាននៅលើពិភពលោក។

ដូចនេះ យើងអាចធ្វើការកំណត់បានថា ចំណេះដឹងមូលដ្ឋាន ប.គ.ព. របស់មន្ត្រីរាជការក្រសួងមហាផ្ទៃ គឺសំដៅទៅលើសមត្ថភាពរបស់មន្ត្រីរាជការក្នុងការប្រើប្រាស់ផលិតផល និងសេវាកម្មក្នុងវិស័យ ប.គ.ព. ដែលអង្គភាពចំណុះក្រសួងមហាផ្ទៃកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន ឬមានគម្រោងដាក់ឱ្យប្រើប្រាស់នាពេលអនាគត ដើម្បីទទួលយកមកគ្រប់គ្រង បង្កើត ចែករំលែកព័ត៌មានទៅកាន់ជនណាម្នាក់ ឬជារួមក្នុងគោលបំណងសិក្សា

បំពេញការងារប្រចាំថ្ងៃ បម្រើដល់តួនាទីភារកិច្ចរបស់អង្គភាពឱ្យសម្រេចដល់គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ និយមន័យនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីកំណត់វិសាលភាពនៃការសិក្សា ការអភិវឌ្ឍ និងពង្រឹងចំណេះដឹងមូលដ្ឋាន ប.គ.ព. នៅក្នុងផែនការពង្រឹងចំណេះដឹងមូលដ្ឋាន ប.គ.ព. ឆ្នាំ២០២៣-២០២៧ សម្រាប់មន្ត្រីរាជការក្រសួងមហាផ្ទៃ។

តាមរយៈការធ្វើបច្ចុប្បន្នភាពសម្រង់ស្ថិតិស្តីពីស្ថានភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅតាមបណ្តាអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ បានឆ្លុះបញ្ចាំងឃើញថាស្ទើរតែគ្រប់អង្គភាពចំណុះទាំងអស់នៅមិនទាន់បានត្រៀមខ្លួនរួចរាល់សម្រាប់ការធ្វើឌីជីថលលូបនីយ៍កម្មនៅឡើយ ដូច្នេះការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីជំនាញបច្ចេកវិទ្យាព័ត៌មាននិងឌីជីថលកម្រិតមធ្យម និងកម្រិតខ្ពស់ ជាពិសេសមន្ត្រីមានសមត្ថភាពក្នុងការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាព (Cyber Security) ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ (Network Infrastructure) និង អ្នកអភិវឌ្ឍកម្មវិធីសូហ្វវែរ (Software Developer) ជាដើម នៅមានកម្រិត និងចំនួនតិចតួចនៅឡើយ។ ដូចនេះ ការរៀបចំយុទ្ធសាស្ត្រ និងសកម្មភាពបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីជំនាញដែលមានស្រាប់ដើម្បីប្រែក្លាយទៅជាមន្ត្រីជំនាញជាន់ខ្ពស់ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារជូនអង្គភាពក៏ដូចជាក្រសួងក្នុងការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាឌីជីថល គឺជាកិច្ចការងារដ៏សំខាន់មួយនៅក្នុងចំណោមកិច្ចការងារអាទិភាពនានារបស់ក្រសួងមហាផ្ទៃ ដើម្បីទទួលបានធនធានមនុស្សគ្រប់គ្រាន់ពេញលេញ និងត្រៀមខ្លួនរួចជាស្រេចសម្រាប់ទទួលយក និងអនុវត្តស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។

បន្ថែមពីលើការងារបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី កិច្ចការងារផ្សព្វផ្សាយអប់រំ (Awareness) ក៏ជាកិច្ចការងារសំខាន់មួយក្នុងការចូលរួមចំណែកបង្កើនចំណេះដឹង អំពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ក៏ដូចជាការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនទូទៅ ព្រមទាំងមន្ត្រីរាជការទាំងនៅក្នុងស្ថាប័ន និងនៅក្រៅស្ថាប័នទាំងអស់ បានយល់ដឹងជ្រួតជ្រាបអំពីប្រព័ន្ធបច្ចេកវិទ្យាដែលក្រសួងបានដាក់ឱ្យប្រើប្រាស់ ជាពិសេសប្រព័ន្ធបច្ចេកវិទ្យាដែលប្រើប្រាស់សម្រាប់ការផ្សព្វផ្សាយព័ត៌មានផ្សេងៗ និងប្រព័ន្ធបច្ចេកវិទ្យាបម្រើដល់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ បច្ចុប្បន្នយើងសង្កេតឃើញថាគ្រប់អង្គភាពចំណុះក្រសួងទាំងអស់បានប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងសង្គមដូចជា Facebook, Instagram, Twitter, YouTube, Telegram ។ល។ ក្នុងគោលបំណងផ្សព្វផ្សាយអំពីសកម្មភាពការងារប្រចាំថ្ងៃរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅតាមអង្គភាពនីមួយៗជូនសាធារណជនផង ប្រើប្រាស់សម្រាប់ផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង ឬគោលការណ៍ណែនាំផ្សេងៗរបស់ប្រធានអង្គភាពដល់មន្ត្រីក្រោមឱវាទផង។ ក្នុងនោះអង្គភាពចំណុះក្រសួងចំនួន ៥ រួមមាន៖ ១-អគ្គលេខាធិការដ្ឋាន ២-អគ្គស្នងការដ្ឋាននគរបាលជាតិ ៣-អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ៤-អគ្គនាយកដ្ឋានរដ្ឋបាល និង ៥-អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានធ្វើការអភិវឌ្ឍ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដើម្បីធ្វើការផ្សព្វផ្សាយ ក៏ដូចជាផ្តល់សេវាកម្មពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួនជូនសាធារណជន

បន្ថែមពីលើបណ្តាញទំនាក់ទំនងសង្គមដែលមានស្រាប់នៅក្នុងកម្មវិធីទូរស័ព្ទវៃឆ្លាត (Mobile Application IOS and Android) ដែលអាចឱ្យប្រជាពលរដ្ឋទាញយកទៅប្រើប្រាស់បានដោយសេរី និងឥតគិតថ្លៃ។

អង្គភាពដែលមានផែនការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញបច្ចេកវិទ្យាព័ត៌មាន (ជំនាញអភិវឌ្ឍកម្មវិធីសូហ្វវែរ (Software Development) ជំនាញគ្រប់គ្រងបណ្តាញណេតវើក (Network Management System) និងជំនាញឌីស្សាញ ។ល។ និងមានផែនការផ្សព្វផ្សាយអប់រំសម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន នៅផ្ទៃក្នុងអង្គភាព អ្នកទទួលសេវា និងសាធារណជន មានដូចខាងក្រោម ៖

**១.អគ្គលេខាធិការដ្ឋាន** បានរៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញបច្ចេកវិទ្យាព័ត៌មានកម្រិតបឋម មធ្យម និងកម្រិតខ្ពស់ រយៈពេល៣ឆ្នាំ រួមមានវគ្គសិក្សាសរុបចំនួន ១៩វគ្គ។ ដោយឡែកសម្រាប់ការងារផ្សព្វផ្សាយអប់រំអំពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសំខាន់ៗជូនសាធារណជន ត្រូវបានធ្វើឡើងតាមរយៈទំព័រហ្វេសប៊ុក (Facebook Page) ផ្លូវការរបស់នាយកដ្ឋានព័ត៌មានវិទ្យា ដែលមានលក្ខណៈជាអត្ថបទ ឬវីដេអូអប់រំផ្សេងៗ។ ដោយឡែកការផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំតាមបណ្តាអង្គភាពចំណុះ ឬសេចក្តីជូនដំណឹងស្តីពីការផ្តល់សេវាសាធារណៈផ្សេងៗ អង្គភាពបានប្រើប្រាស់វិធីសាស្ត្រ ដូចខាងក្រោម ៖

- វេបសាយក្រសួងមហាផ្ទៃ (www.interior.gov.kh)
- កម្មវិធីព័ត៌មានទាន់ហេតុការណ៍ក្រសួងមហាផ្ទៃ (MOI Mobile App)
- ទំព័រហ្វេសបុកផ្លូវការក្រសួងមហាផ្ទៃ (Facebook Page/Ministry of Interior)
- Telegram Channel (សារព័ត៌មានក្រសួងមហាផ្ទៃ)
- Twitter (ក្រសួងមហាផ្ទៃ)
- Instagram (ក្រសួងមហាផ្ទៃ)
- YouTube (ក្រសួងមហាផ្ទៃ)

ទន្ទឹមគ្នានោះការងារអង្កេតតាមដាន និងឆ្លើយតបមតិមហាជន ព្រមទាំងបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងអង្គភាពលើបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានា អង្គភាពបានរៀបចំក្រុមការងារដែលមានមន្ត្រីជំនាញធ្វើការអង្កេតតាមដាន និងសំយោគព័ត៌មានជាប្រចាំថ្ងៃ ដើម្បីគោរពរាយការណ៍ និងស្នើសុំគោលការណ៍របស់ថ្នាក់ដឹកនាំ ដើម្បីចាត់ការបន្តតាមនីតិវិធី មិនមានប្រើប្រាស់ឧបករណ៍ ឬប្រព័ន្ធកម្មវិធី (Tool or Software) ជាជំនួយទេ។

**២.អគ្គស្នងការដ្ឋាននគរបាលជាតិ** មិនមានផែនការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មានលម្អិតនៅឡើយទេ ប៉ុន្តែមន្ត្រីជំនាញត្រូវបានចាត់បញ្ជូនទៅចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗទាំងក្នុង និងក្រៅប្រទេសតាមរយៈកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាដៃគូ ឬក្រោមជំនួយឧបត្ថម្ភផ្សេងៗតាមជំនាញរបស់អង្គភាពចំណុះ និងធ្វើការបណ្តុះបណ្តាលផ្ទាល់នៅហ្នឹងកន្លែង ព្រមទាំងបានធ្វើការផ្សព្វផ្សាយអប់រំតាមរយៈគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមរបស់អង្គភាពនីមួយៗផ្ទាល់ផងដែរ។

ដើម្បីធ្វើការផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអង្គភាពចំណុះ ឬជូនដំណឹងស្តីពីការផ្តល់សេវាសាធារណៈផ្សេងៗ អគ្គស្នងការដ្ឋាននគរបាលជាតិប្រើប្រាស់វិធីសាស្ត្រ ដូចខាងក្រោម ៖

- គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម និងកម្មវិធីទូរស័ព្ទចល័ត (Mobile Application)
- ទទួលពាក្យបណ្តឹង ឬរាយការណ៍តាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (១១៧) និង/ឬ តាមការកំណត់របស់អង្គភាពក្រោមចំណុះ
- ទទួលពាក្យបណ្តឹង ឬរាយការណ៍តាមរយៈបណ្តាញទំនាក់ទំនងសង្គម

អគ្គស្នងការដ្ឋាននគរបាលជាតិបានអនុវត្តវិធីសាស្ត្រចំនួន ២ លើការងារអង្កេតតាមដាន និងឆ្លើយតបមតិមហាជន ព្រមទាំងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងអង្គភាពលើបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានាដូចជា៖

- រៀបចំក្រុមការងារប្រតិកម្មរហ័សដើម្បីធ្វើការឆ្លើយតបតាមបណ្តានាយកដ្ឋាន/អង្គភាព និងស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត
- រៀបចំក្រុមការងារតាមដានមតិយោបល់លើគេហទំព័រហ្វេសប៊ុក (Facebook) របស់ថ្នាក់ដឹកនាំ

**៣.អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ** មានផែនការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញបច្ចេកវិទ្យាព័ត៌មានដូចជា គ្រប់គ្រងម៉ាស៊ីនមេ (Server Management) គ្រប់គ្រងបណ្តាញហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ គ្រប់គ្រងទិន្នន័យ (Database Management) ជួសជុលកុំព្យូទ័រ និងការគ្រប់គ្រងហានិភ័យ (Risk Management) ជាដើម។ បច្ចុប្បន្នអង្គភាពកំពុងប្រើប្រាស់វិធីសាស្ត្រចំនួន ៩ សម្រាប់ធ្វើការផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន-អង្គភាព ព្រមទាំងកិច្ចប្រតិបត្តិការនានារបស់កងកម្លាំងនគរបាលជាតិ ឬធ្វើការជូនដំណឹងអំពីការផ្តល់សេវាសាធារណៈផ្សេងៗ រួមមានដូចជា៖

- គេហទំព័រអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ (www.gdlf-kh.com)
- ហ្វេសប៊ុកផេក (Facebook Page) ឈ្មោះ អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ-GDLF
- ហ្វេសប៊ុកផេក (Facebook Page) របស់អង្គភាពនីមួយៗចំណុះអគ្គនាយកដ្ឋាន
- ការបោះផ្សាយទស្សនាវដ្តី
- ប្រព័ន្ធ Telegram និង WhatApp
- ហ្វេសប៊ុកផេក (Facebook Page) (បណ្តាញព័ត៌មានក្រសួងមហាផ្ទៃ MOI News)
- ឆានែលយូធូបបណ្តាញព័ត៌មានក្រសួងមហាផ្ទៃ (MOI News YouTube Channel)
- គេហទំព័របណ្តាញព័ត៌មានក្រសួងមហាផ្ទៃ (www.moinews.gov.kh)
- ស្ថានីយ៍ទូរទស្សន៍មហាផ្ទៃ (MOI TV) និងស្ថានីយ៍វិទ្យុមហាផ្ទៃ (ភ្នំពេញ FM៩០.៣០Mhz បាត់ដំបង FM៩២.៣០Mhz និងព្រៃវែង FM១០៥.៣០Mhz)។

អគ្គនាយកដ្ឋានបានអនុវត្តវិធីសាស្ត្រចំនួន ៤ លើការងារអង្កេតតាមដាន និងឆ្លើយតបមតិមហាជន ព្រមទាំងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងអង្គភាពលើបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានាដូចជា៖

- បង្កើតក្រុមការងារពិនិត្យ តាមដានរាល់ការបញ្ចេញមតិក្នុងហ្វេសប៊ុកផេករបស់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះ
- តាមដានសម្រង់ខ្លឹមសារប្រចាំថ្ងៃតាមរយៈបណ្តាញទំនាក់ទំនងសង្គមផ្សេងៗ និងសារព័ត៌មាននានាពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមចំណុះ
- ធ្វើការឆ្លើយតបមតិយោបល់ (Comment) ដែលបានផ្សព្វផ្សាយនៅលើហ្វេសប៊ុកឯកជនតាមរយៈក្រុមការងារប្រតិកម្មរហ័ស
- រៀបចំសេចក្តីប្រកាសព័ត៌មាន ការឆ្លើយបំភ្លឺជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ជូនសាធារណជន និងបណ្តាញសារព័ត៌មាននានា។

**៤.អគ្គនាយកដ្ឋានរដ្ឋបាល** ពុំមានផែនការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញបច្ចេកវិទ្យាព័ត៌មាន និងផែនការពាក់ព័ន្ធនឹងការផ្សព្វផ្សាយអប់រំសម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៅឡើយទេ ប៉ុន្តែដើម្បីធ្វើការផ្សព្វផ្សាយអំពីសកម្មការងាររបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងអង្គភាពចំណុះ ឬធ្វើការជូនដំណឹងស្តីពីការផ្តល់សេវាសាធារណៈផ្សេងៗ អគ្គនាយកដ្ឋានបានប្រើប្រាស់វិធីសាស្ត្រ ដូចខាងក្រោម៖

- តាមរយៈគេហទំព័រ និងទំព័រហ្វេសប៊ុកផេក (Facebook Page) ផ្លូវការរបស់អគ្គនាយកដ្ឋាន https://www.facebook.com/general.administration.moi
- គ្រុបតេលេក្រាម (Telegram Channel)
- តាមរយៈគេហទំព័រ http://owso.gov.kh
- តាមរយៈលិខិតបញ្ជូនបន្តទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្សព្វផ្សាយ
- ផលិតជាខិត្តប័ណ្ណ ប័ណ្ណព័ត៌មានតម្លៃសេវា ស្ប៉តវិទ្យុនិងទូរទស្សន៍ ចម្រៀង វីដេអូឯកសារបទយកការណ៍ជាដើម និងធ្វើការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា
- ហ្វេសប៊ុកផេក (Facebook Page) ឈ្មោះ http://facebook.com/dfr.kh
- បង្កើត YouTube Channel ឈ្មោះ http://www.youtube.com/user/owsogovkh
- សហការជាមួយអង្គការក្រៅរដ្ឋាភិបាល (USAID) សម្រាប់គម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ ដោយបានរៀបចំបង្កើតជា (Facebook Chatbot) និងសារសំលេងតាមទូរស័ព្ទ (VTR) នៅតាមខេត្ត/ស្រុក/ក្រុង គោលដៅមួយចំនួនដើម្បីផ្សព្វផ្សាយអំពីការផ្តល់សេវាជូនប្រជាពលរដ្ឋ
- សហការជាមួយគម្រោងសាកល្បងប្រើប្រាស់កម្មវិធីទូរស័ព្ទស្មាតហ្វូន (Mobile App មតិយើង) សម្រាប់ការទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ លើការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិរបស់អង្គការតម្លាភាពកម្ពុជា

- បានបង្កើត Mobile App (Android) OWSM Cambodia សម្រាប់ប្រជាពលរដ្ឋមើលតារាងតម្លៃសេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងពិនិត្យមើលវឌ្ឍនភាព បញ្ហាប្រឈមនៃការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវារដ្ឋបាលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ។

អគ្គនាយកដ្ឋានបានអនុវត្តវិធីសាស្ត្រចំនួន ២ លើការងារអង្កេតតាមដាន និងឆ្លើយតបមតិមហាជនព្រមទាំងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងអង្គភាពលើបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានាដូចជា៖

- ប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ឬអ៊ីម៉ែល (Facebook, E-mail), ទូរស័ព្ទ និងលិខិតលាយល័ក្ខអក្សរ
- សហការជាមួយដៃគូអភិវឌ្ឍ រៀបចំបង្កើតកម្មវិធីនៅក្នុងទូរស័ព្ទស្មាតហ្វូន (Android) សម្រាប់ទទួលមតិយោបល់ពីមហាជន (Mobile App មតិយើង)។

**៥.អគ្គនាយកដ្ឋានអន្តោប្រវេសន៍** ពុំមានផែនការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញបច្ចេកវិទ្យាព័ត៌មាន (អភិវឌ្ឍកម្មវិធីសូហ្វវែរ ឌីហ្សាញ បណ្តាញណេតវើក។ល។) នៅឡើយទេ មានតែការបណ្តុះបណ្តាលជំនាញខ្លីៗកម្រិតមូលដ្ឋានជូនមន្ត្រីនៅតាមបណ្តាអង្គភាពចំណុះ ដើម្បីពង្រឹងសមត្ថភាពប្រើប្រាស់ និងថែទាំប្រព័ន្ធបច្ចេកវិទ្យារបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ប៉ុណ្ណោះ និងពុំទាន់មានឯកសារបណ្តុះបណ្តាលលក្ខណៈស្តង់ដា (Training Curriculum) នៅឡើយទេ។ ដោយឡែក សម្រាប់ការងារផ្សព្វផ្សាយអប់រំ (Awareness) ក៏ដូចជាផ្សព្វផ្សាយអំពីការផ្តល់សេវាសាធារណៈ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗ ជូនជនបរទេស និងសាធារណជន អគ្គនាយកដ្ឋានអន្តោប្រវេសន៍បានប្រើប្រាស់វិធីសាស្ត្រ ដូចខាងក្រោម៖

- ហ្វេសប៊ុកផេក (Facebook Page) របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍(www.facebook.com/GDIOfficial)
- ប្រព័ន្ធផ្តល់ព័ត៌មានក្នុងទូរស័ព្ទស្មាតហ្វូនរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ (GDI News App)
- គេហទំព័ររបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ (www.immigration.gov.kh)
- ការចុះបណ្តុះបណ្តាលរបស់មន្ត្រីជំនាញជូនដល់មន្ត្រីនគរបាលតាមបណ្តារាជធានី/ខេត្ត
- ផ្សព្វផ្សាយ និងជូនដំណឹងដោយផ្ទាល់ដល់ម្ចាស់ ឬអ្នកកាន់កាប់លំនៅដ្ឋាន ដែលមានជនបរទេសស្នាក់នៅ។

អគ្គនាយកដ្ឋានបានអនុវត្តវិធីសាស្ត្រចំនួន ៦ លើការងារអង្កេតតាមដាន និងឆ្លើយតបមតិមហាជនព្រមទាំងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងអង្គភាពលើបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានាដូចជា៖

- តាមរយៈការផ្តល់មតិតាមហ្វេសប៊ុកផេក(Facebook Page) របស់អគ្គនាយកដ្ឋាន
- ព័ត៌មានចំហតាមសារព័ត៌មាន និងបណ្តាញទំនាក់ទំនងសង្គម
- បង្កើតប្រអប់សំបុត្រនៅគ្រប់ប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ

- ធ្វើការឆ្លើយតបបំភ្លឺជាសាធារណៈ ដោយប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម
- ធ្វើការឆ្លើយតបដោយផ្ទាល់តាមលិខិត ឬការជួបបំភ្លឺជូនសាមីជន ឬអង្គភាពផ្ទាល់
- តាមរយៈទូរស័ព្ទប្រចាំការ (Hot Line) និងតាមប្រព័ន្ធ Telegram ជាដើម។

**៦.អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** ពុំទាន់មានផែនការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញបច្ចេកវិទ្យាព័ត៌មាន (អភិវឌ្ឍកម្មវិធីសូហ្វវែរ ឌីហ្សាញ បណ្តាញណេតវើក។ល។) នៅឡើយទេ ប៉ុន្តែបានចាត់បញ្ជូនមន្ត្រីចូលរួមជាសិក្ខាកាមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាព័ត៌មានដូចជា៖

- គោលការណ៍សុវត្ថិភាព
- Linux Administration (ការប្រើប្រាស់ Admin System in Linux) រយៈពេល ៣២ម៉ោង
- រចនា (UX/UI) រយៈពេល ៦០ម៉ោង
  - វិភាគពីការប្រើប្រាស់របស់អ្នកប្រើប្រាស់ប្រព័ន្ធ
  - រចនាផ្ទាំង (User interface) សម្រាប់ Website and Mobile App
- Data Science and Big Data Analytics រយៈពេល ៣០ថ្ងៃ។

អគ្គនាយកដ្ឋានបានធ្វើការផ្សព្វផ្សាយអប់រំតាមរយៈ Mobile App, Website and Facebook Page របស់អគ្គនាយកដ្ឋានផ្ទាល់ និងធ្វើខិត្តប័ណ្ណផ្សព្វផ្សាយទៅដល់គ្រប់រដ្ឋបាលរាជធានី/ខេត្ត បន្ទាប់មកធ្វើការចែកចាយបន្តតាមទីតាំងផ្តល់សេវាអត្តសញ្ញាណកម្មដែលនៅជិតពលរដ្ឋ។

អគ្គនាយកដ្ឋានអនុវត្តវិធីសាស្ត្រចំនួន ២ លើការងារអង្កេតតាមដាន និងពិនិត្យមើលបញ្ហាផ្សេងៗពាក់ព័ន្ធនឹងអង្គភាពលើបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានាដូចជា៖

- បង្កើតក្រុមការងារប្រចាំការសម្រាប់តាមដាន និងពិនិត្យមើលមតិមហាជន ដើម្បីធ្វើការឆ្លើយតបសំណួរ និងបញ្ហាផ្សេងៗរបស់ប្រជាពលរដ្ឋដែលបានលើកឡើងតាមរយៈ ១-ហ្វេសបុកផេករបស់អគ្គនាយកដ្ឋាន ២-កម្មវិធីទូរស័ព្ទស្មាតហ្វូន (gdi eServices) និង៣-ប្រព័ន្ធទូរស័ព្ទឥតគិតថ្លៃ (១២៧១)
- ដាក់ប្រអប់សំបុត្រនៅកន្លែងផ្តល់សេវា ដើម្បីទទួលយកមតិយោបល់ និងបញ្ហាផ្សេងៗរបស់ប្រជាពលរដ្ឋនៅពេលពួកគាត់មករកសេវាអត្តសញ្ញាណកម្ម។

អគ្គនាយកដ្ឋានប្រើប្រាស់វិធីសាស្ត្រចំនួន ៣ ដើម្បីធ្វើការឆ្លើយតបមតិមហាជន និងបញ្ហាផ្សេងៗគឺ៖

- Facebook Page ក្រុមការងារតាមជំនាញបានឆ្លើយតបតាមរយៈ Comment ផ្ញើសារចូលប្រអប់សារផ្ទាល់ និងទាក់ទងទៅកាន់ប្រជាពលរដ្ឋផ្ទាល់តាមរយៈលេខទូរស័ព្ទ
- កម្មវិធីទូរស័ព្ទស្មាតហ្វូន (gdi eServices) ក្រុមការងារតាមជំនាញបានឆ្លើយតបផ្ទាល់ទៅកាន់ប្រជាពលរដ្ឋតាមរយៈកម្មវិធីទូរស័ព្ទស្មាតហ្វូនផ្ទាល់
- ប្រព័ន្ធទូរស័ព្ទឥតគិតថ្លៃ (១២៧១) នៅពេលពលរដ្ឋមានជួបបញ្ហាអ្វីមួយ ឬចង់ចូលរួមជាមតិយោបល់ អាចធ្វើការទំនាក់ទំនងសាកសួរតាមរយៈលេខទូរស័ព្ទឥតគិតថ្លៃ ១២៧១ នឹងមានមន្ត្រីជំនាញប្រចាំការតាមនាយកដ្ឋាននីមួយៗធ្វើការឆ្លើយតបតាមជំនាញរៀងៗខ្លួន។

**៧.បណ្ឌិត្យសភានគរបាលកម្ពុជា** មានរៀបចំផែនការបណ្តុះបណ្តាលផ្ទៃក្នុងលើជំនាញព័ត៌មានវិទ្យា ដែលជាតម្រូវការចាំបាច់របស់អង្គភាពនីមួយៗប្រចាំឆ្នាំ រួមមាន៖

- ការបណ្តុះបណ្តាលមន្ត្រី វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម សារអេឡិចត្រូនិក កម្មវិធីប្រជុំតាមអនឡាញ (Zoom, Google meet, Microsoft team...) កាត់តរូបភាពវីដេអូនិងរចនារូបភាព ការប្រើប្រាស់បច្ចេកវិទ្យាក្លោដ (Cloud) កុំព្យូទ័ររដ្ឋបាល (Microsoft Offices) និងបទល្មើសបច្ចេកវិទ្យា។
- ការបណ្តុះបណ្តាលគ្រូនគរបាលជាតិ វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់សេវាកម្មក្លោដ (Cloud) បទល្មើសបច្ចេកវិទ្យា សន្តិសុខសាយប័រ និងប្រព័ន្ធគ្រប់គ្រងការបង្រៀនតាមអនឡាញ
- ការបណ្តុះបណ្តាលនិស្សិត បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រវិទ្យាសាស្រ្តនគរបាលជំនាញប្រឆាំងបទល្មើសបច្ចេកវិទ្យា និងវិទ្យាសាស្រ្តកុំព្យូទ័រ។

បណ្ឌិត្យសភានគរបាលកម្ពុជា ប្រើប្រាស់វិធីសាស្រ្តចំនួន ៣ ដើម្បីធ្វើការផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ ឬធ្វើការជូនដំណឹងស្តីពីការផ្តល់សេវាសាធារណៈផ្សេងៗ ដូចខាងក្រោម ៖

- វេបសាយបណ្ឌិត្យសភានគរបាលកម្ពុជា(www.pac.edu.kh)
- ទំព័រហ្វេសប៊ុក (Facebook Page) ផ្លូវការបណ្ឌិត្យសភានគរបាលកម្ពុជា (Facebook Page/pac.edu.kh)
- YouTube Channel (Police Academy of Cambodia)

បណ្ឌិត្យសភាបានអនុវត្តវិធីសាស្រ្តចំនួន ៣ លើការងារអង្កេតតាមដាន និងឆ្លើយតបមតិមហាជន ព្រមទាំងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងអង្គភាពលើបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានាដូចជា៖

- ចាត់តាំងអ្នកនាំពាក្យ និងអ្នកឆ្លើយតប
- តាមរយៈបណ្តាញទំនាក់ទំនងសង្គម និងសារព័ត៌មាន
- តាមរយៈលិខិតរដ្ឋបាល។

**៨.អគ្គនាយកដ្ឋានពន្ធនាគារ** ពុំទាន់មានផែនការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញបច្ចេកវិទ្យាព័ត៌មាន (អភិវឌ្ឍកម្មវិធីសូហ្វវែរ ឌីហ្សាញ បណ្តាញណេតវើក។ល។) នៅឡើយទេ ប៉ុន្តែអគ្គនាយកដ្ឋានមានសកម្មភាពពាក់ព័ន្ធនឹងការផ្សព្វផ្សាយអប់រំ (Awareness) សម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាមួយចំនួននៅផ្ទៃក្នុងអង្គភាពដូចជា សម្រង់ព័ត៌មាន សេចក្តីណែនាំស្តីពីការប្រើប្រាស់កម្មវិធីប្រជុំ Zoom ជាដើម។

អគ្គនាយកដ្ឋានបានប្រើប្រាស់វិធីសាស្រ្តចំនួន ៣ ដើម្បីផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ ឬធ្វើការជូនដំណឹងស្តីពីការបម្រើសេវាសាធារណៈផ្សេងៗដូចខាងក្រោម៖

- ទំព័រហ្វេសប៊ុកផេក (Facebook Page) របស់អគ្គនាយកដ្ឋានពន្ធនាគារ
- ការបោះពុម្ពព្រឹត្តិប័ត្រព័ត៌មានប្រចាំឆ្នាំ
- បោះពុម្ពប្រតិទិនប្រចាំឆ្នាំ

អគ្គនាយកដ្ឋានបានអនុវត្តវិធីសាស្ត្រចំនួន ៥ លើការងារអង្កេតតាមដាន និងឆ្លើយតបមតិមហាជន ព្រមទាំងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងអង្គភាពលើបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានាដូចជា៖

- តាមរយៈអ្នកនាំពាក្យរបស់អគ្គនាយកដ្ឋានពន្ធនាគារ
- ទំព័រហ្វេសប៊ុកផេក (Facebook Page) អគ្គនាយកដ្ឋានពន្ធនាគារ
- ប្រអប់សារទំព័រហ្វេសប៊ុកផេក (Facebook Page Messenger)
- ប្រព័ន្ធទូរស័ព្ទ
- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា។

**៩.ក្រុមប្រឹក្សានីតិកម្ម** ពុំមានផែនការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញបច្ចេកវិទ្យាព័ត៌មាន (អភិវឌ្ឍកម្មវិធីសូហ្វវែរ ឌីហ្សាញ បណ្តាញណេតវើក។ល។) និងសកម្មភាព ឬផែនការពាក់ព័ន្ធនឹងការផ្សព្វផ្សាយអប់រំ (Awareness) សម្រាប់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅឡើយទេ។

ក្រុមប្រឹក្សានីតិកម្ម ពុំមានប្រើប្រាស់វិធីសាស្ត្រដើម្បីផ្សព្វផ្សាយអំពីសកម្មការងាររបស់ថ្នាក់ដឹកនាំ ឬធ្វើការជូនដំណឹងស្តីពីការផ្តល់សេវាសាធារណៈផ្សេងៗទេ ប៉ុន្តែបានបង្កើតក្រុមការងារដើម្បីធ្វើការអង្កេត តាមដាន និងឆ្លើយតបមតិមហាជនអំពីបញ្ហាផ្សេងៗតាមបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក Facebook Page (ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សានីតិកម្ម)។

**១០.អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង** មានផែនការបណ្តុះបណ្តាលធនធានមនុស្សដូចជា មន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិចំនួន ២០រូប កំពុងសិក្សាជំនាញព័ត៌មានវិទ្យា និងឌីហ្សាញ ប៉ុន្តែពុំមានសកម្មភាព ឬផែនការពាក់ព័ន្ធនឹងការផ្សព្វផ្សាយអប់រំ (Awareness) ឬសម្រាប់ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងអង្គភាពនៅឡើយទេ។

អគ្គនាយកដ្ឋានប្រើប្រាស់វិធីសាស្ត្រចំនួន ២ ដើម្បីធ្វើការផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ ឬធ្វើការជូនដំណឹងស្តីពីការផ្តល់សេវាសាធារណៈផ្សេងៗដូចខាងក្រោម៖

- ទំព័រហ្វេសបុកផ្លូវការរបស់អគ្គនាយកដ្ឋានអាស័យដ្ឋាន https://www.facebook.com/GeneralDepartmentofInternalAudit
- គ្រុបតេឡេក្រាម (Telegram group)

អគ្គនាយកដ្ឋានបានអនុវត្តវិធីសាស្ត្រចំនួន ៤ លើការងារអង្កេតតាមដាន និងឆ្លើយតបមតិមហាជន ព្រមទាំងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងអង្គភាព លើទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានាដូចជា៖

- ប្រើប្រាស់យន្តការអ្នកនាំពាក្យ
- ទំព័រហ្វេសបុកផ្លូវការរបស់អគ្គនាយកដ្ឋាន
- បង្កើតក្រុមការងារប្រមូល និងវិភាគព័ត៌មាន
- រៀបចំប្រអប់សំបុត្រទទួលព័ត៌មាននៅតាមសវនដ្ឋាន។

**១១.អគ្គាធិការដ្ឋាន** ពុំមានផែនការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញបច្ចេកវិទ្យាព័ត៌មាន (អភិវឌ្ឍ កម្មវិធីសូហ្វវែរ ឌីហ្សាញ បណ្តាញណេតវើក។ល។) នៅឡើយទេ ប៉ុន្តែបានធ្វើការផ្សព្វផ្សាយអប់រំ និងជូនដំណឹងស្តីពីការផ្តល់សេវាសាធារណៈតាមបណ្តាញទំនាក់ទំនងសង្គម ទំព័រហ្វេសប៊ុកផេក (Facebook Page) អគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ (Link:http://www.facebook.com/ អគ្គាធិការដ្ឋាន-ក្រសួងមហាផ្ទៃ -1783628671752862)

អគ្គាធិការដ្ឋានបានអនុវត្តវិធីសាស្ត្រចំនួន ១ លើការងារអង្កេតតាមដាន និងឆ្លើយតបមតិមហាជន ព្រមទាំងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងអង្គភាព លើបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានា គឺចាត់តាំងមន្ត្រីធ្វើសម្រង់រាល់បាតុភាពផ្សេងៗតាមបណ្តាញទំនាក់ទំនងសង្គម និងសារព័ត៌មាននានា។

**១២.សាលាជាតិរដ្ឋបាលមូលដ្ឋាន** មានរៀបចំការបណ្តុះបណ្តាលជំនាញព័ត៌មានវិទ្យាសម្រាប់ក្រុមគោលដៅជាមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិលើប្រធានបទដូចខាងក្រោម៖

- ព័ត៌មានវិទ្យាសម្រាប់ការិយាល័យ (Ms. Word, Excel និងMs. PowerPoint)
- ការប្រើប្រាស់កម្មវិធី/ប្រព័ន្ធទំនាក់ទំនង និងកិច្ចប្រជុំ (Telegram, ZOOM, Microsoft Teams, )

បន្ថែមពីលើការបណ្តុះបណ្តាលផ្ទាល់នៅក្នុងថ្នាក់ សាលាជាតិរដ្ឋបាលមូលដ្ឋានក៏បាននឹងកំពុងបញ្ជ្រាបយ៉ាងសកម្មនូវការបណ្តុះបណ្តាលពីចម្ងាយតាមប្រព័ន្ធអនឡាញ។

កិច្ចការងារផ្សព្វផ្សាយអប់រំ សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននឹងកំពុងប្រើប្រាស់វិធីសាស្ត្រចំនួន ៤ ដូចខាងក្រោម៖

- គេហទំព័រផ្លូវការរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (www.nasla.interior.gov.kh)
- ហ្វេសប៊ុកផេក(Facebook Page) ឈ្មោះ **សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ**
- តេលេក្រាម ឆានែល(Telegram Channel) ឈ្មោះ **សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ**
- ការបោះពុម្ពផ្សាយព្រឹត្តិបត្រវិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងមហាផ្ទៃ។

### ២.៣. កិច្ចការងារផ្តល់សេវាសាធារណៈ

ក្នុងនាមជាសេនាធិការជូនរាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃមានតួនាទីគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ជាន់ថ្នាក់ កងកម្លាំងនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ដែលមានភារកិច្ចថែរក្សាសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម និងសន្តិសុខជាតិ។ បន្ថែមពីលើនេះក្រសួងមហាផ្ទៃ ក៏ជាអាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីផ្តល់សេវាកម្មពាក់ព័ន្ធជាច្រើនជូនមន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារ និងមន្ត្រីរាជការស៊ីវិលចំណុះក្រសួងមហាផ្ទៃផងដែរ ជាពិសេសការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋទូទៅដោយផ្ទាល់ ក្នុងនោះតាមរយៈយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានប្រហែល ១,២០០សេវា ដែលស្ថិតក្រោមសមត្ថកិច្ចផ្តល់ការគាំទ្រដោយក្រសួងមហាផ្ទៃ។ ទន្ទឹមគ្នានោះស្ទើរតែគ្រប់សេវាកម្មផ្តល់ដោយក្រសួងមហាផ្ទៃ នៅបន្តអនុវត្ត

តាមបែបប្រពៃណី មិនទាន់បានធ្វើទំនើបកម្មទៅជាប្រព័ន្ធឌីជីថលពេញលេញនៅឡើយ ទោះបីជាមានអង្គភាពក្រោមចំណុះមួយចំនួនតូច ជាពិសេសអង្គភាពដែលមានសមត្ថកិច្ចផ្ដល់សេវាសាធារណៈផ្ទាល់បានខិតខំធ្វើការអភិវឌ្ឍ និងធ្វើទំនើបកម្មសេវារបស់ខ្លួនទៅជាឌីជីថលម្ដងមួយជំហានហើយក៏ដោយ ក៏សង្កេតឃើញថាដំណើរផ្លូវឆ្ពោះទៅរកការផ្ដល់សេវាសាធារណៈឌីជីថលពេញលេញហាក់បីដូចជានៅវែងឆ្ងាយ ដែលឧបសគ្គទាំងនោះរួមមានដូចជា ធនធានមនុស្សឌីជីថលនៅមានកម្រិតតិចតួច ពុំមានថវិកាសម្រាប់អនុវត្តគម្រោង ឬពង្រីកវិសាលភាពប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា រួមផ្សំទាំងការចូលរួមពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងចំណេះដឹងអំពីប្រព័ន្ធបច្ចេកវិទ្យាឌីជីថលរបស់ប្រជាពលរដ្ឋ ដែលជាអ្នកទទួលប្រើប្រាស់សេវាកម្មផ្ទាល់នៅមានកម្រិតនៅឡើយ។

អង្គភាពមានសមត្ថកិច្ចផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ មានដូចខាងក្រោម៖

**១.អគ្គស្នងការដ្ឋាននគរបាលជាតិ** មានផ្ដល់សេវាកម្មដូចខាងក្រោម៖

- ប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ១១៧ (Hot Line) សម្រាប់ឱ្យប្រជាពលរដ្ឋរាយការណ៍ ឬប្ដឹងអំពីហេតុការណ៍ ឬបទល្មើសអ្វីមួយដែលបានកើតឡើង
- កំពុងរៀបចំកសាងប្រព័ន្ធ Mobile Application សម្រាប់ផ្ដល់ទំនាក់ទំនងកិច្ចអន្តរាគមន៍របស់នគរបាលជូនប្រជាពលរដ្ឋ ដែលមានឈ្មោះថា E-Police តាមប្រព័ន្ធទូរស័ព្ទស្មាតហ្វូន។

**២. អគ្គនាយកដ្ឋានរដ្ឋបាល** មានផ្ដល់សេវាកម្មដូចខាងក្រោម៖

- ចុះបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ និងសហគមន៍ជនជាតិដើមភាគតិច។

**៣.អគ្គនាយកដ្ឋានអន្តោប្រវេសន៍** មានផ្ដល់សេវាកម្មដូចខាងក្រោម៖

- លំហូរសេវាកម្មឌីជីថល ដែលអង្គភាពបានអនុវត្តគឺការបង្កើតប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា (FPCS) ដែលមានគោលបំណងសម្រាប់បម្រើដល់ការងារគ្រប់គ្រងវត្តមានជនបរទេសនៅតាមបណ្ដារាជធានី/ខេត្ត ជួយសម្រួលដល់ការបំពេញការងាររបស់មន្ត្រីមានសមត្ថកិច្ច និងពលរដ្ឋដូចជា៖
  - មន្ត្រីមានសមត្ថកិច្ច ធ្វើការកត់ត្រា ស្រាវជ្រាវ និងបម្រើដល់កិច្ចការជំនាញជាច្រើនទៀត
  - ប្រជាពលរដ្ឋ ជាពិសេសម្ចាស់ ឬអ្នកកាន់កាប់លំនៅដ្ឋាន និងទីតាំងអាជីវកម្ម អាចប្រើប្រាស់ប្រព័ន្ធនេះដើម្បីចុះវត្តមានជនបរទេសស្នាក់នៅទីតាំងរបស់ខ្លួន ដែលព័ត៌មានទាំងនេះត្រូវបានប្រើប្រាស់ក្នុងគោលបំណងរក្សាសន្តិសុខ និងបង្កភាពងាយស្រួលដល់ជនបរទេសពេលមកស្នើសុំបន្តទិដ្ឋាការស្នាក់នៅបណ្ដោះអាសន្ន។
- កន្លងមកការអនុវត្តលំហូរសេវាកម្មបែបប្រពៃណីដែលអគ្គនាយកដ្ឋានធ្លាប់បានអនុវត្តមានដូចជា៖
  - ការស្នើសុំបញ្ជាក់ភាពត្រឹមត្រូវរបស់ជនបរទេស
  - ការស្នើសុំដាក់ពាក្យជាជនបរទេសអន្តោប្រវេសន៍

- ការស្នើសុំទិដ្ឋាការនៅពេលមកដល់ (Visa on Arrival) គឺប្រព្រឹត្តទៅនៅពេលអ្នកដំណើរជាជនបរទេស បានមកដល់ប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ ត្រូវបំពេញបែបបទស្នើសុំដោយផ្ទាល់នៅទីនោះ និងត្រូវបំពេញសាលាកបត្រអន្តោប្រវេសន៍ (Immigration Card)។

- ដំណើរអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាតាមផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖
  - នីតិវិធីនៃការស្នើសុំទិដ្ឋាការពេលមកដល់ ត្រូវបានអគ្គនាយកដ្ឋានរៀបចំជាប្រព័ន្ធបច្ចេកវិទ្យា និងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការមានឈ្មោះថា ប្រព័ន្ធផ្តល់ទិដ្ឋាការពេលមកដល់ (Visa on Arrival System) ហៅកាត់ VoA ដោយគ្រាន់តែយកលិខិតឆ្លងដែនជនបរទេសមកធ្វើការស្កេនទាញយកទិន្នន័យសម្រាប់ធ្វើការបោះពុម្ពលើសន្លឹកទិដ្ឋាការស្អិត រួចបិតនៅលើសន្លឹកលិខិតឆ្លងដែន គឺជាការស្រេច។
  - សាលាកបត្រអន្តោប្រវេសន៍ (Immigration Card) ត្រូវបានអគ្គនាយកដ្ឋានកំពុងរៀបចំជាប្រព័ន្ធបច្ចេកវិទ្យាសាលាកបត្រចូលកម្ពុជា (Cambodia Arrival Card System) ហៅកាត់ CAM Arrival Card ដោយរួមបញ្ចូលព័ត៌មានសុខភាព ការប្រកាសពន្ធគយ និងព័ត៌មានពាក់ព័ន្ធនឹងបុគ្គលអ្នកដំណើរចូលមកក្នុងប្រទេសកម្ពុជា។

**៤.អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** ជាអង្គភាពផ្តល់សេវាកម្មផ្ទាល់ជាមួយប្រជាពលរដ្ឋជាច្រើន រួមមានដូចខាងក្រោម៖

- ផ្ទៀងផ្ទាត់គល់បញ្ជីអត្រានុកូលដ្ឋានដូចជា៖
  - ចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន
  - កែតម្រូវបញ្ជីអត្រានុកូលដ្ឋាន
  - ទទួល រៀបចំ និងលើកយោបល់សម្រាប់អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។
- ការស្នើសុំចូលសញ្ជាតិខ្មែរ ទាមទារសញ្ជាតិខ្មែរ លះបង់សញ្ជាតិខ្មែរ និងតាមដានស្រាវជ្រាវការចូលសញ្ជាតិខ្មែរ និងលះបង់សញ្ជាតិខ្មែរតាមការស្នើសុំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សេវាផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- សេវាផ្តល់សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ លិខិតស្នាក់នៅបណ្តោះអាសន្ន និងផ្លាស់ប្តូរទីលំនៅ
- សេវាផ្តល់លិខិតឆ្លងដែនធម្មតាអេឡិចត្រូនិកសម្រាប់ប្រជាពលរដ្ឋ និងមន្ត្រីរាជការធ្វើដំណើរទៅក្រៅប្រទេស និងលិខិតធ្វើដំណើររបស់ពលករកម្ពុជាធ្វើការនៅបរទេស សម្រាប់ពលករកម្ពុជាដែលបម្រើការងារនៅក្រៅប្រទេស។

**៥.អគ្គនាយកដ្ឋានពន្ធនាគារ** មានផ្តល់សេវាកម្មដូចខាងក្រោម៖

- សេវាជួបសួរសុខទុក្ខជនជាប់ឃុំ (ជួបផ្ទាល់ និងជួបតាមទូរស័ព្ទ)
- សេវាផ្ញើសំបុត្រ

- សេវាផ្ញើសម្ភារប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគ
- សេវាសុខាភិបាល
- សេវាសន្តិសុខសុវត្ថិភាព
- សេវាអប់រំកែប្រែស្តារនីតិសម្បទា
- សេវាបណ្តុះបណ្តាលវិជ្ជាជីវៈ
- សេវាផ្តល់ព័ត៌មាន
- សេវាឱ្យជនជាប់ឃុំជួបមេធាវី
- សេវាដឹកជញ្ជូនជនជាប់ឃុំទៅសវនាការ
- ផ្តល់កិច្ចសហការផ្លាស់ប្តូរព័ត៌មានជាមួយកងកម្លាំង និងអាជ្ញាធរពាក់ព័ន្ធនានា។

**៦.អគ្គាធិការដ្ឋាន** មានផ្តល់សេវាកម្មដូចខាងក្រោម៖

- ធ្វើអធិការកិច្ច ត្រួតពិនិត្យសកម្មភាពការងារ និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ លើការអនុវត្តច្បាប់ លិខិតបទដ្ឋាន កម្មវិធីនយោបាយនានារបស់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ
- ទទួលពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហារ ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការរបស់មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាល មន្ត្រីពន្ធនាគារ ក្នុងដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ។

# ជំពូកទី៣

## យុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល ក្រសួងមហាផ្ទៃ

ក្រោមបន្ទាត់នៃគោលនយោបាយថ្នាក់ជាតិស្តីពីបច្ចេកវិទ្យាឌីជីថលកម្ពុជា២០២២-២០៣៥ ក៏ដូចជាលទ្ធផលនៃការធ្វើសម្រង់បច្ចុប្បន្នភាពប្រព័ន្ធបច្ចេកវិទ្យានៅតាមបណ្តាអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃកន្លងមក យើងអាចធ្វើការកំណត់អំពីចំណុចខ្លាំង ចំណុចខ្សោយ និងឱកាសក្នុងការកែលម្អ ព្រមទាំងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីជួយគ្រប់គ្រង និងសម្រួលដល់លំហូរកិច្ចការងារផ្សេងៗ ជាពិសេសការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ ដូចនេះ ការរៀបចំផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល ក្រសួងមហាផ្ទៃ ២០២៣-២០២៧ បានផ្តោតសំខាន់ទៅលើយុទ្ធសាស្ត្រគោលធំៗចំនួន ៦ ដូចខាងក្រោម៖

**១-យុទ្ធសាស្ត្របណ្តុះបណ្តាលធនធានមនុស្ស និងបញ្ជ្រាបចំណេះដឹង**

**២-យុទ្ធសាស្ត្រកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ក្រសួងមហាផ្ទៃ**

**៣-យុទ្ធសាស្ត្រពង្រឹងសន្តិសុខ និងទប់ស្កាត់បទល្មើសបច្ចេកវិទ្យា (Cyber Security and Cybercrime)**

**៤-យុទ្ធសាស្ត្រស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យា**

**៥-យុទ្ធសាស្ត្រពង្រឹងគុណភាពការងារ និងការផ្តល់សេវាសាធារណៈ**

**៦-យុទ្ធសាស្ត្រអភិបាលកិច្ចបច្ចេកវិទ្យា**

### ៣.១. យុទ្ធសាស្ត្របណ្តុះបណ្តាលធនធានមនុស្ស និងបញ្ជ្រាបចំណេះដឹង

ក្នុងដំណើរអនុវត្តឆ្ពោះទៅសម្រេចបាននូវផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពគាំទ្រទាំងឡាយកិច្ចការងារបណ្តុះបណ្តាលធនធានមនុស្ស និងបញ្ជ្រាបចំណេះដឹងផ្នែកបច្ចេកវិទ្យាឌីជីថលត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងធនធានមនុស្សឱ្យមានចំណេះជំនាញ និងមានសមត្ថភាពពិតប្រាកដក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលកម្រិតខ្ពស់ ដើម្បីគាំទ្រផែនការនានាដែលត្រូវបានដាក់ចេញក្នុងក្របខណ្ឌក្រសួងមហាផ្ទៃព្រមទាំងបានចូលរួមគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការឈានទៅសម្រេចបានគោលដៅកំណើនសេដ្ឋកិច្ច ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដូចនេះ កិច្ចការងារបណ្តុះបណ្តាល គឺជាកត្តាមិនអាចខ្វះបានក្នុងការអភិវឌ្ឍកម្លាំងស្នូលឱ្យពោរពេញទៅដោយចំណេះដឹង ចំណេះធ្វើ ជំនាញបច្ចេកទេស និងសមត្ថភាពពិតប្រាកដ ដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាឌីជីថលនានារបស់ក្រសួងមហាផ្ទៃ ក្នុងការចូលរួមក្នុងគន្លងថ្មីនៃយុគសម័យរដ្ឋាភិបាលឌីជីថល ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល។

## ៣.១.១. យន្តការពង្រឹងប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាល និងកសាងធនធានមនុស្ស

មើលឃើញអំពីសារៈសំខាន់នៃកិច្ចការងារបណ្តុះបណ្តាលកសាងធនធានមនុស្សជំនាញបច្ចេកវិទ្យាឌីជីថល និងដើម្បីសម្រេចបាននូវចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ចាំបាច់តម្រូវឱ្យមានការអភិវឌ្ឍជាប្រចាំបន្ថែមទៀតលើការពង្រឹងគុណភាពអប់រំបណ្តុះបណ្តាល ឆ្លើយតបតម្រូវការជាក់ស្តែងស្របតាមបរិបទសេដ្ឋកិច្ច និងសង្គមឌីជីថល ក្រសួងមហាផ្ទៃបានកំណត់យកយន្តការបណ្តុះបណ្តាលអាទិភាពចំនួន ៥ រួមមានដូចខាងក្រោម៖




**រូបភាពទី៣៖ យន្តការបណ្តុះបណ្តាលពង្រឹងប្រសិទ្ធភាពក្នុងការកសាងធនធានមនុស្សផ្នែកបច្ចេកវិទ្យា**

### ៣.១.១.១. យន្តការពង្រឹង និងកសាងធនធានមនុស្សផ្នែកបច្ចេកវិទ្យា

សំដៅលើកកម្ពស់ការយល់ដឹង ក្នុងការអនុវត្តស្តង់ដារគុណភាពបណ្តុះបណ្តាលជំនាញទាក់ទងនឹងការអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យា ការបណ្តុះបណ្តាលនិងអភិវឌ្ឍធនធានមនុស្សជាមូលដ្ឋានយុទ្ធសាស្ត្រនៃការពង្រឹងគុណភាព និងប្រសិទ្ធភាពការងាររដ្ឋបាល ការងារជំនាញ និងការផ្តល់សេវាសាធារណៈ។

**ក- <u>កិច្ចការងារបណ្តុះបណ្តាលតាមអង្គភាពជំនាញ៖</u>** សំដៅដល់ការស្រាវជ្រាវ និងរៀបចំវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពលើកិច្ចការងាររដ្ឋបាល កិច្ចការងារជំនាញ និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ។ ដើម្បីគាំទ្រនូវយន្តការខាងលើ សម្រាប់កិច្ចការងារបណ្តុះបណ្តាលតាមបណ្តាអង្គភាពជំនាញ ក្រសួងមហាផ្ទៃ បានដាក់ចេញនូវសកម្មភាពស្នូលចំនួន ១១ ដូចខាងក្រោម៖

- កសាងមូលធនមនុស្ស ផ្តោតលើការអប់រំ និងការបណ្តុះបណ្តាលពហុជំនាញ ព្រមទាំងការបណ្តុះនូវអ្នកមានទេពកោសល្យក្នុងការអភិវឌ្ឍ នវានុវត្តន៍ និងបច្ចេកវិទ្យាថ្មីៗឆ្លើយតបទៅនឹងតម្រូវការរបស់អង្គភាពក្នុងពេលបច្ចុប្បន្ន និងអនាគត

- អភិវឌ្ឍធនធានមនុស្សតាមបណ្តាអង្គភាពជំនាញ ជំរុញការយកចិត្តទុកដាក់ ការទទួលយក និងការសម្របខ្លួនទៅនឹងការអភិវឌ្ឍនៃប្រព័ន្ធបច្ចេកវិទ្យាឌីជីថលដើម្បីកសាងប្រព័ន្ធគ្រប់គ្រងថ្មី និងដើរតួជាចលករតភ្ជាប់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលរបស់អង្គភាពខ្លួន ជាមួយបណ្តាអង្គភាពនានាចំណុះក្រសួងមហាផ្ទៃ ក៏ដូចជាក្រសួង ស្ថាប័ន និងអង្គភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដទៃផ្សេងទៀត
- បង្កើនឱកាស និងលទ្ធភាពជូនដល់មន្ត្រីជំនាញតាមបណ្តាអង្គភាពនានា ដើម្បីទទួលបានការអប់រំបណ្តុះបណ្តាលលើជំនាញបច្ចេកវិទ្យាឌីជីថលប្រកបដោយសមធម៌
- ពង្រឹងប្រសិទ្ធភាព និងខ្លឹមសារនៃផែនការបណ្តុះបណ្តាលធនធានមនុស្សវិស័យបច្ចេកវិទ្យាឌីជីថលដល់មន្ត្រីនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធធនាគារ នៅតាមបណ្តាអង្គភាពចំណុះក្រសួង
- កសាងមន្ត្រីជំនាញនៅតាមបណ្តាអង្គភាពនានាចំណុះក្រសួង ឱ្យក្លាយទៅជាគ្រូបង្គោលដើម្បីចូលរួមបណ្តុះបណ្តាល ចែករំលែក និងលើកទឹកចិត្តក្នុងការកសាងចំណេះជំនាញផ្នែកបច្ចេកវិទ្យាឌីជីថល
- លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងជំរុញការចូលរួមពីមន្ត្រីគ្រប់ជាន់ថ្នាក់ ដោយប្រើប្រាស់គោលការណ៍លើកទឹកចិត្តបែបសមធម៌និងវិន័យ ដើម្បីពង្រឹងគុណភាពអប់រំ
- ផ្តល់ឱកាស សម្ភារឧទ្ទេស និងពេលវេលាពេញលេញដល់សិក្ខាកាមអំឡុងពេលបណ្តុះបណ្តាល
- បង្កើតបទដ្ឋានវាស់វែងកម្រិតសមត្ថភាពជំនាញបច្ចេកទេស និងគោលនយោបាយគ្រប់គ្រង កៀរគរ និងលើកទឹកចិត្តមូលធនមនុស្ស ដែលមានជំនាញបច្ចេកវិទ្យាឌីជីថលក្របខណ្ឌក្រសួងមហាផ្ទៃ
- ជំរុញការបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាឌីជីថលសំខាន់ៗជាអាទិ៍ ទូរគមនាគមន៍និងបណ្តាញ ការអភិវឌ្ឍសូហ្វវែរ បញ្ញាសិប្បនិម្មិត(AI) វិទ្យាសាស្ត្រទិន្នន័យ និម្មាបនកម្មប្រព័ន្ធព័ត៌មាន និងសន្តិសុខឌីជីថល
- ជំរុញការបណ្តុះបណ្តាលជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំឌីជីថល ជូនមន្ត្រីជំនាញ និងថ្នាក់ដឹកនាំនៃបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ
- ពិនិត្យ តាមដាន វាយតម្លៃគុណភាពមន្ត្រីជំនាញ ដើម្បីធានាបាននូវធនធានមនុស្សបំពេញតម្រូវការបច្ចេកវិទ្យាឌីជីថលសមស្របនឹងគោលនយោបាយរដ្ឋាភិបាលឌីជីថល។

ខ- <u>កិច្ចការងារបណ្តុះបណ្តាលថ្នាក់កណ្តាល៖</u> បន្ថែមលើសកម្មភាពបណ្តុះបណ្តាលតាមបណ្តាអង្គភាពជំនាញ កិច្ចការងារបណ្តុះបណ្តាលធនធានមនុស្សនៅថ្នាក់កណ្តាល គឺជាបេសកកម្មដ៏មានសារៈសំខាន់ដើម្បីធានាបាននូវការទទួលយកចំណេះដឹង និងចំណេះជំនាញសមស្របតាមគោលការណ៍ និងផែនការដែលបានដាក់ចេញដោយក្រសួងមហាផ្ទៃ ក៏ដូចជាធានាបាននូវការអនុវត្តផែនការសកម្មភាពនានាគាំទ្រដល់គោលនយោបាយរដ្ឋាភិបាលឌីជីថល។ សម្រាប់កិច្ចការងារបណ្តុះបណ្តាលថ្នាក់កណ្តាល ក្រសួងបានដាក់ចេញនូវសកម្មភាពស្នូលចំនួន ៧ ដូចខាងក្រោម៖

- បណ្តុះបណ្តាលលើជំនាញទន់ (Soft skill) និងជំនាញឯកទេស (Hard skill) សមស្របតាមតម្រូវការនៃគោលនយោបាយរដ្ឋាភិបាលឌីជីថល

- ជំរុញការបណ្តុះបណ្តាលមន្ត្រីបម្រើការងារឱ្យមានសមត្ថភាពពេញលេញ មានចំណេះដឹងទូលំទូលាយ មានជំនាញច្បាស់លាស់ អត្តចរិតល្អ និងបន្តការអភិវឌ្ឍចំណេះជំនាញឱ្យស្របនឹងបរិបទបច្ចេកវិទ្យា
- បង្កើត ស្រាវជ្រាវ និងផ្សព្វផ្សាយនូវឯកសារជំនួយស្មារតីអំពីបច្ចេកវិទ្យាថ្មីៗ ក៏ដូចជាបទបង្ហាញអំពីបញ្ហាផ្សេងៗក្នុងមជ្ឈដ្ឋានបច្ចេកវិទ្យា កសាងភាពជាដៃគូរដើម្បីអភិវឌ្ឍធនធានមនុស្សសំដៅធ្វើឱ្យមន្ត្រីជំនាញមានសមត្ថភាពខ្ពស់ឆ្លើយតបទៅនឹងតម្រូវការរបស់អង្គភាព និងស្របតាមស្តង់ដាអប់រំ
- ពង្រឹងការងាររដ្ឋបាល អភិបាលកិច្ចបច្ចេកវិទ្យា ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលបម្រើវិស័យសន្តិសុខ រដ្ឋបាល និងសេវាសាធារណៈ
- ពង្រឹង និងពង្រីកស្ថាប័នបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាឌីជីថល ក្របខណ្ឌក្រសួងមហាផ្ទៃ
- លើកទឹកចិត្តធនធានមនុស្សមានទេពកោសល្យឌីជីថល ក្នុងការចូលរួម និងដើរជាតួអង្គដ៏សំខាន់នៅក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថល ការដោះស្រាយបញ្ហាបានឆាប់រហ័សនៅក្នុងប្រព័ន្ធបច្ចេកវិទ្យា និងការការពារសុវត្ថិភាពនៃប្រព័ន្ធទាំងមូល
- ពិនិត្យ តាមដាន និងវាយតម្លៃគុណភាពមន្ត្រីជំនាញ ដើម្បីធានាបាននូវធនធានមនុស្សសម្រាប់បំពេញតម្រូវការបច្ចេកវិទ្យា សមស្របនឹងគោលនយោបាយរដ្ឋាភិបាលឌីជីថល។

គ- <u>កិច្ចការងារបណ្តុះបណ្តាលថ្នាក់ក្រោមជាតិ៖</u> សំដៅដល់ការស្រាវជ្រាវ និងរៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពលើកិច្ចការងាររដ្ឋបាល កិច្ចការងារជំនាញ និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈជូនមន្ត្រីនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធធនាគារ ពីគ្រប់រដ្ឋបាលរាជធានី/ខេត្ត និងស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត។ ចំពោះកិច្ចការងារបណ្តុះបណ្តាលថ្នាក់ក្រោមជាតិ ក្រសួងបានដាក់ចេញនូវសកម្មភាពស្នូលចំនួន ៥ ដូចខាងក្រោម៖

- អនុវត្តស្តង់ដាបណ្តុះបណ្តាលសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍជំនាញបច្ចេកវិទ្យា ដើម្បីបង្កើនប្រសិទ្ធភាពកិច្ចការងាររដ្ឋបាល និងកិច្ចការងារជំនាញ ព្រមទាំងធ្វើការចែករំលែកចំណេះជំនាញបច្ចេកវិទ្យាជូនដល់មន្ត្រីថ្នាក់ក្រោមជាតិ
- ចែករំលែកកម្មវិធីបច្ចេកវិទ្យា និងបណ្តុះបណ្តាលសមត្ថភាពប្រើប្រាស់ ដើម្បីបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងការងារជំនាញជូនដល់មន្ត្រីថ្នាក់ក្រោមជាតិ
- រៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីជំនាញ យ៉ាងហោចណាស់ត្រូវមានមន្ត្រីចំនួន ១រូប ចេះថែទាំ និងជួសជុលគ្រឿងអេឡិចត្រូនិកក្នុងអង្គភាពរបស់ខ្លួន
- ជំរុញការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលជូនដល់មន្ត្រីនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ពីគ្រប់រដ្ឋបាលរាជធានី/ខេត្ត និងស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត
- ពិនិត្យ តាមដាន និងវាយតម្លៃគុណភាពមន្ត្រីជំនាញ ដើម្បីធានាបាននូវធនធានមនុស្សបំពេញគ្រប់តម្រូវការបច្ចេកវិទ្យាសមស្របនឹងគោលនយោបាយរដ្ឋាភិបាលឌីជីថល។

### ៣.១.១.២. យន្តការផ្តល់លទ្ធភាពគាំទ្រសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍមន្ត្រីជំនាញ និងគ្រូបង្គោល

បន្តគាំទ្រ និងបណ្តុះបណ្តាលមន្ត្រីជំនាញ និងគ្រូបង្គោល លើកិច្ចការងារស្រាវជ្រាវផ្នែកបច្ចេកវិទ្យាដែលកំពុងរីកចម្រើន និងធ្វើការទំនាក់ទំនងជាមួយមជ្ឈដ្ឋានជុំវិញ ឬដៃគូរអភិវឌ្ឍជាយុទ្ធសាស្ត្របម្រើដល់សមត្ថភាពស្រាវជ្រាវ និងទំនាក់ទំនងជាមួយគ្រូបង្គោល អ្នកជំនាញ ឬទីប្រឹក្សាបច្ចេកទេសទាំងក្នុង និងក្រៅប្រទេសដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ ទទួលបានការបណ្តុះបណ្តាល និងធ្វើបច្ចុប្បន្នភាពរាល់ចំណុចខ្វះខាតនានា។ ដើម្បីគាំទ្រយន្តការខាងលើ ក៏ដូចជាផ្តល់លទ្ធភាពគាំទ្រដល់សកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍជូនដល់មន្ត្រីជំនាញ និងគ្រូបង្គោល ក្រសួងបានដាក់ចេញនូវសកម្មភាពស្នូលចំនួន ៦ ដូចខាងក្រោម៖

- បណ្តុះបណ្តាល និងពង្រឹងទំនាក់ទំនងរវាងស្ថាប័នចំណុះក្រសួងមហាផ្ទៃ ដោយប្រើប្រាស់យន្តការដែលមានស្រាប់ដើម្បីបង្កើនការផ្សព្វផ្សាយ បណ្តុះបណ្តាល និងចែករំលែកព័ត៌មានឱ្យបានទូលំទូលាយ
- បង្កើតយន្តការស្ទង់មតិមន្ត្រីជំនាញឱ្យបានទៀងទាត់ ដើម្បីធ្វើការសិក្សាស្វែងរកចំណុះខ្វះខាត និងបង្កើនភាពជាដៃគូជាមួយអង្គភាពចំណុះក្រសួងមហាផ្ទៃ និងវិស័យឯកជន ដើម្បីស្វែងយល់អំពីបច្ចេកទេសស្រាវជ្រាវ និងចំណេះដឹងថ្មីៗ ព្រមទាំងធ្វើបច្ចុប្បន្នភាពចំណេះជំនាញគ្រូបង្គោលឱ្យទាន់បរិបទសង្គមបច្ចេកវិទ្យា
- ជម្រុញសកម្មភាពសិក្សាស្រាវជ្រាវ ជូនដល់អង្គភាពចំណុះក្រសួងមហាផ្ទៃ ដើម្បីបង្កើនប្រសិទ្ធភាពការងារ ចំណេះជំនាញ និងការផ្តល់សេវាសាធារណៈ
- បង្កើតទស្សនកិច្ចសិក្សាឱ្យបានទៀងទាត់ជាត្រីមាស ឬ ៣ខែម្តង ដើម្បីធ្វើបច្ចុប្បន្នភាពចំណេះដឹងគ្រូបង្គោល និងបណ្តុះបណ្តាលបំពេញបន្ថែម
- ជំរុញការកសាងប្រព័ន្ធសិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ក្របខណ្ឌក្រសួងមហាផ្ទៃ
- ជំរុញការបណ្តុះបណ្តាលផ្ទេរបច្ចេកវិទ្យាឌីជីថល ដែលទទួលបានពីលទ្ធផលនៃការស្រាវជ្រាវដល់អង្គភាពចំណុះក្រសួងមហាផ្ទៃ ស្ថាប័នរាជរដ្ឋាភិបាល សម្រាប់វិស័យសាធារណៈ និងឯកជន។

### ៣.១.១.៣. យន្តការផ្តល់លទ្ធភាពសិក្សាពេញលេញដល់សិក្ខាកាមអំឡុងពេលបណ្តុះបណ្តាល

ដើម្បីអនុវត្តសម្រេចបានជោគជ័យនូវយុទ្ធសាស្ត្រ និងចក្ខុវិស័យដូចបានកំណត់ខាងលើ ទាមទារការផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល។ ដូចនេះ ដើម្បីគាំទ្រយន្តការខាងលើ ក្រសួងបានដាក់ចេញនូវសកម្មភាពស្នូលចំនួន ៣ ដូចខាងក្រោម៖

- អនុវត្តស្តង់ដារគុណភាពការបណ្តុះបណ្តាលជំនាញ ទាក់ទងនឹងការអភិវឌ្ឍជំនាញដោយដាក់ចេញនូវយុទ្ធនាការ "មន្ត្រីម្នាក់ ជំនាញមួយ"
- ផ្តល់ឱកាស និងពេលវេលាជាត្រីមាស ឬ ៣ខែម្តង ជូនដល់មន្ត្រីជំនាញដែលកំពុងបំពេញការងារអាចចូលរួមវគ្គបណ្តុះបណ្តាលដោយពេញលេញ និងពុំមានការរំខានអំឡុងពេលសិក្សា

- មន្ត្រីទាំងអស់ចាំបាច់ត្រូវចូលរួមវគ្គបច្ចេកវិទ្យាព័ត៌មានឱ្យបានគ្រប់ៗគ្នា ទោះបីជាការងារប្រចាំថ្ងៃរបស់ពួកគេមិនទាន់ទាក់ទងជាមួយនឹងបច្ចេកវិទ្យាព័ត៌មាននៅឡើយក្តី ព្រោះការងារបណ្តុះបណ្តាលត្រូវធ្វើក្នុងទម្រង់រូបភាពទាំងមូលនិងជារួម ដើម្បីឱ្យដំណើរការអនុវត្តផែនការមានភាពរលូន។

### ៣.១.១.៤. យន្តការរៀបចំផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយអប់រំសមស្របតាមតម្រូវការ

ដើម្បីឱ្យការរៀបចំផែនការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាព័ត៌មាន ស្របតាមតម្រូវការជាក់ស្តែងរបស់បណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ និងតម្រូវការនៃគោលនយោបាយរដ្ឋាភិបាលឌីជីថល ទាមទារឱ្យមានការសិក្សាស្រាវជ្រាវអំពីគោលនយោបាយពាក់ព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់ កំពុងអនុវត្ត និងគ្រោងដាក់ឱ្យប្រើប្រាស់។ ដូចនេះ ដើម្បីគាំទ្រយន្តការខាងលើ ក្រសួងបានដាក់ចេញនូវសកម្មភាពស្នូលចំនួន ៦ ដូចខាងក្រោមៈ

- ធ្វើការសហការរវាងអង្គភាពចំណុះក្រសួងមហាផ្ទៃ ដើម្បីសិក្សាស្រាវជ្រាវ និងដាក់ចេញនូវផែនការបណ្តុះបណ្តាលបច្ចេកវិទ្យាដែលសមស្របតាមតម្រូវការ និងបរិបទសង្គមបច្ចេកវិទ្យា ពិសេសស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថល
- រៀបចំផែនការបណ្តុះបណ្តាលផ្តោតលើការអភិវឌ្ឍចំណេះដឹង និងជំនាញឌីជីថលឱ្យមានលក្ខណៈស្របតាមគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល ដោយផ្តល់អាទិភាពលើមុខព្រួញដាក់លាក់ចំនួន ៣ គឺភាពជាអ្នកដឹកនាំឌីជីថល បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល និងពលរដ្ឋឌីជីថល ឱ្យជ្រៀតចូលដល់កម្រិតសហគមន៍មូលដ្ឋាន
- ធ្វើការស្វែងរកនូវដៃគូបច្ចេកទេស ដៃគូសហប្រតិបត្តិការ វិទ្យាស្ថានបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស ដើម្បីអនុវត្តផែនការបណ្តុះបណ្តាលឱ្យសម្រេចបានតាមការគ្រោងទុក
- ជំរុញការអភិវឌ្ឍខ្លឹមសារជាភាសាខ្មែរសម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធអប់រំ និងផ្តល់រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំជូនមន្ត្រីជំនាញ និងគ្រូបង្គោលដែលមានស្នាដៃឆ្នើម
- បង្កើតយន្តការក្នុងការប្រមូលព័ត៌មាន និងធ្វើការផ្សព្វផ្សាយអប់រំចំណេះដឹង ចំណេះជំនាញបច្ចេកវិទ្យាជូនដល់មន្ត្រីជំនាញ គ្រូបង្គោល តាមរយៈគេហទំព័រ កម្មវិធីបច្ចេកវិទ្យានានា និងទំព័រកម្មវិធីបណ្តាញទំនាក់ទំនងសង្គមជាដើម
- ធ្វើការផ្សព្វផ្សាយគោលនយោបាយ សកម្មភាពការងារ អត្ថបទអប់រំ តាមរយៈគេហទំព័រ ទំព័រកម្មវិធីបណ្តាញទំនាក់ទំនងសង្គម ដោយផ្តោតលើទស្សនទានបច្ចេកវិទ្យា ព្រមទាំងចំណេះដឹងឌីជីថលជូនសាធារណជនដើម្បីជំរុញការកសាងពលរដ្ឋឌីជីថល។

### ៣.១.១.៥. យន្តការបង្កើនកិច្ចសហការជាមួយដៃគូ និងគ្រឹះស្ថានអប់រំក្នុងបេសកកម្មបណ្តុះបណ្តាល

នៅក្នុងបេសកកម្មបណ្តុះបណ្តាល កិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធនានារួមមានស្ថាប័នរបស់រាជរដ្ឋាភិបាល វិស័យឯកជន ដៃគូជាតិនិងអន្តរជាតិ គឺជាកិច្ចការងារដ៏ចាំបាច់ក្នុងការកៀរគរជំនួយហិរញ្ញវត្ថុ

និងជំនួយបច្ចេកទេស បំពេញបន្ថែមលើការងារបណ្តុះបណ្តាលឱ្យសម្រេចបានតាមផែនការកំណត់។ ដូចនេះ ដើម្បីគាំទ្រចំពោះយន្តការខាងលើ ក្រសួងបានដាក់ចេញនូវសកម្មភាពស្នូលចំនួន ៤ ដូចខាងក្រោម៖

- កៀរគរប្រភពថវិកាសម្រាប់ទ្រទ្រង់ផែនការបណ្តុះបណ្តាលស្របតាមតម្រូវការកម្មវិធីបណ្តុះបណ្តាល
- សិក្សា និងពិនិត្យលទ្ធភាពក្នុងការរៀបចំអនុស្សារណៈយោគយល់គ្នារវាងគ្រឹះស្ថានអប់រំនិងគ្រូបង្គោល ព្រមទាំងរៀបចំផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយអប់រំ តាមតម្រូវការ និងផែនការយុទ្ធសាស្ត្រ
- លើកកម្ពស់កិច្ចសហការជាមួយគ្រឹះស្ថានជាតិ និងអន្តរជាតិ ដើម្បីជំរុញសន្ទុះអភិវឌ្ឍបច្ចេកវិទ្យា និងការអប់រំក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ
- រៀបចំដាក់ឱ្យដំណើរការក្រុមការងារបណ្តុះបណ្តាល និងគ្រូបង្គោលដោយផ្ទាល់នៅតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ។

### ៣.១.២. យន្តការពង្រឹងកិច្ចសហការដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាល

នៅក្នុងការអនុវត្តឱ្យទទួលបានជោគជ័យរបស់ផែនការយុទ្ធសាស្ត្រ ដែលមានគោលដៅច្បាស់លាស់ គោលបំណង និងចក្ខុវិស័យជាក់លាក់ ដូចបានកំណត់ខាងលើ យុទ្ធសាស្ត្របណ្តុះបណ្តាលបច្ចេកវិទ្យា បានដាក់ចេញនូវផែនការសកម្មភាពក្រោមទម្រង់ប្រមូលផ្តុំជាចង្កោមកម្មវិធីការងារអាទិភាព ដោយមានកំណត់នូវសូចនាករសម្រាប់វាស់វែង និងពេលវេលាសម្រាប់អនុវត្ត។ បន្ថែមពីលើនេះ ការប្រើប្រាស់យន្តការដែលមានស្រាប់និងការពង្រឹងប្រសិទ្ធភាពលើកិច្ចការងារបណ្តុះបណ្តាល ដោយពង្រីកកិច្ចសហការរវាងអង្គភាពចំណុះក្រសួងមហាផ្ទៃជាមួយបណ្តាដៃគូនានារួមមាន ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលដទៃផ្សេងទៀត ក៏ដូចជាវិស័យឯកជន ដៃគូរជាតិ និងអន្តរជាតិផងដែរ។




រូបភាពទី៤៖ យន្តការសហការលើកិច្ចការងារបណ្តុះបណ្តាលធនធានមនុស្សផ្នែកបច្ចេកវិទ្យា

## ៣.២. យុទ្ធសាស្ត្រកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃជាស្ថាប័នកំពូលមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានភារកិច្ចគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ហើយក៏ជាស្ថាប័នមួយដែលមានតួនាទីផ្តល់សេវាសាធារណៈពាក់ព័ន្ធដោយផ្ទាល់ជាមួយប្រជាពលរដ្ឋច្រើនជាងគេ ដែលមានអគ្គនាយកដ្ឋានក្រោមចំណុះចំនួន១២ ក្នុងនោះមានអង្គភាពមួយចំនួនជាអង្គភាពផ្តល់សេវាសាធារណៈផ្ទាល់ និងមួយចំនួនមិនមែនជាអង្គភាពផ្តល់សេវាសាធារណៈឡើយ។ ក្នុងនោះមានអង្គភាពមួយចំនួនបាននឹងកំពុងអនុវត្តការងារតាមបែបប្រពៃណី នៅមិនទាន់មានការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ជួយសម្រួលដល់ការបំពេញកិច្ចការងារនៅឡើយទេ។ ទន្ទឹមគ្នានោះក៏មានអង្គភាពមួយចំនួនទៀតកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាជំនួយក្នុងការផ្តល់សេវាសាធារណៈ ការរក្សាទុកឯកសារ ឬទិន្នន័យផ្សេងៗ និងគ្រប់គ្រងលំហូរការងារផ្សេងៗជាដើម។ អង្គភាពដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាជំនួយនីមួយៗកំពុងប្រើប្រាស់បណ្តាញហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់បច្ចេកវិទ្យា ដែលគ្រប់គ្រងដោយសាមីអង្គភាពផ្ទាល់ ឬដោយក្រុមហ៊ុនឯកជន មិនមានការតភ្ជាប់បណ្តាញហេដ្ឋារចនាសម្ព័ន្ធជារួមឡើយ ជាហេតុធ្វើឱ្យមានការពិបាកក្នុងការផ្លាស់ប្តូរទិន្នន័យរវាងអង្គភាពមួយនិងអង្គភាពមួយទៀត ក៏ដូចជាធ្វើឱ្យការផ្តល់សេវាសាធារណៈរបស់ក្រសួងមហាផ្ទៃ មានភាពយឺតយ៉ាវ និងចំណាយធនធានច្រើន។ ហេតុដូចនេះ ក្រសួងមហាផ្ទៃបានបង្កើតនូវយុទ្ធសាស្ត្រកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យារួមមួយ ដើម្បីឱ្យអង្គភាពក្រោមចំណុះអាចធ្វើការតភ្ជាប់គ្នាបាន ដែលនឹងធ្វើឱ្យការផ្តល់សេវាផ្សេងៗកាន់តែមានប្រសិទ្ធភាពខ្ពស់និងឆាប់រហ័សជាងមុន ជាពិសេសការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋទូទៅ ព្រមទាំងសន្សំសំចៃថវិកាជាតិ ដោយកាត់បន្ថយការចំណាយធនធានឱ្យនៅតិចបំផុត ក៏ដូចជាត្រៀមខ្លួនរួចជាស្រេចសម្រាប់ការតភ្ជាប់ជាមួយក្រសួងស្ថាប័នដទៃផ្សេងទៀតស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថល។




**រូបភាពទី៥៖ លំហូរការងារគ្រប់គ្រង និងការតភ្ជាប់ប្រព័ន្ធបច្ចេកវិទ្យាក្របខណ្ឌក្រសួងមហាផ្ទៃ**

ដូចនេះ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ក្រសួងបានដាក់ចេញនូវយន្តការស្នូលចំនួន ៤ ដូចខាងក្រោម៖

### ៣.២.១. យន្តការពង្រឹងបណ្តាញហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា

ជំរុញការធ្វើបរិវត្តកម្មឌីជីថលពីការបំពេញការងារតាមបែបប្រពៃណីទៅជាឌីជីថល ដោយប្រើប្រាស់បច្ចេកវិទ្យាបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងព័ត៌មាន ប្រកបដោយប្រសិទ្ធភាព និងសក្តានុពល។

❖ <u>ផែនការសកម្មភាពទី ០១ ៖</u> ការគ្រប់គ្រង និងការសម្រួលដល់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងចំណាយតិច ដោយប្រើប្រាស់សេវាកម្មបច្ចេកវិទ្យាបណ្តាញផ្ទាល់របស់រាជរដ្ឋាភិបាល ឬបណ្តាញរបស់ក្រុមហ៊ុនទូរគមនាគមន៍ដែលមានអនុស្សារណៈយោគយល់។

សេវាកម្មបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍និងព័ត៌មាន បានដើរតួនាទីយ៉ាងសំខាន់សម្រាប់ការគ្រប់គ្រងការធ្វើសមាហរណកម្មរួមទាំងពហុព័ត៌មាន និងទិន្នន័យត្រូវបានផ្តល់ជូនអង្គភាព និងអាជ្ញាធរដែនដីក្នុងរាជធានី/ខេត្ត ព្រមទាំងតំបន់ជនបទដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃនៅទូទាំងប្រទេសតាមរយៈការរួមបញ្ចូលគ្នារវាងសេវាកម្មបច្ចេកវិទ្យារបស់ក្រុមហ៊ុនទូរគមនាគមន៍ និងសេវាកម្មបច្ចេកវិទ្យាគមនាគមន៍ដោយផ្ទាល់របស់ក្រសួងមហាផ្ទៃ។ ក្រសួងត្រូវធានាដល់ការផ្តល់សេវាកម្មល្អបំផុតជាសកលសម្រាប់អង្គភាពរដ្ឋាភិបាលជាមួយនឹងផែនការរយៈពេលវែង ដែលការទាំងនេះត្រូវរួមបញ្ចូលទាំងការទទួលបាននូវសេវាបច្ចេកវិទ្យាគមនាគមន៍ចល័តទាំងក្នុង និងក្រៅប្រទេស សេវាអ៊ីនធឺណិត សេវាតភ្ជាប់លើការផ្លាស់ប្តូរទិន្នន័យល្បឿនលឿន សេវាកម្មគ្រប់គ្រងទំនាក់ទំនងជាសម្លេង/បណ្តាញអ៊ីនធឺណិត និងសេវាទូរគមនាគមន៍ផ្សេងទៀតឱ្យបានទៅដល់តាមបណ្តាខេត្ត និងតំបន់ជនបទដោយផ្ទាល់ជាមួយបច្ចេកវិទ្យាទំនើបចុងក្រោយនៃបណ្តាញខ្សែកាបអុបទិក (FTTx)។

➢ <u>ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ០១</u>

- ធ្វើការផ្តល់ជូនគ្រប់វិស័យដែលទាក់ទងជាមួយនឹងការប្រើប្រាស់អ៊ីនធឺណិត និងធនធានកុំព្យូទ័រតាមរយៈបណ្តាញហេដ្ឋារចនាសម្ព័ន្ធដើម្បីការផ្លាស់ប្តូរទិន្នន័យរបស់ស្ថាប័ន
- ធ្វើការតម្លើង និងថែរក្សាបណ្តាញហេដ្ឋារចនាសម្ព័ន្ធប្រភេទខ្សែស្ពាន់ និងកាបអុបទិកក្នុងអគារស្ថាប័នទាំងអស់
- ធ្វើការគ្រប់គ្រងបណ្តាញទំនាក់ទំនង ដែលតភ្ជាប់ទិន្នន័យរបស់ស្ថាប័នដោយប្រើប្រាស់បច្ចេកវិទ្យា MPLS
- ធ្វើការគ្រប់គ្រង ថែរក្សាបណ្តាញ និងមជ្ឈមណ្ឌលសេវាកម្មហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា
- ធ្វើការគ្រប់គ្រង និងផ្តល់នូវប្រសិទ្ធភាពនៃសេវាកម្មទូរគមនាគមន៍ (សំឡេង និងទិន្នន័យ) ដែលគាំទ្រដល់បេសកកម្ម និងគោលបំណងរបស់ស្ថាប័ន
- ធ្វើការលើកកម្ពស់បណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (សំឡេង និងទិន្នន័យ) ដើម្បីពង្រីកសេវាកម្ម និងផ្តល់នូវការប្រាស្រ័យទាក់ទងដែលអាចទុកចិត្តបានប្រកបដោយសុវត្ថិភាព ក្នុងការទទួលបាននូវធនធានតាមរយៈបច្ចេកទេស និងកម្មវិធីចាំបាច់សម្រាប់បេសកកម្មស្ថាប័ន

- អនុវត្តការវាយតម្លៃតម្រូវការប្រចាំឆ្នាំ ដើម្បីកែលម្អលើប្រភេទតភ្ជាប់ និងទំនាក់ទំនងឱ្យក្លាយជាកម្រិតសហគ្រាស
- ត្រួតពិនិត្យ និងពង្រឹងការកែប្រែបណ្ដាញទូរគមនាគមន៍ទាំងអស់ដើម្បីប្រើប្រាស់ និងកាត់បន្ថយប្រតិបត្តិការឱ្យបានច្រើនបំផុត
- ជំរុញការចូលរួមប្រើប្រាស់សេវាកម្មទូរគមនាគមន៍របស់ស្ថាប័ន សម្រាប់អាជ្ញាធរគ្រប់គ្រងដើម្បីកែលម្អសេវាកម្មបណ្ដាញហេដ្ឋារចនាសម្ព័ន្ធ និងកាត់បន្ថយចំណាយលើវិស័យទូរគមនាគមន៍នៅថ្នាក់មូលដ្ឋាន
- គ្រប់គ្រងការអនុវត្តបណ្ដាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងទំនើបតាមបែបបច្ចេកទេសនៅគ្រប់ទីតាំងដែលបានសាងសង់ និងជួសជុលថ្មីតាមរយៈអន្តរគោលនយោបាយ និងនីតិវិធី
- ផ្ដល់សេវាកម្មថ្មីបន្ថែម និងធ្វើការបណ្ដុះបណ្ដាលអ្នកប្រើប្រាស់លើការត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធការត្រួតពិនិត្យបណ្ដាញ និងការគ្រប់គ្រងគម្រោងដែលកំពុងដំណើរការ
- ពិនិត្យមុខងារ និងសេវាកម្មសុវត្ថិភាពលើទម្រង់សេវាទំនាក់ទំនងសំលេង និងទិន្នន័យ
- អនុវត្តកម្មវិធីទំនាក់ទំនងជាសម្លេងតាមរយៈអ៊ីនធឺណិតវីអូអាយភី (VOIP) និងកម្មវិធីឆ្លើយតបរហ័សដែលសមរម្យផ្សេងទៀត
- សម្របសម្រួលដល់ការផ្លាស់ប្ដូររបត់ការងារទៅជាសេវាកម្មដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលអាចធានាបាននូវប្រតិបត្តិការរួមជាមួយនឹងការគ្រប់គ្រងដែលទាក់ទងទៅនឹងសន្និធិ ការគាំទ្រ និងការថែរក្សាបណ្ដាញ
- ដាក់បញ្ចូលស្តង់ដារឧស្សាហកម្មបច្ចេកវិទ្យាទូរគមនាគមន៍ថ្មី ដើម្បីលើកកម្ពស់ និងបំពេញសេចក្ដីត្រូវការ ក៏ដូចជាការផ្លាស់ប្ដូរវិស័យដឹកជញ្ជូនក្របខណ្ឌក្រសួងមហាផ្ទៃ។

❖ **ផែនការសកម្មភាពទី ០២ ៖** បញ្ជ្រាបការប្រើប្រាស់សេវាកម្មបណ្ដាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងសេវាកម្មមជ្ឈមណ្ឌលទិន្នន័យខ្នាតធំ។

នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានមើលឃើញអំពីភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍធនធានទាំង Hardware និង Software របស់ប្រព័ន្ធបច្ចេកវិទ្យានានាឆ្លើយតបទៅនឹងសេចក្ដីត្រូវការដ៏ជាក់លាក់នៃសង្គមឌីជីថល។ ការរីកចម្រើនយ៉ាងគំហុកនេះ បានបង្កឱ្យមានការចូលរួមទាំងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា Hardware និង Software ដែលតម្រូវឱ្យមានការបំពេញបន្ថែមលើប្រតិបត្តិការសេវាកម្មបច្ចេកទេសជាមួយលក្ខខណ្ឌនៃការវាស់វែងដែលអនុលោមតាមបទដ្ឋានសុវត្ថិភាព។ មជ្ឈមណ្ឌលទិន្នន័យ (Data Center) ដែលជាប្រភពផលិត និងផ្គត់ផ្គង់សេវាកម្មបែបបច្ចេកវិទ្យា គឺជាចំណុចសំខាន់មួយនៃដំណើរការដោះស្រាយគាំពារដល់ការងាររដ្ឋាភិបាលឌីជីថល ដោយធ្វើការផ្ទេរពីប្រតិបត្តិការការងារ និងនីតិវិធីតាមបែបប្រពៃណីរបស់ស្ថាប័នមកដំណើរការតាមបែបស្វ័យកម្ម ហើយវាក៏បានជួយដល់ស្ថាប័នក្នុងការពង្រឹងនូវការកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាសុវត្ថិភាពរហ័ស សម្រាប់ការផ្ដល់សេវាកម្មរបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាព ភាពជឿជាក់ និងទំនុកចិត្តខ្ពស់។

## ➢ ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ០២

- កសាងមជ្ឈមណ្ឌលទិន្នន័យ (Data Center) ខ្នាតមធ្យមរបស់ស្ថាប័នតាមបែបបច្ចេកវិទ្យាពាក់កណ្ដាលស្វ័យកម្មជាមួយប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាពពក ដែលអាចចូលដំណើរការបានជាមួយនឹងដំណោះស្រាយប្រព័ន្ធបច្ចេកវិទ្យាពពកសាធារណៈ ដើម្បីរក្សាល្បឿននៃការផ្លាស់ប្ដូរផ្នែកបច្ចេកវិទ្យា និងឆ្លើយតបទៅនឹងតម្រូវការនៃបរិបទសម័យកុំព្យូទ័រ
- ធ្វើការពង្រាយទីតាំងមជ្ឈមណ្ឌលទិន្នន័យរបស់ស្ថាប័ន ដើម្បីលើកទឹកចិត្តឱ្យមានការផ្លាស់ប្ដូរក៏ដូចជាការដាក់បញ្ចូលប្រព័ន្ធរបស់ពួកគេ
- អនុវត្តដំណោះស្រាយបម្រុងទុក និងស្ដារគ្រោះមហន្តរាយដោយប្រើប្រាស់ប្រតិបត្តិការផ្នែកបច្ចេកវិទ្យារបស់ស្ថាប័នសម្រាប់ការពារដល់ប្រតិបត្តិការរបស់អង្គភាពក្រោមចំណុះ




**រូបភាពទី៦៖ មជ្ឈមណ្ឌទិន្នន័យក្រសួងមហាផ្ទៃ និងការតភ្ជាប់បម្រើដល់ប្រព័ន្ធអេកូឡូហ្ស៊ីឌីជីថលថ្នាក់ជាតិ**

- អនុវត្តដំណោះស្រាយបម្រុងទុក និងការស្ដារគ្រោះមហន្តរាយដោយផ្អែកលើសេវាកម្មរបស់ស្ថាប័នដែលត្រូវធានាឱ្យបាននូវរយៈពេលសមរម្យសម្រាប់ដំណើរការឡើងវិញ ហើយជួយគាំទ្រដល់ការកាត់បន្ថយចំណាយ
- អនុវត្តប្រព័ន្ធលេខរៀងរង់ចាំ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យដោយកំណត់រចនាសម្ព័ន្ធដែលត្រូវការតភ្ជាប់ជាមួយមជ្ឈមណ្ឌលប្រព័ន្ធសេវាកម្ម (ប្រតិបត្តិការតាមច្រកចេញចូលតែមួយ) ដើម្បីជួយក្នុងការបង្កើត និងពង្រឹងភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងប្រជាជនទូទៅ។ ការអនុវត្តនេះនឹងផ្ដល់ជូនដៃគូ និងប្រជាជនទូទៅនូវចំណុចទំនាក់ទំនងរួមតែមួយក្នុងការផ្ទៀងផ្ទាត់ ស្វែងរកទិន្នន័យ និងតាមដានព័ត៌មានផ្សេងៗជាមួយលេខរៀងរបស់ពួកគេ
- បង្កើតអត្ថប្រយោជន៍ និងសេវាកម្មបន្ថែមចេញពីប្រព័ន្ធដោយអនុលោមជាមួយការផ្ទៀងផ្ទាត់តាមបទដ្ឋានអនុវត្ត ITIL និង COBIT សម្រាប់ការគ្រប់គ្រងឧប្បត្តិហេតុ ការគ្រប់គ្រងសំណើសេវាកម្ម ការគ្រប់គ្រងបញ្ហា និងការគ្រប់គ្រងការផ្លាស់ប្ដូរចំពោះសំណើសុំទាំងឡាយ




**រូបភាពទី៧៖ លំហូរសេវាកម្មនៃបទដ្ឋាន ITIL និងអភិបាលកិច្ច COBIT**

- ពង្រឹង និងពង្រីកវិសាលភាពសមត្ថភាពមន្ត្រីដែលគាំទ្រដល់អគ្គនាយកដ្ឋាន និងវិស័យផ្សេងៗទៀត
- បង្កើនការប្រើប្រាស់កម្មវិធីត្រួតពិនិត្យវាយតម្លៃលើការអនុវត្តនៅគ្រប់ទម្រង់នៃចំណុចបច្ចេកវិទ្យាទាំងអស់
- ធ្វើការអភិវឌ្ឍ ថែរក្សា និងតេស្តសាកល្បងដំណើរការស្តារគ្រោះមហន្តរាយ និងការបន្តនិរន្តរភាពជាមួយនឹងនីតិវិធីដែលធ្វើឡើងសម្រាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញតភ្ជាប់សំខាន់ៗ
- កំណត់នូវលក្ខណៈនៃមជ្ឈមណ្ឌលទិន្នន័យសម្រាប់កម្មវិធី និងប្រព័ន្ធទាំងឡាយដែលត្រូវការបម្រុងទុកនៅខាងក្រៅ និងតម្រូវការចាំបាច់សម្រាប់ការសង្គ្រោះត្រឡប់មកវិញ។

❖ <u>ផែនការសកម្មភាពទី ០៣ ៖</u> ផ្តល់ការគាំពារ និងគាំទ្រលើផ្នែកសំខាន់ៗនៃបណ្តាញហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ដើម្បីជំនួយដល់ការពង្រឹងសុវត្ថិភាពសន្តិសុខលំហូរព័ត៌មានរបស់ក្រសួងមហាផ្ទៃ

ប្រព័ន្ធគាំពារ និងគាំទ្រ គឺជាគន្លឹះស្នូលសំខាន់ក្នុងការពង្រឹងយន្តការសុវត្ថិភាព សន្តិសុខលំហូរ និងការផ្លាស់ប្តូរទិន្នន័យរបស់អង្គភាពក្នុងការបំពេញភារកិច្ចជាមួយទំនួលខុសត្រូវផងដែរ។ តាមរយៈយន្តការនៃការគ្រប់គ្រងមួយចំនួនរួមមាន ប្រព័ន្ធគ្រប់គ្រងសន្តិសុខតាមអ៊ីនធឺណិត លំហូរសេវាកម្ម ការអភិវឌ្ឍគោលនយោបាយស្តង់ដា និងគោលការណ៍ណែនាំប្រព័ន្ធគាំពារនិងគាំទ្រ ផ្តល់ការត្រួតពិនិត្យសម្របសម្រួលទៅលើកិច្ចការងារផ្នែកសន្តិសុខ សុវត្ថិភាព និងទប់ស្កាត់ការវាយប្រហារពីចម្ងាយតាមបណ្តាញអ៊ីនធឺណិតទៅគ្រប់ទីតាំងនៃតំបន់ស្ថានីយ៍ទាំងអស់របស់អង្គភាពនីមួយៗក្រោមចំណុះក្រសួងមហាផ្ទៃ ហើយភាពស្មុគស្មាញ និងបញ្ហាប្រឈមនានាដែលទាក់ទងនឹងការគ្រប់គ្រងបែបរិមជ្ឈការ ក៏តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលដើម្បីជួយដល់ការកំណត់ឱ្យកាន់តែច្បាស់អំពីកម្រិតសុវត្ថិភាព និងសន្តិសុខជារួមរបស់ខ្លួន។

➢ <u>ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ០៣</u>

- តម្រង់ទិសគោលនយោបាយសុវត្ថិភាព និងសន្តិសុខទាំងមូល
- បង្កើតកម្មវិធីសុវត្ថិភាព និងសន្តិសុខបច្ចេកវិទ្យាទាំងមូលដែលមានកម្រិតស្តង់ដា ដោយធ្វើការសិក្សាតាមរយៈវិទ្យាស្ថាន ឬសាកលវិទ្យាល័យថ្នាក់ជាតិ

- ការបង្កើតក្របខ័ណ្ឌនីតិវិធីសុវត្ថិភាពតាមអ៊ីនធឺណិត និងការត្រួតពិនិត្យសុវត្ថិភាពនិងសន្តិសុខអាចអនុលោម និងយោងតាមការកំណត់របស់វិទ្យាស្ថានជាតិស្តង់ដាបច្ចេកវិទ្យាអិនអាយអេសធី (NIST) និងមជ្ឈមណ្ឌលសន្តិសុខអ៊ីនធឺណិតស៊ីអាយអេស (CIS)
- ធ្វើការវាយតម្លៃ និងជ្រើសរើសសំណើ (Request For Proposal) បម្រើដល់តម្រូវការនៃសេវាកម្មក្នុងការគ្រប់គ្រងសុវត្ថិភាព សន្តិសុខ ក្នុងគោលបំណងជួយដល់ការកំណត់អត្តសញ្ញាណវាស់វែង និងកំណត់ឱ្យបានជាអាទិភាពនូវហានិភ័យ ដែលអាចកើតមានឡើងដល់សម្បត្តិអាយស៊ីធីរបស់ស្ថាប័ន
- ផ្តល់ជូនដំណោះស្រាយដើម្បីចូលធ្វើការប្រើប្រាស់ពីចម្ងាយតាមរយៈបច្ចេកវិទ្យាវីភីអិន (VPN) ដែលដំណោះស្រាយបច្ចេកវិទ្យា VPN នេះបានធ្វើការពង្រីកបណ្តាញសុវត្ថិភាពជាលក្ខណៈឯកជនឆ្លងកាត់តាមបណ្តាញសាធារណៈដទៃទៀត ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចទៅចូលប្រើប្រាស់បណ្តាញនៅក្នុងស្ថាប័នពីចម្ងាយបាន
- ធ្វើការប្រមូល និងវិភាគព័ត៌មានទាក់ទងទៅនឹងការប្រើប្រាស់ ក៏ដូចជាតម្លៃដែលពាក់ព័ន្ធទៅនឹងដំណោះស្រាយ ឬសេវាកម្មសន្តិសុខតាមអ៊ីនធឺណិតសម្រាប់ស្ថាប័ន។ ការវិភាគព័ត៌មាននេះនឹងជួយដល់ការពង្រឹងកម្មវិធីសុវត្ថិភាពទិន្នន័យ និងសន្តិសុខព័ត៌មាន ក៏ដូចជាជំនួយដល់ការសម្រេចចិត្តសម្រាប់ការកាត់បន្ថយហានិភ័យ និងថ្លៃដើមក្នុងការបង្កើតនូវដំណោះស្រាយ និងសេវាកម្មសន្តិសុខផ្សេងទៀតឱ្យមានលក្ខណៈសមស្រប
- សិក្សាស្រាវជ្រាវអំពីដំណោះស្រាយ និងសេវាកម្មសុវត្ថិភាពទិន្នន័យ សន្តិសុខព័ត៌មានតាមរយៈបច្ចេកវិទ្យាក្លោដ(Cloud) ដើម្បីទទួលបានភាពប្រាកដប្រជាចំពោះការប្រើប្រាស់ ក៏ដូចជាការកាត់បន្ថយនូវរាល់ហានិភ័យក្នុងការបង្កើតគោលការណ៍ទប់ស្កាត់ សម្រាប់កម្មវិធីសុវត្ថិភាពសន្តិសុខឆ្លើយតបនឹងការប្រឆាំង ឬរាល់ការគំរាមកំហែងទាំងឡាយដែលអាចកើតមាន ជាមួយគ្នាផងដែរការអនុវត្តស្ថាបត្យកម្មហេដ្ឋារចនាសម្ព័ន្ធជាមួយបច្ចេកវិទ្យាក្លោដទៅលើបណ្តាញ ផ្តល់ភាពងាយស្រួលក៏ដូចជាទប់ស្កាត់ហានិភ័យមួយចំនួនយ៉ាងមានប្រសិទ្ធភាពគួរឱ្យជឿជាក់បាន
- ធ្វើការគ្រប់គ្រងលើសេវាកម្មសុវត្ថិភាពសន្តិសុខ ដែលបង្កើតឡើងជាមួយឧបករណ៍គ្រប់គ្រងសុវត្ថិភាពដើម្បីជួយបំពេញតម្រូវការសន្តិសុខដល់ភូមិសាស្ត្រក៏ដូចជាតម្រូវការផ្នែកច្បាប់ និងបទបញ្ជារបស់ស្ថាប័នសម្រាប់ការការពារបណ្តាញ និងកុំព្យូទ័ររបស់អ្នកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព
- ធ្វើការអភិវឌ្ឍ RFP បន្ថែម សម្រាប់តម្រូវការ និងអនុវត្តការការពារជាមួយដំណោះស្រាយសមរម្យដើម្បីបង្កើនសមត្ថភាពក្នុងការការពារទ្រព្យសម្បត្តិរដ្ឋ ប្រឆាំងទៅនឹងការវាយប្រហារដែលបានរកឃើញតាមរយៈការប្រោះ និងរារាំងចំពោះកម្មវិធីដែលមិនមែនជាតម្រូវការ ការព្យាបាទដោយបច្ចេកទេសកូដ ឬចរាចរណ៍ពីអ្នកប្រើប្រាស់ ដែលមានគំនិតអាក្រក់ពីបណ្តាញអ៊ីនធឺណិតទៅកាន់គេហទំព័រស្ថាប័ន និងប្រជាជនស៊ីវិល

- ផ្តល់សេវាកម្មគ្រប់គ្រងសុវត្ថិភាពសន្តិសុខ ដើម្បីជួយវាយតម្លៃ និងស្រាវជ្រាវអំពីការគំរាមកំហែង ដែលបានដាក់ជាអាទិភាពសម្រាប់ការដាស់តឿន និងផ្តល់មតិយោបល់ជាមួយបទពិសោធន៍ក្នុងការគ្រប់គ្រងហានិភ័យ
- ផ្តល់សេវាគ្រប់គ្រងសន្តិសុខ ដើម្បីជួយក្នុងការត្រួតពិនិត្យ និងវិភាគឧប្បត្តិហេតុសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត កាត់បន្ថយពេលវេលាដែលចាំបាច់ដើម្បីឆ្លើយតបក្នុងករណីមានឧប្បត្តិហេតុសន្តិសុខតាមអ៊ីនធឺណិត
- ធ្វើការកាត់បន្ថយពេលវេលាក្នុងការផ្តល់យោបល់ ឬឆ្លើយតប ដោយជួយត្រួតពិនិត្យ តាមដាន និងវិភាគលើឧប្បត្តិហេតុសុវត្ថិភាព ដោយអនុវត្តផែនការស្រាវជ្រាវ និងពិចារណាទុកមុនលើការអភិវឌ្ឍ RFP ចំពោះសេវាសុវត្ថិភាពគ្រប់គ្រងសន្តិសុខ ដែលស្ថិតក្រោមការគ្រប់គ្រងក្នុងករណីមានបញ្ហាសន្តិសុខតាមអ៊ីនធឺណិត
- បន្តស្រាវជ្រាវលើទីផ្សារអំពីការធានារ៉ាប់រងសម្រាប់ឧប្បត្តិហេតុតាមអ៊ីនធឺណិត ដើម្បីកាត់បន្ថយ និងទប់ស្កាត់ការខាតបង់ពីឧប្បត្តិហេតុតាមអ៊ីនធឺណិតដែលមានដូចជា ការចូលបំផ្លាញទិន្នន័យ ការចូលលួចយកទិន្នន័យ ការបំផ្លាញបណ្តាញ និងការទទួលខុសត្រូវនៃការខាតបង់របស់អ្នកប្រើប្រាស់។

### ៣.២.២. យន្តការពង្រឹងប្រសិទ្ធភាព នៃការគាំទ្រសេវាកម្មឌីជីថល

ស៊ើបអង្កេត អភិវឌ្ឍ និងលើកកម្ពស់ដំណោះស្រាយសេវាកម្មរួមគ្នាតាមរយៈបច្ចេកវិទ្យារវាងអង្គភាពនីមួយៗក្រោមចំណុះក្រសួងមហាផ្ទៃ ដើម្បីទទួលបានការបែងចែកអត្ថប្រយោជន៍ច្រើនបំផុត។

❖ <u>ផែនការសកម្មភាពទី ០៤ ៖</u> អនុវត្ត និងលើកកម្ពស់ដំណោះស្រាយឌីជីថលរបស់ស្ថាប័នជាមួយដំណោះស្រាយសេវាកម្មចល័តដើម្បីផ្តល់សេវាកម្មក្នុងវិស័យសាធារណៈ។

សារៈសំខាន់នៃភាពជាដៃគូរបស់វិស័យសាធារណៈ និងឯកជន គឺសេវាកម្មរបស់ស្ថាប័នរដ្ឋ និងស្ថាប័នឯកជន ដោយផ្តោតលើការផ្គត់ផ្គង់សេវាកម្មឱ្យមានប្រសិទ្ធភាពខ្ពស់ ទាន់ពេលវេលា ទាំងដំណោះស្រាយអចល័តនិងចល័តដទៃដូចជា កម្មវិធីកុំព្យូទ័រ គេហទំព័រ និង APPs ដែលប្រើប្រាស់បណ្តាញអ៊ីនធឺណិត ដើម្បីឱ្យប្រជាពលរដ្ឋ ធុរកិច្ចជន បុគ្គលិករដ្ឋាភិបាល និងអង្គភាពក្នុងស្រុកអាចទទួលបានអត្ថប្រយោជន៍ពីដំណោះស្រាយដែលបានផ្តល់ជូន។ គោលដៅនៃភាពជាដៃគូនេះ គឺផ្តល់លទ្ធភាពដល់អង្គភាពចំណុះក្រសួងក្នុងការបង្កើននូវប្រសិទ្ធភាពកម្មវិធីសេវាកម្ម និងផ្តល់ព័ត៌មានតាមរយៈគេហទំព័រដល់ប្រជាពលរដ្ឋ រួមផ្សំជាមួយការផ្សព្វផ្សាយតាមរយៈប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមប្រកបដោយប្រសិទ្ធភាព។

➢ <u>ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី០៤</u>

- ផ្តល់ឱ្យមានការគាំពារ និងគាំទ្រតាមរយៈលិខិតរដ្ឋបាលសម្រាប់ប្រសិទ្ធភាពមុខងារ ដែលរួមមានការប្រើប្រាស់វិធីសាស្ត្រឱ្យមានការដាក់ពង្រាយពាក្យសុំរបស់រដ្ឋាភិបាលឌីជីថលនៅទូទាំងស្ថាប័នរបស់រដ្ឋ
- បង្កើតការដឹកនាំក្នុងការប្រមូលព័ត៌មានត្រឡប់មកវិញតាមរយៈបច្ចេកវិទ្យាទូរស័ព្ទស្មាតហ្វូន រួមផ្សំជាមួយការច្នៃប្រឌិតថ្មី

- ពង្រីកការប្រើប្រាស់ម៉ាស៊ីនទូទាត់អេឡិចត្រូនិក ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬវិស័យឯកជន
- ធ្វើឱ្យកាន់តែប្រសើរឡើងនូវវិបផតថល (Web Portal) របស់ស្ថាប័ន ក៏ដូចជាកម្មវិធី និងគេហទំព័រ ដើម្បីផ្តល់ព័ត៌មានបន្ថែមដល់អ្នកប្រើប្រាស់ ជាមួយការលើកទឹកចិត្តក្នុងការប្រើប្រាស់សេវាកម្មឌីជីថលរបស់ស្ថាប័នឱ្យបានច្រើនបំផុត
- ប្រើប្រាស់វិធីសាស្ត្រចែករំលែកសេវាកម្មស្ថាប័ន ដើម្បីផ្តល់លទ្ធភាពស្មើគ្នាក្នុងបច្ចេកវិទ្យាជឿនលឿន
- ពង្រីកការប្រើប្រាស់កម្មវិធីអ៊ីនធឺណិត និងសេវាទូរស័ព្ទស្មាតហ្វូនដល់កម្រិតមូលដ្ឋាន ក្រុមប្រឹក្សា និងគណៈកម្មការនានា។

❖ **<u>ផែនការសកម្មភាពទី ០៥ ៖</u>** អនុវត្តសេវាកម្មទូរសារអេឡិចត្រូនិកប្រកបដោយប្រសិទ្ធភាពសម្រាប់ស្ថាប័ន

ការរៀបចំដំណោះស្រាយនៃការបម្រើទម្រង់សេវាកម្មទូរសារអេឡិចត្រូនិក ដោយផ្តល់នូវមធ្យោបាយក្នុងការគ្រប់គ្រងប្រព័ន្ធដោយខ្លួនឯង ជាមួយការជម្រុញបន្ថែមនូវកម្រិតស្តង់ដាប្រសិទ្ធភាពដើម្បីកាត់បន្ថយការចំណាយទូទៅ ហើយវាក៏ជាដំណោះស្រាយមួយដែលត្រូវបានបង្កើតឡើងដើម្បីជួយដល់កិច្ចការងាររដ្ឋបាលក្នុងការពង្រីកសមត្ថភាព និងអត្ថប្រយោជន៍បន្ថែមលើសពីសេវាកម្មសារអេឡិចត្រូនិកធម្មតា ហើយកិច្ចការងាររដ្ឋបាលនេះនឹងជួយដល់ស្ថាប័នដោយបន្ថែមជាមួយមុខងារមួយចំនួនដូចជា ការកំណត់ឈ្មោះទូទៅ ការបង្កើតសៀវភៅអាស័យដ្ឋានរបស់បុគ្គលិក មុខងារប្រតិទិន មុខងារប្រមូលឯកសារ និងមុខងារក្រុមការងារក៏ដូចជាការទទួលបាននូវសេវាកម្មដែលមានលក្ខណៈប្រសើរឡើងផ្សេងទៀតដូចជា ការចែករំលែកឯកសារជាក្រុម និងទម្រង់កិច្ចការងាររដ្ឋបាលពេញលេញ ហើយសេវាកម្មទាំងនេះក៏ជាផ្នែកមួយនៃកិច្ចការងាររដ្ឋបាលរបស់អាជ្ញាធរដទៃទៀតផងដែរ។

➢ <u>ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ០៥</u>

- បន្តស្នើសុំការគាំទ្រផ្នែកប្រតិបត្តិការសម្រាប់ដំណោះស្រាយសារអេឡិចត្រូនិក ដែលផ្តោតសំខាន់លើប្រសិទ្ធភាពនៃប្រតិបត្តិការ និងសន្សំសំចៃការចំណាយដែលមានសក្តានុពល
- បង្កើតដំណោះស្រាយគ្រប់គ្រងអត្តសញ្ញាណគ្រប់ជ្រុងជ្រោយសម្រាប់ស្ថាប័ន
- បន្តទំនាក់ទំនងទាក់ទងនឹងមុខងារទូរសារអេឡិចត្រូនិកស្នូល ជាមួយហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការសម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ
- ធ្វើការកំណត់ទិសដៅនៃដំណោះស្រាយដោយផ្តោតរកកិច្ចព្រមព្រៀងមួយ ដែលមានរួមបញ្ចូលកិច្ចព្រមព្រៀងដោយឡែកដែលមានស្រាប់
- ធ្វើការពង្រឹងសេវាកម្មទូរសារអេឡិចត្រូនិកជាមួយមុខងារច្រោះ និងបញ្ជូនតាមកម្រិត
- អភិវឌ្ឍឧបករណ៍ដែលអាចផ្តល់ការរាយការណ៍ និងគ្រប់គ្រងឱ្យបានទូលំទូលាយដើម្បីសម្រួលដល់នីតិវិធីក្នុងការប្រើប្រាស់ និងការអនុវត្តទាក់ទងនឹងសេវាកម្មដែលបានផ្តល់ជូន
- បន្តការស្រាវជ្រាវ និងអនុវត្តបន្ថែមដើម្បីជំរុញ និងពន្លឿនយុទ្ធសាស្ត្រឱ្យស្របទាន់សេវាកម្មស្ថាប័ន។

- **ផែនការសកម្មភាពទី ០៦ ៖** ស៊ើបអង្កេត លើកយោបល់ និងអនុវត្តសេវាកម្មស្តារគ្រោះមហន្តរាយប្រកបដោយសក្តានុពល និងប្រសិទ្ធភាព។

ការធ្វើទំនើបកម្មនៃកម្មវិធីរបស់ស្ថាប័នគួបផ្សំនឹងការចូលប្រើប្រាស់គេហទំព័រ ធ្វើឱ្យយើងចាំបាច់ត្រូវពិចារណាឡើងវិញ និងធ្វើឱ្យប្រសើរឡើងនូវយុទ្ធសាស្រ្តស្តារគ្រោះមហន្តរាយដែលមានស្រាប់។ ប្រជាពលរដ្ឋបច្ចុប្បន្នរំពឹងថា ការធ្វើជំនួញជាមួយស្ថាប័ននឹងមានភាពរហ័ស និងអាចទុកចិត្តបានដូចជាការធ្វើជំនួញនៅលើអ៊ីនធឺណិត។ ដើម្បីធានានិរន្តរភាព និងភាពងាយស្រួលក្នុងការទទួលបានធនធានសេវាកម្មរបស់ស្ថាប័នក្នុងករណីមានគ្រោះមហន្តរាយ ផែនការស្តារគ្រោះមហន្តរាយដ៏រឹងមាំមួយ និងដំណោះស្រាយបម្រុងទុក គឺមានសារៈសំខាន់ណាស់ដើម្បីឆ្លើយតបជាមួយពេលវេលាជាក់លាក់ក្នុងការស្តារសេវាកម្មឡើងវិញ។ ជាងនេះទៅទៀត វិធីសាស្រ្តសង្គ្រោះគ្រោះមហន្តរាយតែមួយ និងដំណោះស្រាយថ្មីត្រូវបានតម្រូវឱ្យមានការផ្តល់ជាជម្រើសដើម្បីបំពេញតាមតម្រូវការពិសេសជាក់លាក់របស់ប្រជាពលរដ្ឋ។ ការផ្តល់ការគាំទ្រលើដំណោះស្រាយថ្មីនេះ ក៏ត្រូវផ្តល់ឱ្យតាមរយៈសេវាកម្មដែលអាចត្រូវបានរៀបចំឡើងដោយប្រើប្រាស់ភាពសំខាន់នៃមុខងាររបស់ APPs។

- **ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ០៦**
  - បង្កើតយុទ្ធសាស្រ្តស្តារឡើងវិញ ដែលមានលក្ខណៈល្អប្រសើរចំពោះគ្រោះមហន្តរាយឱ្យបានគ្រប់ជ្រុងជ្រោយជាមួយជម្រើសឆ្លើយតបភ្ជាប់ជាមួយពេលវេលាជាក់លាក់នៃការស្តារ និងគោលបំណងនៃការស្តារឡើងវិញ
  - អភិវឌ្ឍដំណោះស្រាយស្តារគ្រោះមហន្តរាយតាមរយៈភាពជាដៃគូយុទ្ធសាស្រ្ត
  - ធ្វើការវាយតម្លៃចំពោះដំណោះស្រាយបម្រុងទុកដោយផ្ទាល់របស់បច្ចេកវិទ្យាពពក និងបច្ចេកវិទ្យាពាក់កណ្តាលស្វ័យកម្មដើម្បីធានាដល់ការការពារទិន្នន័យរបស់រដ្ឋ
  - ធានាថារាល់ទិន្នន័យដែលរក្សាទុកនៅកន្លែងមានសុវត្ថិភាពជាមួយនឹងវិធានការបំប្លែង និងវិធានការសុវត្ថិភាពដទៃទៀត
  - ជំរុញការគាំទ្រដល់ប្រតិបត្តិការនៃសេវាកម្មសង្គ្រោះគ្រោះមហន្តរាយជាមួយការបម្រុងទុក ដែលមាននៅក្នុងស្ថាប័ន
  - ធ្វើការតេស្តវាយតម្លៃ និងវាស់វែងលទ្ធផលជាប្រចាំដើម្បីធានាបានថាសមត្ថភាពមុខងារនៃការស្តារគ្រោះមហន្តរាយមានលក្ខណៈគ្រប់គ្រាន់។

- **ផែនការសកម្មភាពទី ០៧ ៖** ស៊ើបអង្កេត លើកយោបល់ និងអនុវត្តដំណោះស្រាយបច្ចេកវិទ្យាកុំព្យូទ័រពពក (Cloud Computing) ប្រកបដោយប្រសិទ្ធភាពសម្រាប់ស្ថាប័ន។

បរិបទនៃបច្ចេកវិទ្យាកុំព្យូទ័រពពក បានប្រែក្លាយទៅជាបច្ចេកវិទ្យាព័ត៌មាននាំមុខមួយនៅក្នុងវិស័យសាធារណៈជាមួយការធានាបាននូវប្រសិទ្ធភាពខ្ពស់ និងការសន្សំសំចៃថ្លៃដើម។ នៅក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចដែលទទួលរងឥទ្ធិពលពីជំងឺកូវីដ-១៩ ការព្យាយាមបង្រួបបង្រួមមជ្ឈមណ្ឌលទិន្នន័យ និងសេវាកម្ម

ព្រមទាំងបច្ចេកទេសស្រដៀងគ្នាដែលមានមូលដ្ឋានគ្រឹះនៃការប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រពពក គឺជាគំនិតនៃការបង្រួបបង្រួមហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មរួមគ្នា ហើយវាជួយជានាដល់ការបង្វិលជុំនៃវិនិយោគមូលធនសមស្រប (CAPEX) ដោយផ្តោតលើលទ្ធកម្ម ការអនុវត្ត និងដំណើរការហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់ដែលជាប្រយោជន៍នៃការគាំពារទៅវិញទៅមកចំពោះការចំណាយលើប្រតិបត្តិការ (OPEX) ក្នុងការពង្រីកសេដ្ឋកិច្ចដែលទទួលបានមកពីការចែករំលែកនៃតម្រូវការសេវាកម្មរួមនៅពេលប្រើប្រាស់ផងដែរ។ ការពង្រីកសេដ្ឋកិច្ចជាមួយការវិនិយោគលើបរិបទបច្ចេកវិទ្យាពពក គឺបានជួយសម្រួលដល់ការសន្សំសំចៃឱ្យមានប្រសិទ្ធភាពចំពោះការគ្រប់គ្រងលើការសាងសង់បណ្តាញបានមួយផ្នែក។

➢ <u>ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ០៧</u>

- សម្របសម្រួលដំណើរការកិច្ចលទ្ធកម្មបច្ចេកវិទ្យា តាមរយៈការប្រើប្រាស់ដំណោះស្រាយផែនការធនធានសហគ្រាស (ERP)
- បន្តលើកកម្ពស់ដំណើរការកិច្ចលទ្ធកម្ម ដើម្បីផ្តល់ភាពងាយស្រួល និងតម្លាភាពដល់អ្នកផ្គត់ផ្គង់ និងអង្គភាពលទ្ធកម្មតាមរយៈការបើកកម្មវិធីគេហទំព័រឱ្យប្រើប្រាស់
- ការបោះពុម្ពផ្សាយតាមអ៊ីនធឺណិតសម្រាប់សំណើសុំ (RFP) ដោយបញ្ជាក់អំពីបំណង បញ្ជាក់អំពីវិញ្ញាបនបត្រលទ្ធកម្ម និងការផ្សាយពាណិជ្ជកម្ម
- ធ្វើការបង្ហាញព័ត៌មានស្តីពីស្ថានភាពលទ្ធកម្ម
- ធ្វើការបោះពុម្ពផ្សាយលទ្ធផលលទ្ធកម្ម / ព័ត៌មានអំពីរង្វាន់
- បន្តពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវស្តង់ដាសម្រាប់ការអនុវត្តលើ RFP និងប្រភពនៃការផ្គត់ផ្គង់ចង្វាក់លទ្ធកម្មជាមួយវិធីសាស្រ្តវាយតម្លៃ
- តម្រឹមគោលគំនិតរបស់ក្រសួងលើឧបករណ៍ព័ត៌មានវិទ្យា តាមរយៈដំណោះស្រាយសេវាកម្មជាមួយផែនការចែកចាយស្ថាបត្យកម្មបច្ចេកវិទ្យាឌីជីថល
- ធ្វើកិច្ចសហការជាមួយក្រុមហ៊ុនផ្គត់ផ្គង់ និងអ្នកលក់បន្តលើបញ្ជីផលិតផល (Express Products List) ដើម្បីផ្តល់ជូនទីភ្នាក់ងារ សាកលវិទ្យាល័យសាធារណៈ និងអាជ្ញាធរគ្រប់គ្រងមូលដ្ឋានក្នុងការទិញយកជម្រើសនៃបច្ចេកវិទ្យាបច្ចុប្បន្នតាមលក្ខណៈទាន់ពេលវេលា និងជានាប្រសិទ្ធភាពចំណាយ
- បង្កើនដំណើរការលទ្ធកម្មផ្ទៃក្នុង ដោយសង្កត់ធ្ងន់លើដំណើរការឱ្យសមស្រប ត្រឹមត្រូវទៅនឹងសំណើទាំងអស់ដែលបូករួមទាំងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ប្រៀបធៀបទៅនឹងការឡើងចុះនៃបន្ទុកការងារតាមរដូវកាលដែលបណ្តាលមកពីកង្វះមូលនិធិ
- ពន្លឿនការអនុម័តលើការផ្គត់ផ្គង់ទំនិញគ្រប់កម្រិតសម្រាប់គម្រោងបច្ចេកវិទ្យាដែលបានស្នើសុំ
- ផ្តល់ការបណ្តុះបណ្តាលយ៉ាងសកម្ម និងទាន់ពេលវេលាដល់ដៃគូ ប្រជាពលរដ្ឋ អាជ្ញាធរស៊ីវិល និងអាជ្ញាធរដែនដីគ្រប់ប្រភេទ
- ទំនាក់ទំនងនៃច្បាប់ និងនីតិវិធីលទ្ធកម្មដោយផ្អែកលើពេលវេលាជាក់លាក់ និងបទពិសោធន៍ល្អបំផុត

- សម្របសម្រួលដល់ការពិភាក្សារវាងក្រសួងមហាផ្ទៃ និងវិស័យដទៃទៀតស្តីពីយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមបច្ចេកវិទ្យា
- សម្របសម្រួលដំណើរការលទ្ធកម្មជាមួយដំណើរការរៀបចំផែនការបច្ចេកវិទ្យា ដើម្បីធ្វើការកំណត់ឱ្យបានរាល់នូវសំណើទាំងឡាយព្រមទាំងកំណត់ទិសដៅបច្ចេកវិទ្យាជាក់លាក់
- លើកកម្ពស់ក្នុងការប្រើប្រាស់ធនធានបច្ចេកទេសដែលមានស្រាប់ ជំនួសឱ្យការផ្គត់ផ្គង់គ្រឿងបរិក្ខារថ្មី និងបែងចែកចេញចំពោះសម្ភារប្រើប្រាស់លែងបានតទៅទៀត
- ផ្តល់កិច្ចសហការចំពោះតម្រូវការធ្វើឱ្យប្រសើរឡើងនូវឧបករណ៍លទ្ធកម្ម ដើម្បីជម្រុញឱ្យសម្រេចបានផលិតផល និងសេវាកម្មបច្ចេកវិទ្យាល្អបំផុត
- អនុម័តរាល់ដំណោះស្រាយទាំងឡាយណា ដែលមានមុខងាររួមក្នុងការផ្តល់នូវផលិតផលស្តង់ដាដល់ក្រសួងមហាផ្ទៃ។

### ៣.២.៣. យន្តការគ្រប់គ្រង និងការធ្វើទំនើបកម្មឧបករណ៍បច្ចេកវិទ្យា

ការវិនិយោគជាយុទ្ធសាស្ត្រដោយជំរុញលើការផ្គត់ផ្គង់ចង្វាក់លទ្ធកម្ម និងការគ្រប់គ្រងបច្ចេកវិទ្យាឌីជីថល។

❖ <u>ផែនការសកម្មភាពទី ០៨ ៖</u> ការផ្តួចផ្តើមយុទ្ធសាស្ត្រ និងការអនុវត្តលទ្ធកម្មប្រកបដោយភាពច្នៃប្រឌិត និងការសហការ

Helpdesk គឺជាកម្មវិធីដែលអាចជួយស្ថាប័ន និងអាជ្ញាធរមូលដ្ឋានក្នុងការទទួលបានការគាំពារទាំង Hardware និង Software ព្រមទាំងធនធានសេវាកម្មព័ត៌មានវិទ្យាផ្សេងទៀត ស្របពេលគ្នានេះដែរយើងក៏អាចបង្កើតវិស្វកម្មឡើងវិញក្នុងការកែលម្អជាបន្តបន្ទាប់នៃដំណើរការនីតិវិធីលទ្ធកម្ម តាមរយៈការផ្លាស់ប្តូរយុទ្ធសាស្ត្រដោយផ្តោតលើកិច្ចសហប្រតិបត្តិការ។ ទន្ទឹមគ្នានេះកិច្ចលទ្ធកម្មក៏បានជួយសម្រួលដល់ការប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាតែមួយផងដែរ។ ការធ្វើឱ្យប្រសើរឡើងនៅក្នុងដំណើរការកិច្ចលទ្ធកម្ម គឺផ្តោតសំខាន់លើការអនុវត្ត ដោយសំដៅការផ្តល់សេវាកម្មល្អជាងមុនទៅដល់ស្ថាប័នជាដៃគូ ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ហើយជួយដល់ការសន្សំសំចៃពេលវេលាផងដែរ។

➢ <u>ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ០៨</u>

- ស្វែងរកកាលានុវត្តន៍ភាពដើម្បីអភិវឌ្ឍ និងអនុវត្តសេវាកម្មឌីជីថល ដែលមានលក្ខណៈសាមញ្ញសម្រាប់កម្មវិធីគម្រោងរដ្ឋាភិបាលឌីជីថល ក្នុងគោលបំណងកាត់បន្ថយភាពត្រួតគ្នាក្នុងចំណោមអង្គភាពនានាចំណុះក្រសួងមហាផ្ទៃ
- ពង្រីកសក្តានុពលសេដ្ឋកិច្ចឱ្យអស់លទ្ធភាពដោយកំណត់ថ្លៃដើមថេរចំពោះបរិមាណដែលធំ ដើម្បីកាត់បន្ថយថ្លៃដើមឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ រួមទាំងចំណាយទៅលើធនធានមនុស្សជំនាញបច្ចេកទេសឌីជីថលផងដែរ

- ផ្តោតលើការលើកកម្ពស់នៃការបញ្ចូលទិសដៅរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ដែលមានគោលបំណងសម្រេចបាននូវកំណើនសេដ្ឋកិច្ច និងបង្កើនគណនេយ្យភាពជាមួយការអនុវត្តដំណោះស្រាយមានលក្ខណៈជាចង្វាក់សហគ្រាស
- ស្វែងរកការរួមបញ្ចូលគ្នារវាងផ្នែកនានា ដើម្បីធ្វើការដោះស្រាយលក្ខណៈជាចង្វាក់សហគ្រាសរបស់ក្រសួងមហាផ្ទៃ ទៅលើមុខងារទាំងអស់ដោយប្រើប្រាស់កម្មវិធីផ្នែកទន់ ផ្នែករឹង ប្រព័ន្ធទំនាក់ទំនង កម្មវិធីទិន្នន័យ និងកិច្ចសន្យាសេវាកម្មវិជ្ជាជីវៈ
- ផ្តល់ការអនុញ្ញាតឱ្យមានការរិះគន់ជាចំហរ ចំពោះយុទ្ធសាស្ត្រនៃគម្រោងបច្ចេកវិទ្យាឌីជីថលដែលបានកំណត់ជាអាទិភាពដោយថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ជាមួយការវាយតម្លៃលើថវិកាបម្រុងតាមរយៈដំណើរការរៀបចំថវិកាគ្រោងទុកដាច់ដោយឡែក ហើយត្រូវគ្រប់គ្រងតាមដានត្រួតពិនិត្យ និងរាយការណ៍តាមរយៈការិយាល័យគ្រប់គ្រងគម្រោង
- ធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រក្នុងការផ្តល់មូលនិធិបច្ចេកវិទ្យាឌីជីថល តាមរយៈការពង្រីកការអនុម័តចង្វាក់មូលនិធិប្រកបដោយភាពច្នៃប្រឌិត និងការសន្សំសំចៃលើការកែលម្អសេវាកម្មជូនប្រជាពលរដ្ឋ និងរដ្ឋាភិបាល
- អង្កេតលើគំនិតផ្តួចផ្តើមនៃសេវាកម្មឌីជីថល ដើម្បីផ្តល់មូលនិធិសម្រាប់ធ្វើបច្ចុប្បន្នភាព។

❖ <u>ផែនការសកម្មភាពទី ០៩</u> ៖ លើកកម្ពស់ការយល់ដឹង និងតម្រង់ទិសនៃដំណើរការវិនិយោគឌីជីថល

កិច្ចដំណើរការវិនិយោគនៃបច្ចេកវិទ្យាឌីជីថល គឺសំដៅធានាឱ្យបានថាស្ថាប័ននឹងទទួលបានការប្រើប្រាស់បច្ចេកវិទ្យាទំនើបជាមួយនឹងភាពច្នៃប្រឌិតថ្មី ហើយបច្ចេកវិទ្យាឌីជីថលដែលនឹងក្លាយជាសមាសធាតុសំខាន់នៃហេដ្ឋារចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ សម្រាប់ប្រើប្រាស់នៅគ្រប់សេវាកម្មសាធារណៈដើម្បីដោះស្រាយបញ្ហាប្រតិបត្តិការរបស់ស្ថាប័ន ទាំងបញ្ហាកម្លាំងពលកម្ម និងបញ្ហាដែលផ្តោតលើការផ្តល់សេវាកម្ម។ ទោះយ៉ាងណាក៏ដោយ ការជ្រើសរើសកម្មវិធីបច្ចេកវិទ្យាដែលសមស្របគឺត្រូវទាមទារឱ្យមានការធ្វើផែនការច្បាស់លាស់ ការវិភាគយ៉ាងហ្មត់ចត់ និងចក្ខុវិស័យដ៏រឹងមាំដែលអាចបំពេញតម្រូវការរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរ និងជួយសម្រួលដល់ការធ្វើអភិបាលកិច្ចរបស់ស្ថាប័នក្នុងការកែលម្អដំណើរការស្ថាប័នផ្ទៃក្នុងដោយធានាបាននូវចំណាយសមរម្យ និងងាយស្រួលក្នុងការអនុវត្ត។ នាពេលបច្ចុប្បន្ននេះ ការរៀបចំគម្រោងការថវិកា និងថវិកាបម្រុងទុកសម្រាប់គម្រោងបច្ចេកវិទ្យាឌីជីថលរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានសម្រេចជាមូលដ្ឋានមួយជាក់លាក់ ហើយឱកាសជាច្រើនដែលមានអាចត្រូវបានប្រើប្រាស់ដើម្បីសម្រេចបាននូវការវិនិយោគជាយុទ្ធសាស្ត្រឱ្យកាន់តែខ្លាំងឡើងនៃធនធានបច្ចេកវិទ្យាឌីជីថលនៅទូទាំងរដ្ឋាភិបាល រួមទាំងការធ្វើផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ ការធ្វើកម្មវិធីចរន្តនៃប្រាក់សន្សំទៅកាន់ថវិកាបម្រុងទុក និងការអនុវត្តកម្មវិធីនានាដែលធានាបានដល់ការត្រឡប់មកវិញនូវការវិនិយោគ។

➢ <u>ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ០៩</u>

- បន្តលើកកម្ពស់ការអភិវឌ្ឍកិច្ចសន្យារបស់អ្នកផ្គត់ផ្គង់

- បញ្ចូលលក្ខខណ្ឌក្នុងកិច្ចសន្យាដើម្បីគាំទ្រដល់ការវិវឌ្ឍន៍នៃបច្ចេកវិទ្យាឌីជីថល និងការអនុវត្តនៅក្នុងក្រសួងមហាផ្ទៃ រួមទាំងវិធានការណ៍ផ្សេងៗដើម្បីពង្រឹងជំហរសន្តិសុខរបស់ក្រសួងមហាផ្ទៃ
- គ្រប់គ្រងកិច្ចសន្យាដោយប្រើប្រាស់សេវាកម្មកម្មវិធី escrow
- គ្រប់គ្រងកិច្ចព្រមព្រៀងមេនៃសេវាទូរស័ព្ទ និងអ្នកផ្តល់សេវាកម្មបច្ចេកទេសសម្រាប់ធនធានបច្ចេកវិទ្យាឌីជីថលឱ្យជាអ្នកម៉ៅការឯករាជ្យ។

❖ ផែនការសកម្មភាពទី ១០ ៖ ពង្រឹងយុទ្ធសាស្ត្រក្នុងការអនុវត្តការគ្រប់គ្រងកិច្ចសន្យា

កិច្ចសន្យាសេវាកម្មឌីជីថលរវាងស្ថាប័ន និងអតិថិជន លទ្ធកម្មផ្សេងទៀតសម្រាប់ការទទួលបានផ្នែករឹងនៃប្រព័ន្ធព័ត៌មានវិទ្យា កម្មវិធីស្ថាប័ននិងសេវាកម្ម ព្រមទាំងគំនិតផ្តួចផ្តើមដែលកំពុងបន្តការកែលម្អជាបន្តបន្ទាប់នៃការអភិវឌ្ឍ និងការគ្រប់គ្រងកិច្ចសន្យា ជាមួយនឹងយុទ្ធសាស្ត្រចរចាដោយមានគោលដៅសម្រាប់ពង្រឹងជំហររបស់រាជរដ្ឋាភិបាលជាមួយអ្នកលក់បច្ចេកវិទ្យាឌីជីថល វាអាចផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមកក្នុងការចែកចាយផលិតផល និងសេវាកម្មបច្ចេកវិទ្យាឌីជីថលប្រកបដោយប្រសិទ្ធភាព។

➢ ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ១០

- ផ្តល់វគ្គបណ្តុះបណ្តាលដោយខ្លួនឯងតាមអ៊ីនធឺណិត
- ផ្តល់ការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាតាមអ៊ីនធឺណិត
- ផ្តល់កម្មវិធីបណ្តុះបណ្តាលប្រព័ន្ធព័ត៌មានវិទ្យា ទូលំទូលាយដល់អ្នកប្រើប្រាស់បច្ចេកទេស និងថ្នាក់ដឹកនាំ។

### ៣.២.៤. យន្តការពង្រឹង និងលើកកម្ពស់នវានុវត្តន៍ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា

លើកកម្ពស់ដល់ការចែករំលែកព័ត៌មាននៅគ្រប់ផ្នែកតាមរយៈបច្ចេកវិទ្យាឌីជីថល ដើម្បីជម្រុញឱ្យមានភាពសហការរួមគ្នាប្រកបដោយភាពច្នៃប្រឌិត និងការផ្លាស់ប្តូរបែបបទរបស់ស្ថាប័នក្នុងលក្ខណៈឌីជីថល។

❖ ផែនការសកម្មភាពទី ១១ ៖ បង្កើត និងអភិវឌ្ឍផែនការបច្ចេកវិទ្យាឌីជីថលដែលជម្រុញដល់ការសម្របសម្រួល និងការវិនិយោគដែលធ្វើឱ្យកាន់តែប្រសើរឡើងលើផ្នែកឌីជីថល

វិស័យជាច្រើនកំពុងតែធ្វើការចាប់អារម្មណ៍ទៅលើការផ្សារភ្ជាប់គ្នារវាងប្លង់មេ នៃបច្ចេកវិទ្យាឌីជីថលមួយដែលជារឿយៗត្រូវបានគេហៅថាស្ថាបត្យកម្មសហគ្រាស និងការវិនិយោគលក្ខណៈសហគ្រាសលើវិស័យឌីជីថល។ ប្លង់មេបច្ចេកវិទ្យាឌីជីថលបង្ហាញពីសមាសធាតុបច្ចេកវិទ្យាសំខាន់ៗដើម្បីបង្កើតប្រព័ន្ធអេកូឡូហ្ស៊ីឌីជីថល ហើយវាក៏ជាវិធីសាស្ត្រនៃការរៀបចំផែនការដ៏ទូលំទូលាយមួយសម្រាប់ស្ថាប័នក្នុងការរួមបញ្ចូលគ្នានៃព័ត៌មាន និងសេវាកម្មសម្រាប់តំបន់នីមួយៗរបស់ស្ថាប័ន។ ប្លង់មេនៃបច្ចេកវិទ្យាឌីជីថលគាំទ្រដល់ការសម្របសម្រួលមុខងារគាំទ្របច្ចេកវិទ្យាផ្សេងៗដែលអាចបង្កើត និងពង្រឹងស្តង់ដាជាក្រមគោលនយោបាយសម្រាប់លំហូរទិន្នន័យ សន្តិសុខ សុវត្ថិភាពចរន្ត ការទិញ ការគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការសម្រាប់ការវិនិយោគទាំងអស់នៅគ្រប់ជ្រុងនៃបច្ចេកវិទ្យាឌីជីថល។

➢ ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ១១

- អនុវត្តប្លង់គំរូដោយផ្អែកលើស្តង់ដាសម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់ក្រសួង ដែលអាចកំណត់បានទាំងស្រុងនូវការចែករំលែកទិន្នន័យចំពោះមុខងារទាំងអស់ ដើម្បីផ្តល់នូវការប្រើប្រាស់ជាទូទៅមួយនៃផ្នែកទន់ ផ្នែករឹង ប្រព័ន្ធទំនាក់ទំនង និងកម្មវិធីទិន្នន័យផ្សេងៗទៀត
- បង្កើនប្រសិទ្ធភាពនៃការចែករំលែកសមាសធាតុបច្ចេកវិទ្យាឌីជីថល រួមទាំងមជ្ឈមណ្ឌលទិន្នន័យ ប្រព័ន្ធអ៊ីម៉ែល កុំព្យូទ័រ ទម្រង់នៃការផ្គត់ផ្គង់ កន្លែងផ្ទុក កម្មវិធីជំនួយ និងបណ្តាញ។ សេវាកម្មចែករំលែកទាំងនេះអាចកាត់បន្ថយចរន្តនៃការទិញ និងថ្លៃតំហែទាំដែលអាចធានាបាននូវការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដែលមានស្រាប់ឱ្យកាន់តែប្រសើរឡើង និងលើកកម្ពស់អន្តរប្រតិបត្តិការគ្រប់ផ្នែករបស់ក្រសួង
- ការចាប់ផ្តើមអនុវត្តថ្មី និងពិនិត្យឡើងវិញនូវគោលនយោបាយស្តង់ដា គោលការណ៍ណែនាំ និងការទិញឧបករណ៍ ដែលមានស្រាប់សម្រាប់ភាពស្ថិតស្ថេរក៏ដូចជាតម្រង់ទិសដៅយុទ្ធសាស្ត្រ
- កំណត់ និងពិនិត្យឡើងវិញនូវកិច្ចដំណើរការជាទូទៅរបស់ក្រសួង
- គាំទ្រការងារអន្តរវិស័យ ដែលទាក់ទងដល់ការផ្តួចផ្តើមកិច្ចសហប្រតិបត្តិការជាក់លាក់នៃដំណើរការរបស់ប្រព័ន្ធដូចជា ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ប្រព័ន្ធសុវត្ថិភាពការងារ ប្រព័ន្ធចូលនិវត្តន៍ និងសេវាកម្មមនុស្ស
- អភិវឌ្ឍជម្រើសគោលដៅផ្សេងៗ និងណែនាំអំពីសកម្មភាពទាក់ទងនឹងសេវាកម្មចែករំលែកនាពេលអនាគតដែលនឹងផ្តល់ឱ្យនូវតម្លៃស្នូល និងការសន្សំសំចៃ
- សម្របសម្រួលដល់គំនិតផ្តួចផ្តើមនៃការរៀបចំផែនការ និងសម្ព័ន្ធវិធីសាស្ត្រសម្រាប់ការរួមបញ្ចូលគ្នានៃអាជីវកម្ម និងបច្ចេកវិទ្យា ដោយធ្វើការបន្សុីគ្នារវាងប្រព័ន្ធព័ត៌មានវិទ្យា កិច្ចដំណើរការ ការរៀបចំអង្គភាព និងប្រជាជនដល់ស្ថាប័ន។

❖ **ផែនការសកម្មភាពទី ១២ ៖** សម្របសម្រួលដំណើរការបញ្ចូលគ្នានៃការរៀបចំផែនការ និងការផ្សព្វផ្សាយក្នុងស្ថាប័ន។

តម្រូវការសេវាកម្មឌីជីថល គឺមានឥទ្ធិពលទៅបានតាមរយៈការផ្តល់សេវាកម្មជាប់លាប់ និងការប្រើប្រាស់ធនធានឌីជីថលប្រកបដោយប្រសិទ្ធភាព ដោយធ្វើការខិតខំប្រឹងប្រែងស្វែងរកដំណោះស្រាយល្អ និងសន្សំសំចៃបំផុតចំពោះតម្រូវការរបស់ស្ថាប័ន។ ការរៀបចំផែនការបច្ចេកវិទ្យាឌីជីថលមួយច្បាស់លាស់គឺជួយដល់ការវិនិយោគចំពោះកង្វះខាតធនធានសាធារណៈ និងដើម្បីបង្កើនផលិតភាពរបស់មន្ត្រីក្នុងស្ថាប័នក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាដល់ប្រជាពលរដ្ឋ និងគ្រប់សេវាកម្មសាធារណៈរបស់អង្គភាពក្រោមចំណុះក្រសួង។ សេវាកម្មឌីជីថល គឺផ្តោតលើសេវាកម្មដែលមាននៅក្នុងមជ្ឈមណ្ឌលទិន្នន័យ ក៏ដូចជាតម្រូវការនៃផលិតផល និងសេវាកម្មបច្ចេកវិទ្យា សេវាទូរគមនាគមន៍ និងប្រព័ន្ធសុវត្ថិភាព។ ក្រសួងគួរតែផ្តល់នូវការផ្សព្វផ្សាយដល់អង្គភាពក្រោមចំណុះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងជាមួយគ្រប់សេវាសាធារណៈ និងធនធានដើម្បីជួយដល់ផលិតផល និងសេវាកម្មបច្ចេកវិទ្យាឌីជីថលនានា។

➤ ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ១២

- សម្របសម្រួលដល់កិច្ចប្រជុំតាមផ្នែកនានា ដើម្បីត្រួតពិនិត្យឡើងវិញនូវសេវាកម្មបច្ចេកវិទ្យាឌីជីថល ដែលបានផ្តល់នាពេលបច្ចុប្បន្នក្នុងការធានាឱ្យបាននូវការពេញចិត្ត និងពិនិត្យមើលបញ្ជីគម្រោងសម្រាប់ឱកាសសក្តានុពលក្នុងការប្រើប្រាស់ធនធានឌីជីថលប្រកបដោយប្រសិទ្ធភាពទៅតាមផែនការ
- បង្កើតក្រុមការងារផ្តល់ប្រឹក្សាអន្តរអង្គភាពផ្នែកបច្ចេកវិទ្យាឌីជីថល ក្នុងការបន្តជួយរៀបចំទិសដៅ និងកំណត់ការងារអាទិភាពសម្រាប់គំនិតផ្តួចផ្តើមផ្នែកបច្ចេកវិទ្យារបស់ស្ថាប័ន
- ផ្តល់ការគាំទ្រលើសម្ភារឧបករណ៍បច្ចេកទេស តាមបណ្តាញអ៊ីនធឺណិតចំពោះក្រុមប្រឹក្សា និង គណៈកម្មការដើម្បីជួយសម្រួលក្នុងការរៀបចំថវិកា និងផែនការនៃគម្រោងបច្ចេកវិទ្យាឌីជីថល
- ពង្រីកប្រព័ន្ធផែនការបច្ចេកវិទ្យាឌីជីថលរបស់ស្ថាប័នឱ្យមានមុខងារកាន់តែច្រើន ជាមួយនឹងទម្រង់របាយការណ៍កាន់តែប្រសើរឡើង
- ពិនិត្យឡើងវិញនូវផែនការបច្ចេកវិទ្យាឌីជីថលតាមវិស័យនីមួយៗ ដោយសិក្សាអំពីផលប៉ះពាល់ និង តម្រូវការហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថាប័ន កិច្ចសហការ ការអប់រំបណ្តុះបណ្តាល សក្តានុពល និងវិស័យដែលជាចំណាប់អារម្មណ៍ផ្សេងទៀត
- អភិវឌ្ឍដំណើរការគ្រប់គ្រងជាផ្លូវការមួយសម្រាប់ការត្រួតពិនិត្យ និងអនុម័តលើផែនការបច្ចេកវិទ្យា
- សម្របសម្រួលការគ្រប់គ្រង ការផ្លាស់ប្តូរជាប្រចាំជាមួយផ្នែកនានាដើម្បីលើកកម្ពស់ទំនាក់ទំនង
- បង្កើតការស្ទង់មតិដើម្បីទាញយកព័ត៌មានដែលទាក់ទងនឹងសេវាកម្ម និងប្រធានបទផ្សេងៗទៀត
- រៀបចំវេទិកាមួយដើម្បីជូនដំណឹងដល់គ្រប់ផ្នែកពាក់ព័ន្ធ នៃការផ្លាស់ប្តូរសេវាកម្មគោលនយោបាយ ឬនីតិវិធីបទដ្ឋាន ឬថ្លៃដើមសម្រាប់សេវាកម្មតាមតំបន់ដែលកំណត់ជាក់លាក់
- សម្របសម្រួលសន្និសីទជាមួយរបៀបវារៈបច្ចេកវិទ្យា ក្នុងការបញ្ចេញមតិយោបល់ជំនួយដល់ស្ថាប័ន
- បណ្តុះបណ្តាល និងពង្រឹងទំនាក់ទំនងដែលមានស្រាប់ដោយបង្កើតយន្តការដើម្បីជួយសម្រួលដល់ការផ្សព្វផ្សាយ និងចែករំលែកព័ត៌មានជាមួយគ្រប់វិស័យពាក់ព័ន្ធ។

❖ **ផែនការសកម្មភាពទី ១៣ ៖** បន្តការស្រាវជ្រាវលើបច្ចេកវិទ្យាឌីជីថលដែលកំពុងរីកចម្រើន និង ធ្វើការទំនាក់ទំនងជាមួយវិស័យឯកជនជាយុទ្ធសាស្ត្រ។

ស្ថាប័នប្រើប្រាស់សមត្ថភាពស្រាវជ្រាវ និងទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ដើម្បីទទួលបានព័ត៌មានក្នុងការផ្លាស់ប្តូរ និងធ្វើបច្ចុប្បន្នភាពឧស្សាហកម្មត្រង់ចំណុចដែលមានផលប៉ះពាល់។ អ្នកដឹកនាំបច្ចេកទេសឌីជីថលរបស់ស្ថាប័នត្រូវតាមដានត្រួតពិនិត្យមើលការផ្លាស់ប្តូរ និងនិន្នាការបច្ចេកវិទ្យានាពេលអនាគតដែលមាននៅក្នុងប្រព័ន្ធអេកូឡូហ្ស៊ីឌីជីថល ព្រមទាំងទទួលយកបច្ចេកវិទ្យា និងវិធីសាស្ត្រថ្មីៗ ដើម្បីបំពេញតម្រូវការរបស់ស្ថាប័ន។ ការស្រាវជ្រាវក្នុងការបង្កើតផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាឌីជីថល ជាយុទ្ធសាស្ត្រសម្រាប់ពេលអនាគតអាចធ្វើទៅបានលុះត្រាតែមានកិច្ចសហការរវាងបច្ចេកវិទ្យាថ្នាក់ជាតិ តម្រូវការនៅថ្នាក់មូលដ្ឋាន និងដំណោះស្រាយពីអ្នកផ្គត់ផ្គង់។

➢ ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ១៣

- ប្រើប្រាស់ភាពជាដៃគូរយ៉ាងពេញលេញជាមួយក្រុមហ៊ុនស្រាវជ្រាវ និងលើកយោបល់ប្រឹក្សាផ្នែកបច្ចេកវិទ្យាឌីជីថលឈានមុខគេ
- បន្តចូលរួមនៅក្នុងអង្គភាពបច្ចេកវិទ្យាឌីជីថលជាតិដោយផ្តោតលើស្ថាប័ន
- បន្តការស្រាវជ្រាវបច្ចេកវិទ្យាឌីជីថល និងច្នៃប្រឌិតដើម្បីរក្សាភាពជឿនលឿននៃបច្ចេកវិទ្យាចុងក្រោយ
- បង្កើនភាពជាដៃគូរជាមួយអង្គភាពរដ្ឋាភិបាលដទៃទៀត ដើម្បីស្វែងយល់ពីរបៀបដែលពួកគេកំពុងអនុវត្តបច្ចេកវិទ្យាឌីជីថលថ្មីៗ
- ជម្រុញការផ្លាស់ប្តូរឌីជីថលទៅស្ថាប័ន ដោយនាំមកនូវបច្ចេកវិទ្យាច្នៃប្រឌិតថ្មី។

❖ **ផែនការសកម្មភាពទី ១៤ ៖** ផ្តល់ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពតាមរយៈសកម្មភាពដែលទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងជាមួយគ្រប់សេវាកម្មសាធារណៈ និងជម្រុញធ្វើឱ្យបេសកកម្ម និងចក្ខុវិស័យសេវាកម្មឌីជីថលមានអន្តរកម្មសាធារណៈ។

សេវាកម្មបច្ចេកវិទ្យាឌីជីថល ត្រូវព្យាយាមផ្តល់ការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពដល់អង្គភាពក្រោមចំណុះក្រសួងមហាផ្ទៃ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការប្រាស្រ័យទាក់ទង និងផ្តល់ធនធានដើម្បីជួយដល់ការសម្រេចចិត្តផ្នែកបច្ចេកវិទ្យាសម្រាប់ផលិតផល និងសេវាកម្មដែលត្រូវការ។ បណ្តាញទំនាក់ទំនងមានចាប់តាំងពីកិច្ចប្រជុំ សិក្ខាសាលា កិច្ចប្រជុំកំពូល និងក្រុមប្រឹក្សាដែលបង្កើតឡើងសម្រាប់គំនិតផ្តួចផ្តើមសហគ្រាស។

➢ ចង្កោមសកម្មភាពគាំទ្រផែនការសកម្មភាពទី ១៤

- កំណត់បញ្ហាប្រឈមក្នុងការប្រាស្រ័យទាក់ទង និងកែតម្រូវយុទ្ធសាស្រ្តទាក់ទងជាមួយអ្នកវាយតម្លៃឬប្រើប្រាស់សេវាកម្មទាំងក្នុង និងក្រៅស្ថាប័ន
- វិភាគលើទម្រង់ទំនាក់ទំនង និងបង្កើតវិធីសាស្រ្ត ដើម្បីសម្រួចការទំនាក់ទំនងតាមគ្រប់ទម្រង់ឱ្យមានលក្ខណៈសមស្របជាមួយអ្នកប្រើប្រាស់
- អភិវឌ្ឍ និងធានាបាននូវប្រព័ន្ធផ្សព្វផ្សាយសង្គម និងសេវាកម្មគំហែទាំគេហទំព័រឌីជីថល ដោយធ្វើការរក្សាខ្លឹមសារមាតិកាដែលផ្តោតជាយុទ្ធសាស្រ្តទៅលើការធ្វើផែនការ ការបង្កើត ការចែកចាយ និងការគ្រប់គ្រង
- គ្រប់គ្រងការផលិត ការបោះពុម្ពផ្សាយយុទ្ធសាស្រ្ត ផែនការយុទ្ធសាស្រ្តបច្ចេកវិទ្យាឌីជីថល និងផែនការយុទ្ធសាស្រ្តរយៈពេល ០៥ឆ្នាំ រួមទាំងកាតាឡុកសេវាកម្មឌីជីថលផ្សេងៗជាមួយខិត្តប័ណ្ណ និងសៀវភៅណែនាំការស្ទង់មតិបន្ថែម និងរបាយការណ៍ប្រចាំឆ្នាំ។ល។
- ស្វែងរកកាលានុវត្តន៍ភាពដែលមានសក្តានុពល ដើម្បីបង្កើតឱ្យមានការទទួលស្គាល់កម្រិតថ្នាក់ជាតិក្នុងការបង្ហាញពីសមិទ្ធិផលការងាររបស់ស្ថាប័ន ការផ្តល់នូវសេវាកម្មបច្ចេកវិទ្យាឌីជីថលដល់ប្រជាជន
- ផ្តល់សេវាពិគ្រោះយោបល់ដើម្បីសម្របសម្រួលដល់ការអភិវឌ្ឍឱ្យមានប្រសិទ្ធភាព និងការប្រើប្រាស់សម្ភារអេឡិចត្រូនិកសម្រាប់ការប្រជុំជាសាធារណៈ សិក្ខាសាលា និងសន្និសីទ។

### ៣.៣. យុទ្ធសាស្ត្រពង្រឹងសន្តិសុខ និងទប់ស្កាត់បទល្មើសបច្ចេកវិទ្យា (Cyber Security and Cybercrime)

សន្ទុះនៃការវិវឌ្ឍន៍របស់ប្រព័ន្ធបច្ចេកវិទ្យាយ៉ាងលឿនក្រោមចរន្តនៃបដិវត្តន៍ឧស្សាហកម្ម៤.០ ធ្វើឱ្យតម្រូវការជំនាញផ្នែកបច្ចេកវិទ្យាឌីជីថលមានការប្រែប្រួលយ៉ាងខ្លាំង តាមរយៈការបង្កើតការងារថ្មីៗ ដែលមិនធ្លាប់មានពីមុនមកជំនួសការងារដែលមានស្រាប់ ក្នុងនោះជំនាញវិជ្ជាជីវៈបានដើរតួនាទីយ៉ាងចាំបាច់នៅក្នុងការផ្តល់លទ្ធភាពដល់បុគ្គលិកគ្រប់រូបឱ្យរក្សាស្ថិរភាពការងារ និងចាប់យកឱកាសសម្រាប់តួនាទីថ្មីៗ។ ដោយសារកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅកម្ពុជាមានសន្ទុះយ៉ាងខ្លាំង ស្របពេលដែលការយល់ដឹងរបស់អ្នកប្រើប្រាស់នៅមានកម្រិតនៅឡើយ ជាហេតុធ្វើឱ្យជនខិលខូចឆ្លៀតឱកាសកេងយកផលប្រយោជន៍ ឬប្រើប្រាស់បច្ចេកវិទ្យាដើម្បីប្រព្រឹត្តបទល្មើសជាច្រើន រួមមានដូចខាងក្រោម៖

- បទល្មើសហិរញ្ញវត្ថុ (Financial Crime)៖ គឺជាបទល្មើសបច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងអំពើក្លែងបន្លំលួចលុយ ឬផ្ទេរលុយ
- បទល្មើសឆបោកបន្លំលួចព័ត៌មាន និងគណនីអ៊ីនធឺណិត៖ បទល្មើសប្រភេទនេះកំពុងកើតមានជាច្រើនករណី (កម្រិតគួរឱ្យកត់សម្គាល់) រួមមាន ការបន្លំលួចព័ត៌មានបុគ្គល ព័ត៌មានធនាគារ ឬលេខសម្ងាត់ដោយប្រើប្រាស់វិស្វកម្មបណ្តាញសង្គម (Phishing) និងឈានដល់ការគ្រប់គ្រងគណនី
- ការជំរិត ឬគំរាមកំហែងដោយប្រើប្រាស់រូបភាព ឬវីដេអូអាសអាភាស (Sex Extortion)៖ ជាអំពើបោកបញ្ឆោតលួចថតយករូបភាព ឬវីដេអូអាសអាភាសរបស់ជនរងគ្រោះ និងគំរាមទារប្រាក់។ ក្នុងនោះមានបទល្មើសមួយចំនួនកើតឡើងពីសំណាក់ឧក្រិដ្ឋជនដែលមានជាអង្គការចាត់តាំង ប៉ុន្តែមួយចំនួនកើតឡើងដោយដៃគូស្នេហាជាដើម។
- ការបង្ហោះអត្ថបទ រូបភាពយាយី ឬបរិហារកេរ្តិ៍លើបណ្តាញទំនាក់ទំនងសង្គមផ្សេងៗ (Cyberbully/Defamation)៖ បទល្មើសប្រភេទនេះកំពុងកើតមានជាច្រើនករណី ជាពិសេសក្នុងស្រទាប់យុវជន។
- ការបង្ហោះព័ត៌មានមិនពិត (Fake News/Hate Speech) អំពើញុះញង់ និងបង្កចលាចលសង្គម៖ ជាការបង្កើតនូវព័ត៌មានក្លែងក្លាយ ឬព័ត៌មានញុះញង់ឱ្យមានការរើសអើងប្រកាន់ពូជសាសន៍ សាសនា ពណ៌សម្បុរជាដើម។ ព័ត៌មានក្លែងក្លាយ ឬញុះញង់មួយចំនួនអាចបង្កឱ្យមានចលាចលនៅក្នុងសង្គម។
- ការចម្លងមេរោគកុំព្យូទ័រ (Viruses and Malware)៖ មេរោគដែលអនុញ្ញាតឱ្យជនវាយប្រហារធ្វើការបញ្ជាកុំព្យូទ័រជនរងគ្រោះពីចម្ងាយ និងជាប្រភេទមេរោគចាក់សោរឯកសារជម្រិតទារប្រាក់ជាដើម។
- ល្បែងភ្នាល់ ល្បែងកំសាន្តអនឡាញខុសច្បាប់ (Online Gambling)៖ ជាអំពើលេងល្បែងភ្នាល់ ឬល្បែងស៊ីសងខុសច្បាប់តាមប្រព័ន្ធអនឡាញ។
- ការវាយប្រហារជ្រៀតចូលប្រព័ន្ធកុំព្យូទ័រ ឬម៉ាស៊ីនមេ (Hacking)៖ ជាអំពើជ្រៀតចូល ឬរំខានដល់ប្រព័ន្ធ ឬជាការចូលទៅលួច ឬបំផ្លាញទិន្នន័យដោយខុសច្បាប់។
- សកម្មភាពផ្សព្វផ្សាយមនោគមវិជ្ជាភេរវកម្ម (Cyberterrorism)។

វេទិកាក្រុមការងារប្រតិបត្តិការប្រឆាំងបទល្មើសបច្ចេកវិទ្យា INTERPOL ASEAN បានវិភាគទិន្នន័យដែលបានផ្តល់ដោយដៃគូរផ្នែកសន្តិសុខបច្ចេកវិទ្យាក្នុងវិស័យឯកជនរបស់ INTERPOL ដោយបានកំណត់ការគំរាមកំហែងសន្តិសុខ និងបទល្មើសបច្ចេកវិទ្យានៅក្នុងតំបន់ (ASEAN Cyberthreat Assessment 2021) មានដូចជា ៖

- ការចម្លងមេរោគម៉ាស៊ីនរងគ្រោះ (Botnets)
- បច្ចេកទេសវិស្វកម្មបណ្តាញសង្គម (Phishing)
- ការជ្រៀតចូលសារអេឡិចត្រូនិក (Business email compromise)
- មេរោគលួចទិន្នន័យធនាគារ (Banking malware)
- មេរោគជម្រិតទារប្រាក់ (Ransomware)
- ការលួចប្រើប្រាស់ម៉ាស៊ីនរងគ្រោះ ដើម្បីរកប្រាក់ឌីជីថល (Cryptojacking)

### ៣.៣.១. យន្តការទប់ស្កាត់បទល្មើសបច្ចេកវិទ្យា

មានកត្តារួមផ្សំមួយចំនួនដែលបង្កឱ្យមានភាពងាយរងគ្រោះ នៃការវាយប្រហារតាមប្រព័ន្ធបច្ចេកវិទ្យា ក៏ដូចជាបទល្មើសបច្ចេកវិទ្យាក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងតំបន់ ដែលកត្តាទាំងនោះមានដូចជា៖

- កំណើននៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាពីសំណាក់ប្រជាពលរដ្ឋទូទៅ
- កង្វះការយល់ដឹងអំពីហានិភ័យនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា
- កត្តាច្បាប់ បទដ្ឋានគតិយុត្ត និងយន្តការពាក់ព័ន្ធនានាដើរពុំទាន់បរិបទនៃប្រព័ន្ធបច្ចេកវិទ្យា (ដោយមើលឃើញអំពីផលលំបាកទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈអង្គភាពជំនាញកំពុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងយន្តការពាក់ព័ន្ធនានាដូចជា ច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងច្បាប់ស្តីពីសន្តិសុខបច្ចេកវិទ្យាជាដើម)
- ភាពអំណោយផលនៃប្រតិបត្តិការផ្ទេរប្រាក់ (Crypto Currency / Digital Payment / Payment System / Bank Transfer)
- ឧក្រិដ្ឋជនបច្ចេកវិទ្យាប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកទេសកម្រិតខ្ពស់ក្នុងការប្រព្រឹត្តបទល្មើស
- ឧក្រិដ្ឋជនចាប់ផ្តើមប្រព្រឹត្តបទល្មើស ស្ថិតក្រោមរចនាសម្ព័ន្ធចាត់តាំងជាដើម
- សមត្ថភាពមន្ត្រីអនុវត្តច្បាប់នៅមានកម្រិត
- កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការស៊ើបអង្កេតជាមួយប្រទេសជាដៃគូ និងក្រុមហ៊ុនផ្តត់ផ្គង់សេវាបច្ចេកវិទ្យានៅមានកម្រិត។




រូបភាពទី៨៖ យន្តការពង្រឹងសន្តិសុខ និងទប់ស្កាត់បទល្មើសបច្ចេកវិទ្យា

## ៣.៣.២. យន្តការគ្រប់គ្រងសន្តិសុខបច្ចេកវិទ្យា

ការការពារសន្តិសុខប្រព័ន្ធបច្ចេកវិទ្យា គឺជាអន្តរសកម្មភាពរួមទាំងការបង្កើតនូវគោលនយោបាយ បទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិផ្សេងៗជូនដល់អង្គភាពពាក់ព័ន្ធ ដោយមូលដ្ឋាននៃសុវត្ថិភាពបច្ចេកវិទ្យា ត្រូវបានផ្តោតលើចំណុចសំខាន់ចំនួន ៣ ដូចខាងក្រោម៖

- ការសំងាត់នៃទិន្នន័យ (Confidentiality)
- សុក្រិតភាពនៃទិន្នន័យ (Integrity)
- ការប្រើប្រាស់បាននៃទិន្នន័យ (Availability)




រូបភាពទី៩៖ មូលដ្ឋានសន្តិសុខបច្ចេកវិទ្យាព័ត៌មាន

### ៣.៣.២.១. យន្តការគ្រប់គ្រងប្រព័ន្ធសន្តិសុខព័ត៌មាន (Information Security Management System)

ដើម្បីធានាបាននូវសុវត្ថិភាពរបស់ប្រព័ន្ធ ចាំបាច់ត្រូវមានការសិក្សារៀបចំបង្កើតគោលនយោបាយ និងបទដ្ឋានគតិយុត្ត ព្រមទាំងដាក់ឱ្យអនុវត្តនៅគ្រប់តួអង្គទាំងអស់ក្នុងសង្គម ក្នុងនោះព្រះរាជាណាចក្រកម្ពុជាតាមរយៈក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ បានបង្កើតនូវបទដ្ឋានមួយដែលមានឈ្មោះថា "ការគ្រប់គ្រងប្រព័ន្ធសន្តិសុខព័ត៌មាន" (Information Security Management System - CS ISO/IEC 27001:2021) សម្រាប់ជាទស្សនាទានដល់បណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការជំរុញប្រព័ន្ធការពារសុវត្ថិភាពបច្ចេកវិទ្យា។ ក្នុងន័យនេះ ក្រសួងមហាផ្ទៃនឹងធ្វើការប្រើប្រាស់បទដ្ឋាននេះជាធាតុចូលស្នូលក្នុងប្រតិបត្តិការបច្ចេកវិទ្យារបស់ខ្លួន និងប្រើប្រាស់បទដ្ឋានពាក់ព័ន្ធថ្នាក់តំបន់ និងអន្តរជាតិដទៃទៀតផងដែរ។




រូបភាពទី១០៖ ការគ្រប់គ្រងប្រព័ន្ធសន្តិសុខព័ត៌មាន (Information Security Management System)

### ៣.៣.២.២. យន្តការសហប្រតិបត្តិការផ្នែកសន្តិសុខបច្ចេកវិទ្យា

កិច្ចសហប្រតិបត្តិការគឺជាកិច្ចការងារដ៏ចាំបាច់ក្នុងការអនុវត្តយន្តការគ្រប់គ្រង និងកាត់បន្ថយហានិភ័យបច្ចេកវិទ្យា ក្នុងនោះការអនុលោមតាមគោលនយោបាយថ្នាក់ជាតិ និងការតម្រឹមឱ្យត្រូវនឹងបរិបទនៃបច្ចេកវិទ្យារបស់ក្រសួងមហាផ្ទៃ ក៏ជាកិច្ចការងារមួយដែលត្រូវមានការរៀបចំឱ្យបានរួចរាល់ និងឆាប់រហ័ស។ ទន្ទឹមគ្នានេះ អង្គភាពចំណុះក្រសួងមហាផ្ទៃទាំងអស់ត្រូវចូលរួមសហការអនុវត្តនូវបទដ្ឋានរួមមួយ ដើម្បីធានាបាននូវការអនុលោមតាមតម្រូវការ និងសន្តិសុខប្រព័ន្ធ ក៏ដូចជាការបម្រើដល់ចរន្តការងារ និងការផ្ដល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពផងដែរ។




រូបភាពទី១១៖ យន្តការសហប្រតិបត្តិការ និងភាពប្រទាក់ក្រឡានៃសន្តិសុខបច្ចេកវិទ្យា

## ៣.៤. យុទ្ធសាស្ត្រស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យា (Research Develop and Innovation - RDI)

នៅក្នុងដំណើរធ្វើឱ្យសម្រេចបានតាមផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល និងផែនការសកម្មភាពគាំទ្រទាំងឡាយ យើងឃើញថាកិច្ចការងារស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍ (RDI) វិស័យបច្ចេកវិទ្យាឌីជីថលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកសាងសមត្ថភាពលើផ្នែកស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍នៃគម្រោងផែនការរដ្ឋាភិបាលឌីជីថលដែលត្រូវធ្វើការបែងចែកទៅតាមការវិវត្តន៍ជាដំណាក់កាលដូចជា ការពង្រឹងគោលការណ៍ផ្សព្វផ្សាយការងារ RDI ការកសាងប្រព័ន្ធគ្រប់គ្រង និងយន្តការផ្តល់មូលនិធិ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពនៃមជ្ឈមណ្ឌល RDI ដែលជាការចូលរួមចំណែកមួយយ៉ាងសំខាន់ក្នុងការងារស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្របខណ្ឌក្រសួងមហាផ្ទៃ ព្រមទាំងជួយពង្រឹង និងបង្កើនប្រសិទ្ធភាពក្នុងការបំពេញកិច្ចការងាររដ្ឋបាល និងកិច្ចការងារជំនាញផ្សេងៗ ជាពិសេសគឺកិច្ចការងារផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋស្របតាមចក្ខុវិស័យនៃគោលនយោបាយរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់គុណភាពជីវិត និងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ។

នៅក្នុងបេសកកម្មគាំទ្រដល់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យាក្របខណ្ឌក្រសួងមហាផ្ទៃ ក្រសួងបានដាក់ចេញនូវយន្តការចំនួន ៣ ដូចខាងក្រោម៖

### ៣.៤.១. យន្តការការពង្រឹងគោលការណ៍ផ្សព្វផ្សាយ RDI

- បង្កើតកម្មវិធីស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍ថ្នាក់ក្រសួង ដើម្បីធ្វើការផ្សព្វផ្សាយទាក់ទាញ និងប្រើប្រាស់ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការក្នុង និងក្រៅប្រទេស

- លើកទឹកចិត្តឱ្យអង្គភាព ឬស្ថាប័នស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍ ក្រោមចំណុះក្រសួងមហាផ្ទៃ មានផ្នែកផ្ទេរបច្ចេកវិទ្យា ដោយមានភារកិច្ចទទួល និងភ្ជាប់ទំនាក់ទំនងកម្មវិធីសូហ្វវែររវាងអង្គភាព ឬក្រសួងស្ថាប័ននានា រួមទាំងមានកម្មវិធីដើម្បីផ្សព្វផ្សាយពន្យល់ និងការចូលរួមគាំទ្រឱ្យបានទូលំទូលាយក្រោមយន្តការសម្របសម្រួលថ្នាក់ជាតិ
- សិក្សា និងរៀបចំកសាងយុទ្ធសាស្ត្រស្តីពីការជំរុញកិច្ចការងារស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍ សំដៅផ្តល់ទិសដៅ និងលើកកម្ពស់គំនិតផ្តួចផ្តើមកម្មវិធី និង/ឬ គម្រោងនានាសម្រាប់ការងារស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍។

### ៣.៤.២. យន្តការកសាងប្រព័ន្ធគ្រប់គ្រង RDI និងយន្តការផ្តល់មូលនិធិ

- បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍ (RDI Center) រួមមានការស្រាវជ្រាវបឋម ស្រាវជ្រាវអនុវត្ត និងការអភិវឌ្ឍដោយពិសោធន៍បង្កើតកម្មវិធី RDI នៅតាមបណ្តាអង្គភាពចំណុះ
- RDI មូលដ្ឋានទិន្នន័យហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ
- រៀបចំ RDI សម្រាប់ការផ្លាស់ប្តូរព័ត៌មាន និងចំណេះដឹងបច្ចេកវិទ្យាឌីជីថលតាមបណ្តាអង្គភាពចំណុះ
- ស្រាវជ្រាវរៀបចំឯកសារស្តង់ដាគំរូសម្រាប់កំណត់លក្ខខណ្ឌបច្ចេកទេស ពិធីសារ វិស្វកម្មកម្មវិធី និងប្រព័ន្ធព័ត៌មានចំណុះក្រសួង
- ស្រាវជ្រាវ និងកំណត់ដែនបច្ចេកវិទ្យាប្រកបដោយសក្តានុពលសម្រាប់ការផ្តល់សេវាសាធារណៈជាអាទិភាពរបស់ក្រសួងមហាផ្ទៃទាំង ៤ គឺ៖ ១-ការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មប្រជាពលរដ្ឋ ២-ការងារចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ៣-ការងារគ្រប់គ្រងជនបរទេស និង ៤-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមអង្គភាព និងការិយាល័យច្រកចេញចូលតែមួយ
- បង្កើនបរិយាកាសអំណោយផលសម្រាប់ការងារ RDI ដោយការបង្កើតឱ្យមានមូលនិធិ RDI របស់ក្រសួងផ្ទាល់ដើម្បីលើកទឹកចិត្តដល់ការងារស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍។

### ៣.៤.៣. យន្តការការលើកកម្ពស់ប្រសិទ្ធភាពនៃមជ្ឈមណ្ឌល RDI

- ធានាឱ្យមានមូលដ្ឋានបរិក្ខារសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធនៃ RDI ស្របតាមតម្រូវការជាក់ស្តែង ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ ហើយការបង្កើតមជ្ឈមណ្ឌល RDI ក៏ស្ថិតនៅក្នុងគម្រោងអាទិភាពមួយរបស់ក្រសួង សម្រាប់ប្រើប្រាស់រួមគ្នាតាមជំនាញនីមួយៗដែលធ្វើប្រតិបត្តិការដោយអ្នកបច្ចេកទេសជំនាញបំពេញឱ្យមូលដ្ឋានវិទ្យាសាស្ត្រដែលមានស្រាប់នៅតាមបណ្តាអង្គភាពចំណុះ
- កសាងក្របខណ្ឌភាពជាដៃគូជាមួយនឹងវិស័យឯកជនក្នុងការជំរុញ និងអភិវឌ្ឍការងារ RDI ដោយរួមផ្សំជាមួយនឹងការរៀបចំមូលនិធិគាំទ្រតាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បង្កើន និងគ្រប់គ្រងធនធានសម្រាប់ការងារ RDI ឱ្យមានប្រសិទ្ធភាព។

## ៣.៥. យុទ្ធសាស្ត្រពង្រឹងគុណភាពការងារ និងការផ្តល់សេវាសាធារណៈ

ក្នុងយុគសម័យរីកចម្រើនឥតឈប់ឈរនៃប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនៅលើសកលលោក ជាពិសេសការធ្វើដំណើរយ៉ាងលឿននិងប្រែប្រួលយ៉ាងឆាប់រហ័សនៃប្រព័ន្ធបច្ចេកវិទ្យា បានធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាចាំបាច់ត្រូវរៀបចំខ្លួនឱ្យរួចជាស្រេចសម្រាប់ដំណើរការធ្វើបរិវត្តកម្មឌីជីថលឱ្យបានទាន់ពេលវេលា ដើម្បីទាញយកប្រយោជន៍ឱ្យអស់លទ្ធភាពពីប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនេះ។ ដូច្នេះ ដើម្បីធ្វើការឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងបានកំណត់ចក្ខុវិស័យនៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល គឺការលើកកម្ពស់គុណភាពជីវិត និងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ។

វិស័យសាធារណៈដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវសេវាសាធារណៈជូនប្រជាពលរដ្ឋ ដូច្នេះការធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធសេវាសាធារណៈ ត្រូវឈរលើមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមអនុវត្តកម្មវិធី និងគំនិតផ្តួចផ្តើមមួយចំនួនក្នុងការធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធរដ្ឋបាលសាធារណៈ និងសេវាសាធារណៈជាបន្តបន្ទាប់។ ទោះជាយ៉ាងនេះក្តី នៅក្នុងដំណើរនៃការធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធសេវាសាធារណៈរបស់កម្ពុជា កំពុងតែស្ថិតនៅក្នុងល្បឿនមួយដែលមានសភាពយឺត បើធ្វើការប្រៀបធៀបជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និងសកលលោកដែលកំពុងស្ថិតក្នុងកម្រិតមធ្យម និងលឿនបង្គួរ។ ស្ថិតនៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានភាពចាំបាច់ត្រូវពន្លឿនការអនុវត្តគំនិតផ្តួចផ្តើម និងកិច្ចការងារកំណែទម្រង់ពាក់ព័ន្ធនានាដើម្បីសម្របខ្លួនទៅនឹងការធ្វើបរិវត្តកម្មឌីជីថល និងលើកកម្ពស់ការចូលរួមពីសំណាក់អ្នកប្រើប្រាស់ សំដៅប្រែក្លាយទៅជារដ្ឋាភិបាលឌីជីថលពេញលេញនៅពេលខាងមុខ។ ដើម្បីជំរុញរបៀបវារៈនៃការធ្វើកំណែទម្រង់របស់រាជរដ្ឋាភិបាលដោយប្រើប្រាស់បច្ចេកវិទ្យា និងបង្កើតបរិយាកាសប្រកបដោយបរិយាប័ន្នកម្មក្នុងការអភិវឌ្ឍ ក៏ដូចជាកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើកមួយ ដែលគាំទ្ររាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវបេសកកម្មនៃការធ្វើបរិវត្តកម្មឌីជីថលពេញលេញ ព្រមទាំងធ្វើការពង្រីកបន្ថែមដល់ធុរកិច្ចឌីជីថល និងពលរដ្ឋឌីជីថលផងដែរ។ ផ្អែកលើយុទ្ធសាស្ត្រដ៏មុឺងម៉ាត់ខាងលើនេះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានដាក់ចេញនូវអនុសាសន៍ណែនាំ និងគាំទ្រទាំងស្រុងលើការរៀបចំកសាងនូវផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថលរបស់ក្រសួងមហាផ្ទៃមួយ ដែលមានទស្សនវិស័យវែងឆ្ងាយគាំទ្រគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាទាំងលើកិច្ចការងាររដ្ឋបាល ការងារជំនាញបច្ចេកទេស ជាពិសេសការងារផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ព្រមទាំងដើម្បីពង្រឹងប្រសិទ្ធភាពការបំពេញការងាររបស់មន្ត្រីក្របខណ្ឌក្រសួងមហាផ្ទៃ។

ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ត្រូវផ្អែកលើយន្តការដែលមានការផ្សារភ្ជាប់គ្នារវាងគោលនយោបាយ បទដ្ឋានគតិយុត្ត រចនាសម្ព័ន្ធស្ថាប័ន និងប្រតិបត្តិការក្នុងផ្តល់សេវាដើម្បីឈានទៅបង្កើតនូវប្រព័ន្ធគាំទ្រដែលមានភាពប្រទាក់ក្រឡាគ្នា សំដៅលើកកម្ពស់គុណភាពជីវិត និងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការផ្តល់សេវា

សាធារណៈឱ្យកាន់តែល្អប្រសើរ។ ដូចនេះដើម្បីចូលរួមសម្រេចឱ្យបាននូវចក្ខុវិស័យជាតិដែលមានចែងនៅក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ក្រសួងមហាផ្ទៃបានដាក់ចេញនូវយន្តការគាំទ្រសំខាន់ៗចំនួន ៣ ដូចខាងក្រោម៖

### ៣.៥.១. យន្តការគ្រប់គ្រង និងអភិវឌ្ឍក្របខណ្ឌឌីជីថល

ជំរុញការរៀបចំ និងអនុម័តគោលនយោបាយចាំបាច់ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងសុវត្ថិភាព ក្នុងគោលដៅរួមចំណែកគាំទ្រដល់ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើកមួយដែលរួមមានគោលនយោបាយសំខាន់ៗដូចជា៖

- គោលនយោបាយអភិបាលកិច្ចទិន្នន័យ ដែលកំណត់អំពីគោលការណ៍ស្តង់ដា និម្មាបនកម្មទិន្នន័យ យន្តការនិងក្របខណ្ឌនៃការគ្រប់គ្រង ការចែកចំណាត់ថ្នាក់ ការចែករំលែក និងការការពារទិន្នន័យ ក្នុងគោលដៅធានាឱ្យមានទិន្នន័យគ្រប់គ្រាន់ប្រកបដោយគុណភាព និងសុវត្ថិភាពស្របទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់
- គោលនយោបាយទិន្នន័យបើកចំហ ដែលកំណត់អំពីគោលការណ៍ ស្តង់ដា និងយន្តការនៃការបើកចំហ ការរក្សាទុក និងការចែករំលែកទិន្នន័យរបស់អង្គភាពក្រោមចំណុះក្រសួង ទៅដល់វិស័យឯកជន ប្រជាពលរដ្ឋ និងអង្គភាព ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀតដើម្បីយកទៅប្រើប្រាស់ជាប្រយោជន៍ផ្សេងៗ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ការបើកចំហទិន្នន័យ មានគោលដៅលើកកម្ពស់តម្លាភាព គណនេយ្យភាព គុណភាពសេវា បង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើរាជរដ្ឋាភិបាល ព្រមទាំងលើកកម្ពស់ការស្រាវជ្រាវនិងនវានុវត្តន៍ និងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម
- គោលនយោបាយជំរុញការអភិវឌ្ឍ និងប្រើប្រាស់សូហ្វវែរដែលកំណត់គោលការណ៍ស្តង់ដាគុណភាព និងយន្តការកសាងធនធានមនុស្សជំនាញសម្រាប់គាំទ្រដល់ការអភិវឌ្ឍ និងប្រើប្រាស់សូហ្វវែរ។ គោលនយោបាយនេះនឹងបង្កើនការប្រើប្រាស់ និងការផ្គត់ផ្គង់សូហ្វវែរក្នុងស្រុក កាត់បន្ថយការចំណាយលើការនាំចូលសូហ្វវែរពីបរទេស លើកកម្ពស់សមត្ថភាពប្រកួតប្រជែង និងបង្កើនផលិតភាពសេដ្ឋកិច្ចជាតិ
- គោលនយោបាយអ៊ីនធឺណិតល្បឿនលឿន ដែលកំណត់អំពីគោលការណ៍ស្តង់ដាគុណភាពក្របខណ្ឌ និងយន្តការនៃការគ្រប់គ្រង ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាអ៊ីនធឺណិតល្បឿនលឿនដែលមានវិសាលភាពគ្របដណ្តប់គ្រប់ទីកន្លែងទូទាំងប្រទេស ងាយស្រួលប្រើប្រាស់ និងមានតម្លៃសមរម្យ ឆ្លើយតបទៅនឹងតម្រូវការ និងលទ្ធភាពចំណូលរបស់ប្រជាពលរដ្ឋ។ ការជំរុញការអភិវឌ្ឍអ៊ីនធឺណិតល្បឿនលឿន ជាកត្តាចាំបាច់សម្រាប់គាំទ្រ និងលើកកម្ពស់ការប្រើប្រាស់សេវានានារបស់រដ្ឋាភិបាលឌីជីថល និងសេវាផ្សេងៗទៀតដែលត្រូវបានផ្តល់តាមរយៈប្រព័ន្ធអ៊ីនធឺណិត។




**រូបភាពទី១២៖ យន្តការនៃការអភិវឌ្ឍកម្មវិធីសូហ្វវែរ**

### ៣.៥.២. យន្តការពង្រឹងសេវារដ្ឋបាលឌីជីថល

ជំរុញការរៀបចំ និងធ្វើឱ្យប្រសើរឡើងនូវសេវារដ្ឋបាលផ្ទៃក្នុង ដើម្បីឱ្យមានភាពសាមញ្ញ ងាយស្រួល និងបង្កើនប្រសិទ្ធភាពការងាររដ្ឋបាលរបស់ក្រសួង តាមរយៈការលើកកម្ពស់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការរបស់ស្ថាប័ន ការផ្លាស់ប្តូររបៀបរបបការងារពីឯកសារក្រដាសទៅជាការងារឯកសារអេឡិចត្រូនិក និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសការងារនៅតាមបណ្តាអង្គភាពនានា ដោយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ សកម្មភាពសំខាន់ៗ សម្រាប់ជំរុញឱ្យសម្រេចបាននូវវិធានការគោលនយោបាយនេះមានដូចជា៖

- រៀបចំ និងធ្វើឱ្យប្រសើរឡើងនូវថ្នាលសហការកិច្ចការរដ្ឋបាល ដើម្បីសម្រួលដល់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការការងារតាមរយៈការប្រើប្រាស់ប្រព័ន្ធគមនាគមន៍ប្រមូលផ្តុំ (អ៊ីម៉ែល ប្រព័ន្ធវីដេអូសន្និសីទ) ប្រព័ន្ធគ្រប់គ្រងក្រុមការងារ គ្រប់គ្រងគម្រោង និងគ្រប់គ្រងលំហូរការងារ ព្រមទាំងប្រព័ន្ធចែករំលែកឯកសារព័ត៌មាន និងចំណេះដឹង
- រៀបចំ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងរួមរបស់ក្រសួងដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងឯកសារអេឡិចត្រូនិក និងប្រព័ន្ធសច្ចានុម័តអេឡិចត្រូនិក សំដៅបង្កើនប្រសិទ្ធភាព និងតម្លាភាពការងាររដ្ឋបាលរបស់ស្ថាប័ន កាត់បន្ថយការចំណាយ និងលុបបំបាត់នូវការបង្កើតប្រព័ន្ធដដែលៗច្រើនដងដែលមានមុខងារជាន់គ្នា
- រៀបចំ និងបំពាក់ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ឌីជីថល សូហ្វវែរ និងប្រព័ន្ធព័ត៌មានចាំបាច់នានា ដើម្បីជួយសម្រួល និងលើកកម្ពស់ប្រសិទ្ធភាពការងារតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ។

### ៣.៥.៣. យន្តការធ្វើឱ្យប្រសើរឡើងនូវសេវាច្រកចេញ ចូលតែមួយសម្រាប់ប្រជាពលរដ្ឋ

ជំរុញការរៀបចំ និងធ្វើឱ្យប្រសើរឡើងនូវសេវាច្រកចេញចូលតែមួយសម្រាប់ប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព គុណភាព និងតម្លាភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងកាត់បន្ថយការចំណាយថវិកា និងពេលវេលាច្រើនតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងយន្តការសមស្របសម្រាប់ប្រមូលមតិយោបល់ និងការចូលរួមរបស់ប្រជាពលរដ្ឋ។ សកម្មភាពសំខាន់ៗសម្រាប់ជំរុញការរៀបចំសេវាច្រកចេញចូលតែមួយសម្រាប់ប្រជាពលរដ្ឋមានដូចជា៖

- រៀបចំថ្នាលសេវាច្រកចេញចូលតែមួយ សម្រាប់ផ្តល់សេវាសាធារណៈគ្រប់ក្រសួងស្ថាប័ន ព្រមទាំងការប្រមូលមតិយោបល់ និងទំនាក់ទំនងប្រជាពលរដ្ឋតាមប្រព័ន្ធឌីជីថល និងសេវាទូរស័ព្ទ
- រៀបចំ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្រានុកូលដ្ឋាន សម្រាប់ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការធ្វើសមកាលកម្ម (Synchronization) សម្រាប់ការចុះបញ្ជីសំបុត្រកំណើត លិខិតអាពាហ៍ពិពាហ៍ និងលិខិតមរណភាព
- រៀបចំ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានការស្នាក់នៅ និងគ្រួសារដើម្បីធានាបាននូវប្រសិទ្ធភាពដល់ការងារចុះបញ្ជី ការរក្សាទុក និងការស្វែងរកទិន្នន័យ ព្រមទាំងការផ្តល់សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារជូនប្រជាពលរដ្ឋ។




រូបភាពទី១៣៖ លំហូប្រព័ន្ធទិន្នន័យ API Gateway

## ៣.៦. យុទ្ធសាស្ត្រអភិបាលកិច្ចបច្ចេកវិទ្យា

ការគ្រប់គ្រងប្រព័ន្ធរដ្ឋាភិបាលឌីជីថល គឺជាកិច្ចការដ៏ចាំបាច់ដើម្បីធានាឱ្យមានប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលមួយប្រកបដោយគុណភាព ស័ក្តិសិទ្ធិភាព ស្របតាមតម្រូវការ ស្ថិតក្រោមការគ្រប់គ្រង និងភាពងាយស្រួលក្នុងការកែលម្អចំណុចខ្វះខាត។ អភិបាលកិច្ចបច្ចេកវិទ្យានឹងផ្តល់នូវផែនទីចង្អុលបង្ហាញផ្លូវស្តីពីគោលនយោបាយ បទដ្ឋាន គតិយុត្ត និងឯកសារពាក់ព័ន្ធផ្សេងៗនៅក្នុងលំហូរការងារ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។




រូបភាពទី១៤៖ វត្ថុបំណងនៃអភិបាលកិច្ចបច្ចេកវិទ្យា

### ៣.៦.១. យន្តការពង្រឹងក្របខ័ណ្ឌបទដ្ឋានគតិយុត្ត

- ពិនិត្យ និងលើកកម្ពស់ច្បាប់ ព្រមទាំងបទប្បញ្ញត្តិគតិយុត្តដែលមានស្រាប់ ដើម្បីជួយសម្រួលដល់ការប្រើប្រាស់យ៉ាងទូលំទូលាយនៃប្រព័ន្ធបច្ចេកវិទ្យា នៅក្នុងក្របខណ្ឌក្រសួងឱ្យស្របតាមស្តង់ដាតំបន់ និងអន្តរជាតិ
- បង្កើតស្តង់ដា និងគោលការណ៍ណែនាំឱ្យត្រូវគ្នានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅគ្រប់អង្គភាពទាំងអស់ចំណុះក្រសួង
- បង្កើតស្តង់ដា និងគោលការណ៍ណែនាំដើម្បីការពារបណ្តាញទំនាក់ទំនងអេឡិចត្រូនិកជាតិ រួមទាំងការទប់ស្កាត់ ការតាមរក និងការឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ព្រមទាំងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅក្នុងផ្លូវខុស
- បង្កើតតារាងម៉ាទ្រីសដើម្បីបង្កើនទំនុកចិត្ត និងភាពជឿជាក់ជូនអ្នកប្រើប្រាស់ ក៏ដូចជាដើម្បីការពារទាំងទិន្នន័យ និងសុវត្ថិភាពបណ្តាញ
- កំណត់របនាសម្ព័ន្ធស្តង់ដាសម្រាប់ក្រសួង និងអង្គភាពថ្នាក់ក្រោមជាតិដូចជា៖
  - ទីតាំងបង្ហោះទិន្នន័យ ដើម្បីកំណត់អត្តសញ្ញាណការប្រមូលផ្តុំទិន្នន័យ និងឯកសារទាំងអស់សម្រាប់ធ្វើការប្រមូលចូលមកក្នុងប្រទេសវិញ
  - កំណត់ស្តង់ដាមជ្ឈមណ្ឌលទិន្នន័យដែលមាន ២ធំៗ ស្របតាមបទដ្ឋានមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ
  - កំណត់ និងពង្រឹងគោលនយោបាយសន្តិសុខព័ត៌មានជាតិ ដើម្បីការពារប្រព័ន្ធបណ្តាញទិន្នន័យ និងប្រព័ន្ធបច្ចេកវិទ្យាទាំងឡាយពីការវាយប្រហារ និងការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត

- បង្កើត និងថែរក្សាផលប័ត្រនៃសេវាកម្ម និងទ្រព្យសម្បត្តិឌីជីថល ដែលជាមូលដ្ឋានសម្រាប់ធ្វើផែនការថវិកាឌីជីថលក្នុងពេលបច្ចុប្បន្ន និងគាំទ្រផែនការយុទ្ធសាស្រ្តនៃប្រព័ន្ធបច្ចេកវិទ្យានានានៅក្នុងក្រសួង។

- ធានាសុវត្ថិភាព និងលទ្ធភាពប្រើប្រាស់ទិន្នន័យដូចជា៖
  - កំណត់ចំណាត់ថ្នាក់ទិន្នន័យ ដែលរួមមាន Protected, Confidential, Internal, and Public
  - កំណត់តួនាទីម៉ាទ្រីសសម្រាប់ការចូលប្រើទិន្នន័យ
  - កំណត់កាលវិភាគដើម្បីពិនិត្យមើលការចូលប្រើទិន្នន័យ និងប្រព័ន្ធបណ្តោះអាសន្ន
  - បង្កើត និងធានាមូលដ្ឋានច្បាប់សម្រាប់ការទុកដាក់ឯកសារអេឡិចត្រូនិកដែលមិនសូវប្រើប្រាស់
  - ធ្វើស្តង់ដាការផ្លាស់ប្តូរទិន្នន័យរវាងអង្គភាពផ្សេងៗដែលក្រសួងមានទំនាក់ទំនងជាមួយ
  - ផ្សព្វផ្សាយការយល់ដឹងអំពីសុវត្ថិភាពប្រព័ន្ធដល់អ្នកប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាប្រចាំឆ្នាំ។

### ៣.៦.២. យន្តការអភិបាលកិច្ចបច្ចេកវិទ្យា

- ការត្រួតពិនិត្យឯករាជ្យនៃអភិបាលកិច្ចបច្ចេកវិទ្យា៖
  - បង្កើតក្រុមការងារតាមដាន និងត្រួតពិនិត្យកម្រិតផ្ទៃក្នុងអង្គភាពលើការប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងទិន្នន័យ
  - បង្កើតក្រុមការងារតាមដាន និងត្រួតពិនិត្យកម្រិតផ្ទៃក្នុងថ្នាក់ក្រសួងលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងទិន្នន័យ
  - កំណត់ដំណើរទស្សនកិច្ចអភិបាលកិច្ចដោយអង្គភាពខាងក្រៅ។
- ការគ្រប់គ្រងកិច្ចព្រមព្រៀងសេវាកម្ម៖
  - កំណត់កិច្ចសន្យាផ្តល់សេវាកម្ម (SLA) ជូនប្រជាពលរដ្ឋដោយផ្អែកលើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យា និងកិច្ចសន្យាផ្តល់សេវាកម្មពីក្រុមផ្ទៃក្នុងនៃអង្គភាពដើម្បីបម្រើដល់មន្រ្តីជួរមុខ
  - ត្រួតពិនិត្យគោលការណ៍ និងដំណើរការនៃការអនុវត្តការងារឱ្យស្របតាមបទដ្ឋាន។
- ធានាការបញ្ចូលប្រព័ន្ធបច្ចេកវិទ្យាថ្មីសំរាប់ប្រើប្រាស់ មិនឱ្យមានការប៉ះពាល់ដល់ប្រព័ន្ធប្រតិបត្តិការប្រចាំថ្ងៃ៖
  - ធានាបាននូវឯកសារគ្រប់គ្រាន់ សម្រាប់គ្រប់គម្រោងដាក់ឱ្យដំណើរការទាំងអស់ទៅកាន់ប្រព័ន្ធប្រតិបត្តិការប្រចាំថ្ងៃ
  - អនុវត្តគោលការណ៍ណែនាំ និងស្តង់ដាសម្រាប់ការត្រួតពិនិត្យគុណភាពប្រព័ន្ធបច្ចេកវិទ្យា និងការផ្តល់សេវា។
- ការគ្រប់គ្រងដំណើរការនៃប្រព័ន្ធបច្ចេកវិទ្យា៖

- កំណត់ការងារដោយដៃ នៅពេលដែលប្រព័ន្ធមិនអាចដំណើរការបាន
- កំណត់ផែនការបន្តដំណើរការនៃប្រព័ន្ធបណ្តោះអាសន្ន
- កំណត់ផែនការសង្គ្រោះគ្រោះមហន្តរាយនៃប្រព័ន្ធ
- អនុវត្តការហាត់សមលើប្រព័ន្ធសំខាន់ៗជារៀងរាល់ឆ្នាំ
- អនុវត្តការហាត់សមធ្វើការទាញយកទិន្នន័យពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ។




**រូបភាពទី១៥៖ យន្តការនៃការកសាងអភិបាលកិច្ចបច្ចេកវិទ្យាក្របខណ្ឌក្រសួងមហាផ្ទៃ**

### ៣.៦.៣. យន្តការតម្លើងអភិបាលកិច្ចបច្ចេកវិទ្យា

ការតម្លើងស្ថាបត្យកម្ម និងអភិបាលកិច្ចបច្ចេកវិទ្យា គឺជាកត្តាចម្បងសម្រាប់ការអភិវឌ្ឍវិស័យឌីជីថលប្រកបដោយចីរភាព និងសម្រេចបានតាមយុទ្ធសាស្ត្ររបស់អង្គភាព។ វដ្តនៃការតម្លើងអភិបាលកិច្ចបច្ចេកវិទ្យាមានចំនួន ៤ ដូចខាងក្រោម៖

- **ដំណាក់កាលរៀបចំ** ៖ ប្រមូលជាតុចូលពីគ្រប់គោលនយោបាយ បទដ្ឋាន គតិយុត្ត និងនីតិវិធីប្រតិបត្តិថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីរៀបចំ Framework និងផែនការលម្អិតនៃគម្រោងអភិវឌ្ឍអភិបាលកិច្ចបច្ចេកវិទ្យា
- **ដំណាក់កាលតម្លើង** ៖ ធ្វើការតម្លើងអភិបាលនូវកិច្ចបច្ចេកវិទ្យាដែលបានអនុម័តរួចរាល់នៅតាមបណ្តាអង្គភាពចំណុះក្រសួង
- **ដំណាក់កាលត្រួតពិនិត្យ** ៖ ពិនិត្យតាមដានការតម្លើង និងការប្រតិបត្តិ ដើម្បីស្វែងរកនូវចំណុចខ្លាំង និងចំណុចខ្សោយ
- **ដំណាក់កាលជួសជុល** ៖ ធ្វើការកែលម្អនូវចំណុចខ្វះខាត ដើម្បីជំរុញអភិបាលកិច្ចបច្ចេកវិទ្យាឱ្យកាន់តែប្រសើរឡើង ស្របតាមយុទ្ធសាស្ត្រឌីជីថលក្របខណ្ឌក្រសួងមហាផ្ទៃ ថ្នាក់ជាតិ និងតំបន់។




រូបភាពទី១៦៖ យន្តការនៃការកសាងអភិបាលកិច្ចបច្ចេកវិទ្យាក្របខណ្ឌក្រសួងមហាផ្ទៃ

## ៣.៦.៤. យន្តការត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន

ដើម្បីទទួលបានការប្រើប្រាស់ធនធានបច្ចេកវិទ្យាព័ត៌មានបានល្អបំផុត ចាំបាច់ត្រូវមានការវាយតម្លៃអំពីហានិភ័យនៃភាពបរាជ័យរបស់ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង លើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗរបស់ក្រសួងមហាផ្ទៃ។ ការវាយតម្លៃហានិភ័យផ្ទៃក្នុងនឹងក្រសោបយកសកម្មភាពដូចជា ការស្វែងយល់ពីប្រតិបត្តិការរបស់អង្គភាពផ្ទៃក្នុង និងការវាយតម្លៃហានិភ័យ។ ការត្រួតពិនិត្យផ្ទៃក្នុង និងវាយតម្លៃហានិភ័យរបស់អង្គភាពចំណុះក្រសួងលើចំណុចពាក់ព័ន្ធដូចខាងក្រោម៖

- **ហានិភ័យនៃការគ្រប់គ្រង៖** គំហើទាំបរិក្ខារ សុវត្ថិភាពនៃការគ្រប់គ្រង យន្តការនៃការត្រួតពិនិត្យជាប្រចាំ ការជួសជុល (Maintenance) រាល់ការខូចខាតនៃប្រព័ន្ធ ឬទិន្នន័យ និងធនធានមនុស្សសម្រាប់គាំទ្រកិច្ចដំណើរការ
- **ហានិភ័យហេដ្ឋារចនាសម្ព័ន្ធ៖** ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Hardware, Software, Network..) ពុំមានប្រសិទ្ធភាពដើម្បីជួយទ្រទ្រង់ដល់តម្រូវការបច្ចុប្បន្ន និងអនាគតនៃធុរកិច្ចប្រកបដោយស័ក្តិសិទ្ធិភាព ប្រសិទ្ធផល និងប្រព័ន្ធត្រួតពិនិត្យរឹងមាំ អំពីស្ថានភាពនៃការប្រើប្រាស់ (ភាពចាំបាច់ ភាពងាយស្រួល...) ព្រមទាំងការអភិវឌ្ឍបន្ត (Version Update)
- **ហានិភ័យការសម្ងាត់៖** ព័ត៌មាន (ទិន្នន័យ ឬកម្មវិធី) ដំណើរការក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវបានចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬបែកធ្លាយជាដើម និងការចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាដោយមិនបានទទួលសិទ្ធត្រឹមត្រូវ ឬសមស្រប ការការពារការជ្រៀតជ្រែកពីទិន្នន័យខាងក្រៅ (Data Injection) យន្តការសុវត្ថិភាពទិន្នន័យ (Firewall)...។
- **ហានិភ័យបូរណភាព៖** ពាក់ព័ន្ធនឹងការអនុញ្ញាត ភាពពេញលេញ និងភាពត្រឹមត្រូវនៃប្រតិបត្តិការនៅពេលបញ្ចូលព័ត៌មាន ដំណើរការ និងផលិតរបាយការណ៍ដោយកម្មវិធីស្រេចផ្សេងៗដែលប្រើប្រាស់ដោយអង្គភាព

- **ហានិភ័យលទ្ធភាពប្រើប្រាស់:** ព័ត៌មានមិនអាចប្រើប្រាស់បាននៅពេលមានតម្រូវការ
- **ការគ្រប់គ្រងហានិភ័យ:** យន្តការ ឬផែនការសម្រាប់គ្រប់គ្រង បញ្ចៀស និងបង្ការនូវបញ្ហាបាត់បង់ទិន្នន័យ (Backup, Warehouse...)។

### ៣.៦.៤.១. ប្រភេទនៃការត្រួតពិនិត្យផ្ទៃក្នុង

ជាការចាំបាច់ ការត្រួតពិនិត្យផ្ទៃក្នុងត្រូវមានកម្មវិធីរួមមួយដែលមានប្រភេទត្រួតពិនិត្យដូចខាងក្រោម៖

- **ការត្រួតពិនិត្យបែបធានារ៉ាប់រង:** ការត្រួតពិនិត្យដំណើរការផ្អែកលើហានិភ័យនីមួយៗស្លែងឡើងតាមការកំណត់គោលបំណងរបស់ប្រតិបត្តិការកំពុងធ្វើ ហានិភ័យពាក់ព័ន្ធ ការពិនិត្យវត្តមាននៃប្រព័ន្ធត្រួតពិនិត្យ និងបន្ទាប់មកគឺការធ្វើតេស្តប្រព័ន្ធត្រួតពិនិត្យ ដើម្បីធានាថាប្រព័ន្ធទាំងនេះត្រូវបានដាក់ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយហានិភ័យអំឡុងពេលប្រតិបត្តិការ និងពីលទ្ធភាពដែលអាចកើតមានឡើង
- **ការត្រួតពិនិត្យភាពអនុលោម:** ដើម្បីផ្តល់ការធានាបានថា គោលនយោបាយ និងនីតិវិធីនានាត្រូវបានគោរពតាម ហើយកម្មវិធីនៃការត្រួតពិនិត្យប្រព័ន្ធចាំបាច់ត្រូវបូកបន្ថែមនូវកម្មវិធីត្រួតពិនិត្យភាពអនុលោម។ ការយកចិត្តទុកដាក់នៃការត្រួតពិនិត្យភាពអនុលោម គឺជាការធ្វើតេស្តលម្អិតទៅលើសុចរិតភាពនៃយន្តការដែលកំពុងដំណើរការ
- **ការត្រួតពិនិត្យការតាមដាន:** ការត្រួតពិនិត្យនេះធ្វើបន្ថែមលើការត្រួតពិនិត្យប្រព័ន្ធ និងការត្រួតពិនិត្យភាពអនុលោម តាមរយៈការធ្វើតេស្តកម្រិតប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍ត្រួតពិនិត្យផ្ទៃក្នុងដែលបានផ្តល់ជូនកន្លងមក
- **ការត្រួតពិនិត្យវាយតម្លៃ:** ការត្រួតពិនិត្យលើភាពសមស្របចំពោះសកម្មភាពការងារ ដែលបានបង្កើតឡើងធៀបជាមួយនឹងបទពិសោធន៍ល្អៗ ប៉ុន្តែមិនមែនជាការត្រួតពិនិត្យអនុលោមភាពទេ។

### ៣.៦.៤.២. ការវាយតម្លៃគោលបំណងនៃការត្រួតពិនិត្យហានិភ័យគន្លឹះ

ការវាយតម្លៃប្រសិទ្ធភាពរួមរបស់ប្រព័ន្ធត្រួតពិនិត្យទាំងឡាយ ឱ្យត្រូវគោលបំណងនៃការត្រួតពិនិត្យហានិភ័យនឹងត្រូវរៀបចំឡើង។ ការវាយតម្លៃដែលផ្អែកតែលើការងារត្រួតពិនិត្យផ្ទៃក្នុងរួមមានដូចខាងក្រោម៖

- **ការធានាជាសារវន្ត:** មានន័យថា ការត្រួតពិនិត្យផ្ទៃក្នុងចាំបាច់ត្រូវតែមាន និងអាចធានានិរន្តរភាពព្រមទាំងទទួលបានសមិទ្ធផលខ្ពស់ចំពោះគោលបំណងគ្រប់គ្រង និងគោលបំណងរបស់អង្គភាព
- **ការធានាសមហេតុផល:** មានន័យថា មានបរិមាណត្រួតពិនិត្យផ្ទៃក្នុងសមស្រប តែមិនអាចដំណើរការប្រកបដោយប្រសិទ្ធភាពគ្រប់ពេលទាំងអស់នោះទេ
- **ការធានាមានកំណត់:** មានន័យថា ការត្រួតពិនិត្យដែលមានមិនគ្រប់គ្រាន់សម្រាប់ធានាឱ្យមាននិរន្តរភាព និងសមិទ្ធផលខ្ពស់ចំពោះគោលបំណងសម្រាប់ត្រួតពិនិត្យឡើយ
- **គ្មានការធានា:** មានន័យថា មូលដ្ឋានគ្រឹះនៃការត្រួតពិនិត្យផ្ទៃក្នុងនៅខ្សោយ ឬអវត្តមាន។

# ជំពូកទី៤

## យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល ២០២៣-២០២៧ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ និងប្រសិទ្ធផលច្រើនបំផុត ព្រមទាំងធានាបាននូវវឌ្ឍនភាពជាបន្តបន្ទាប់ ក្រសួងមហាផ្ទៃចាំបាច់ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដោយមានកំណត់នូវសូចនាករច្បាស់លាស់ដែលអាចវាស់វែងបាន។ ផ្អែកលើប្រព័ន្ធនេះ លេខាធិការដ្ឋាននៃក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវរៀបចំចេញជារបាយការណ៍តាមពេលវេលាដូចខាងក្រោម៖

- របាយការណ៍វាយតម្លៃ នៃការប្រៀបធៀបលទ្ធផលសម្រេចបានទៅនឹងសូចនាករដែលបានកំណត់ក្នុងគោលដៅនៃផែនការយុទ្ធសាស្ត្រ ត្រូវធ្វើពីរដងនៅក្នុងរយៈពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ គឺលើកទី១ រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ដើម្បីពិនិត្យវាយតម្លៃ និងលើកជាអនុសាសន៍សម្រាប់កែសម្រួលក្នុងករណីចាំបាច់ និងលើកទី២ រៀបចំរបាយការណ៍នៅឆ្នាំបញ្ចប់
- របាយការណ៍វឌ្ឍនភាពត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ជូនក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីមានវិធានការចាំបាច់ក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខ និងបន្តអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានជោគជ័យ និង
- របាយការណ៍វាយតម្លៃលើការអនុវត្តផែនការសកម្មភាពជាអាទិភាពនីមួយៗ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ។

### ៤.១. បច្ចេកទេសវិភាគ SWOT

ដើម្បីកំណត់បាននូវផែនការសកម្មភាព និងការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ យន្តការតាមដាន និងវាយតម្លៃ គឺជាកិច្ចការងារចាំបាច់បំផុត។ ក្នុងន័យនេះ ក្រុមការងារបច្ចេកទេសបានប្រើប្រាស់នូវយន្តការវិភាគ SWOT Analysis ធ្វើជាផែនទីចង្អុលបង្ហាញផ្លូវក្នុងការបន្តត្រួតពិនិត្យប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃផែនការនីមួយៗ និងគម្រោងទាំងឡាយដែលបានដាក់ឱ្យអនុវត្ត ហើយធ្វើការជួសជុសឱ្យបានទាន់ពេលវេលា។




រូបភាពទី១៧៖ យន្តការតាមដាន និងវាយតម្លៃ SWOT Analysis




រូបភាពទី១៨៖ យន្តការគ្រប់គ្រងគម្រោងបច្ចេកវិទ្យាឌីជីថល

## ៤.២. ការរៀបចំរបាយការណ៍

ជាសេនាធិការជូនក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ក.រ.ប.គ.ព) លេខាធិការដ្ឋានមានតួនាទី ត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពនានាដែលអង្គភាពក្រោមចំណុះក្រសួងមហាផ្ទៃអនុវត្ត។ ក្នុងនោះ អង្គភាពក្រោមចំណុះត្រូវធ្វើរបាយការណ៍អំពីវឌ្ឍនភាពការងារជារៀងរាល់ឆ្នាំដោយធ្វើការបង្ហាញ និងឆ្លុះបញ្ចាំងអំពី លទ្ធផលសម្រេចបាន បញ្ហាប្រឈម និងសំណូមពរមកកាន់លេខាធិការដ្ឋាន ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ព្រមទាំងថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងគោរពស្នើសុំមតិដឹកនាំបន្តលើការអនុវត្តគម្រោងនីមួយៗឆ្ពោះទៅរកភាពជោគជ័យ ដោយទទួលបាននូវប្រសិទ្ធភាពខ្ពស់ និងប្រសិទ្ធផលគួរជាទីពេញចិត្ត។

# ជំពូកទី៥

## ផែនការសកម្មភាព

| ល.រ | សកម្មភាពគន្លឹះ | លទ្ធផលរំពឹងទុក | ការបរិច្ឆេទ | អង្គភាព | ផ្សេងៗ |
|---|---|---|---|---|---|
| **១. យុទ្ធសាស្ត្របណ្តុះបណ្តាលធនធានមនុស្ស និងបញ្ជ្រាបចំណេះដឹង** | | | | | |
| ១.១ | រៀបចំគោលនយោបាយ បទដ្ឋានគតិយុត្ត លើកិច្ចការងារបណ្តុះបណ្តាល | សិក្សា និងចងក្រងឯកសារគោលនយោបាយ បទដ្ឋានគតិយុត្ត លើកិច្ចការងារបណ្តុះបណ្តាល ក្នុងនោះបទដ្ឋានសមត្ថភាពឌីជីថល "Digital Competency Standards for MoI" គឺជាឯកសារគោលនិងជាអាទិភាពត្រូវអនុវត្តសម្រាប់កម្មវិធីបណ្តុះបណ្តាលឌីជីថល នៅតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>ប.ន.ក<br>ស.ជ.រ.ម<br>ក្រ.ប្រ.ន | |
| ១.២ | រៀបចំយន្តការកម្មវិធីសិក្សាឌីជីថល សម្រាប់អង្គភាពចំណុះក្រសួងមហាផ្ទៃ | សិក្សា រៀបចំរចនាសម្ព័ន្ធបណ្តុះបណ្តាល រួមបញ្ចូល៖<br>-ការគ្រប់គ្រងសមាសភាពក្រុមការងារ មន្ត្រីជំនាញ និងគ្រូបង្គោល តាមអង្គភាពចំណុះក្រសួងមហាផ្ទៃ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)<br>-បញ្ជីសម្ភារៈ និងប្រព័ន្ធគ្រប់គ្រងបច្ចេកទេស កាលបរិច្ឆេទបណ្តុះបណ្តាល ឈ្មោះវគ្គ ការវាយតម្លៃលទ្ធផល និងកែលម្អវគ្គបណ្តុះបណ្តាលដោយផ្តោតលើបទដ្ឋានសមត្ថភាពឌីជីថល | ២០២៣-២០២៧ | ក.រ.ប.គ.ព<br>ប.ន.ក<br>ស.ជ.រ.ម | |
| ១.៣ | រៀបចំវគ្គបណ្តុះបណ្តាលកម្មវិធីបញ្ជ្រាបការយល់ដឹងនិងការអប់រំអំពីចំណេះដឹងមូលដ្ឋានបច្ចេកវិទ្យាឌីជីថលនិងការគ្រប់គ្រងសេវាសាធារណៈឌីជីថល | រៀបចំវគ្គបណ្តុះបណ្តាល កម្មវិធីបញ្ជ្រាបការយល់ដឹង និងការអប់រំអំពីចំណេះដឹងមូលដ្ឋានបច្ចេកវិទ្យាឌីជីថល និងការគ្រប់គ្រងសេវាសាធារណៈឌីជីថល ជូនដល់មន្ត្រីជំនាញបច្ចេកទេស ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ | ២០២៣-២០២៧ | ក.រ.ប.គ.ព<br>ប.ន.ក<br>ស.ជ.រ.ម | |
| ១.៤ | បណ្តុះបណ្តាលធនធានមនុស្ស លើជំនាញបច្ចេកវិទ្យាព័ត៌មាន និងជំនាញសន្តិសុខបច្ចេកវិទ្យាព័ត៌មានដល់មន្ត្រីជំនាញថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | មន្ត្រីនគរបាលជាតិទទួលបានជំនាញបច្ចេកវិទ្យាព័ត៌មាន និងការស្រាវជ្រាវបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបក្នុងការសម្របសម្រួលការងាររបស់អង្គភាព | ២០២៣-២០២៦ | ក.រ.ប.គ.ព<br>ប.ន.ក<br>ស.ជ.រ.ម | |

| ល.រ | សកម្មភាពគន្លឹះ | លទ្ធផលរំពឹងទុក | កាលបរិច្ឆេទ | អង្គភាព | ផ្សេងៗ |
|---|---|---|---|---|---|
| ១.៥ | ជម្រុញសកម្មភាពសិក្សា ស្រាវជ្រាវ និងនវានុវត្តន៍ បច្ចេកវិទ្យាឌីជីថល (RDI) | -បង្កើតឱ្យមានកម្មវិធីបណ្តុះបណ្តាល ជំនាញសិក្សា ស្រាវជ្រាវ និងនវានុវត្តន៍ (RDI) ដោយផ្តល់នូវយន្តការ ក៏ដូចជាបទដ្ឋានគោល ដើម្បីធ្វើបច្ចុប្បន្នភាពចំណេះដឹងមន្ត្រីជំនាញ គ្រូបង្គោល ក្នុងការជម្រុញឱ្យមានគំនិតបង្កើតថ្មី ក្នុងវិស័យបច្ចេកវិទ្យាឌីជីថល ដើម្បីបំពេញតម្រូវការកិច្ចការងារ និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ<br>-រៀបចំទស្សនៈកិច្ចសិក្សាឱ្យបានទៀងទាត់រយៈពេល ៣ខែម្តង ដើម្បីធ្វើបច្ចុប្បន្នភាពចំណេះដឹងមន្ត្រីជំនាញ គ្រូបង្គោល និងបំពេញបន្ថែមនូវចន្លោះខ្វះខាត | ២០២៣-២០២៧ | គ.រ.ប.គ.ព<br>ប.ន.ក<br>ស.ជ.រ.ម | |
| ១.៦ | បង្កើតនូវយន្តការកិច្ចសហប្រតិបត្តិការរវាងដៃគូពាក់ព័ន្ធដើម្បីពង្រឹងគុណភាព និងគាំទ្រដល់ការអនុវត្តផែនការបណ្តុះបណ្តាល | សិក្សា និងពិនិត្យលទ្ធភាពចុះអនុស្សារណៈជាមួយដៃគូរួមមាន ស្ថាប័នរដ្ឋាភិបាល វិទ្យាស្ថានឯកជន ដៃគូជាតិ និងអន្តរជាតិ ដើម្បីលើកស្ទួយប្រសិទ្ធភាព និងកម្មវិធីបណ្តុះបណ្តាល | ២០២៣-២០២៧ | គ.រ.ប.គ.ព<br>ប.ន.ក<br>ស.ជ.រ.ម | |
| **២. យុទ្ធសាស្ត្រកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាក្រសួងមហាផ្ទៃ** | | | | | |
| ២.១ | រៀបចំគោលនយោបាយ បទដ្ឋានគតិយុត្តលើវិស័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ក្រសួងមហាផ្ទៃ | សិក្សា និងចងក្រងឯកសារគោលនយោបាយ បទដ្ឋានគតិយុត្ត លើវិស័យហេដ្ឋារចនាសម្ព័ន្ធ ក្នុងនោះរួមមានគោលនយោបាយ និងបទដ្ឋានៈ អភិបាលកិច្ចបច្ចេកវិទ្យា លំហូរការងារ ការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យា អភិបាលកិច្ចទិន្នន័យ និងដាក់ឱ្យអនុវត្តនៅគ្រប់បណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ | ២០២៣-២០២៤ | គ.រ.ប.គ.ព<br>ក្រ.ប្រ.ន | |
| ២.២ | រៀបចំតភ្ជាប់បណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងព័ត៌មាន រវាងអង្គភាពចំណុះក្រសួងមហាផ្ទៃ | បណ្តាញតភ្ជាប់រួចរាល់សម្រាប់សមាហរណកម្មបច្ចេកវិទ្យា និងលំហូរទិន្នន័យរវាងអគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃ (ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិកម្រិតរាជធានី/ខេត្ត) | ២០២៣-២០២៤ | គ.រ.ប.គ.ព<br>អ.ល | |
| ២.៣ | តម្លើងមជ្ឈមណ្ឌលទិន្នន័យសម្រួលដល់ការធ្វើសមាហរណកម្មប្រព័ន្ធឌីជីថលក្របខណ្ឌក្រសួងមហាផ្ទៃ និងថ្នាក់ជាតិ | កសាងមជ្ឈមណ្ឌលទិន្នន័យកម្រិតក្រសួងមហាផ្ទៃ ដែលមានតួនាទីផ្តោតលើ API Gateway, Hosting, Backup, ប្រព័ន្ធផ្ទៀងផ្ទាត់អត្តសញ្ញាណ AIM និងតួនាទីមួយចំនួនទៀតបម្រើដល់បរិវត្តកម្មឌីជីថលក្រសួងមហាផ្ទៃ | ២០២៤ | គ.រ.ប.គ.ព<br>អ.ល | |

| ល.រ | សកម្មភាពគន្លឹះ | លទ្ធផលរំពឹងទុក | កាលបរិច្ឆេទ | អង្គភាព | ផ្សេងៗ |
|---|---|---|---|---|---|
| ២.៤ | តម្លើងមជ្ឈមណ្ឌលត្រួតពិនិត្យសន្តិសុខបច្ចេកវិទ្យា ដើម្បីធានាបាននូវដំណើរការរបស់ប្រព័ន្ធបច្ចេកវិទ្យា ប្រកបដោយសុវត្ថិភាព | កសាងប្រព័ន្ធត្រួតពិនិត្យកំណត់ត្រាប្រព័ន្ធ SIEM ដើម្បីតាមដានសន្តិសុខរបស់ប្រព័ន្ធបច្ចេកវិទ្យានានាពីការវាយប្រហារ ឬជ្រៀតចូលដោយខុសច្បាប់ | ២០២៤ | ក.រ.ប.គ.ព<br>អ.ល | |
| ២.៥ | តម្លើងប្រព័ន្ធ HelpDesk សម្រាប់គ្រប់គ្រងការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធ ICT | អភិវឌ្ឍ និងតម្លើងកម្មវិធី HelpDesk ដើម្បីគ្រប់គ្រង់សេវា ការសាកសួរ ការផ្តល់ប្រអប់សារ និងដំណោះស្រាយផ្សេងៗ | ២០២៤ | ក.រ.ប.គ.ព<br>អ.ល | |
| ២.៦ | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ជូនប្រជាពលរដ្ឋ | រៀបចំ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ជូនប្រជាពលរដ្ឋ ក្នុងនោះរួមមានទាំងការទំនាក់ទំនងរាយការណ៍ និងការផ្តល់សេវាសាធារណៈរបស់បណ្តាអង្គភាពចំណុះក្រសួង | ២០២៥-២០២៦ | ក.រ.ប.គ.ព<br>និងអង្គភាព<br>ចំណុះ<br>ក្រសួង<br>មហាផ្ទៃ | |
| **៣. យុទ្ធសាស្ត្រពង្រឹងសន្តិសុខ និងទប់ស្កាត់បទល្មើសបច្ចេកវិទ្យា (Cyber Security and Cybercrime)** | | | | | |
| ៣.១ | រៀបចំគោលនយោបាយបទដ្ឋានគតិយុត្ត គ្រប់គ្រងសន្តិសុខបច្ចេកវិទ្យា ក្របខណ្ឌក្រសួងមហាផ្ទៃ | សិក្សា និងចងក្រងឯកសារគោលនយោបាយ បទដ្ឋានគតិយុត្តលើវិស័យសន្តិសុខបច្ចេកវិទ្យា ក្នុងនោះរួមមានគោលនយោបាយ និងបទដ្ឋានដូចជាអភិបាលកិច្ចសន្តិសុខបច្ចេកវិទ្យា និងដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពចំណុះ | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>អ.ល<br>អ.ន.ប<br>ក្រ.ប្រ.ន | |
| ៣.២ | រៀបចំគោលនយោបាយនិងបទដ្ឋានគតិយុត្តស្តីពីកិច្ចគាំពារទិន្នន័យ | សិក្សា និងចងក្រងឯកសារគោលនយោបាយ បទដ្ឋានស្តីពីអភិបាលកិច្ចទិន្នន័យ កិច្ចគាំពារទិន្នន័យ ចំណាត់ថ្នាក់ទិន្នន័យ និងដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពចំណុះក្រសួងមហាផ្ទៃ (ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>អ.ល<br>អ.ន.ប<br>ក្រ.ប្រ.ន<br>អ.អ.ស<br>អ.អ | |
| ៣.៣ | រៀបចំគោលនយោបាយនិងបទដ្ឋានគតិយុត្ត លើកិច្ចការងារស្រាវជ្រាវ និងប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា | សិក្សា និងចងក្រងឯកសារគោលនយោបាយ បទដ្ឋានគតិយុត្តលើកិច្ចការងារស្រាវជ្រាវ និងប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីធានាបាននូវប្រសិទ្ធភាព និងដាក់ឱ្យអនុវត្តនៅតាមបណ្តាអង្គភាពពាក់ព័ន្ធ | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>អ.ល<br>អ.ន.ប<br>ក្រ.ប្រ.ន | |
| ៣.៤ | តម្លើង និងអនុវត្តបទដ្ឋានគ្រប់គ្រងប្រព័ន្ធសន្តិសុខព័ត៌មាន (Information Security Management System) | រៀបចំ និងអនុវត្តបទដ្ឋានគ្រប់គ្រងប្រព័ន្ធសន្តិសុខព័ត៌មាន អនុលោមតាមស្តង់ដារ CS ISO/IEC 2700:2021 ចេញដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ បទដ្ឋាននេះនឹងត្រូវដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពចំណុះ | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>និងអង្គភាព<br>ចំណុះ<br>ក្រសួង<br>មហាផ្ទៃ | |

| ល.រ | សកម្មភាពគន្លឹះ | លទ្ធផលរំពឹងទុក | ពេលបរិច្ឆេទ | អង្គភាព | ផ្សេងៗ |
|---|---|---|---|---|---|
| ៣.៥ | តម្លើងប្រព័ន្ធផ្ទៀងផ្ទាត់សារតា និងសុក្រិតភាពទិន្នន័យ សម្រាប់ការប្រើប្រាស់ និងលំហូរទិន្នន័យ | តម្លើងប្រព័ន្ធផ្ទៀងផ្ទាត់សារតា និងសុក្រិតភាពទិន្នន័យសម្រាប់ការប្រើប្រាស់ និងលំហូរទិន្នន័យ ដោយប្រើប្រាស់បទដ្ឋានហត្ថលេខាឌីជីថល | ២០២៣-២០២៧ | ក.រ.ប.គ.ព<br>អ.ល<br>អ.អ.ស | |
| ៣.៦ | បង្កើតយន្តការកិច្ចសហប្រតិបត្តិការរវាងដៃគូពាក់ព័ន្ធ ដើម្បីពង្រឹងគុណភាព និងគាំទ្រដល់កិច្ចការងារសន្តិសុខបច្ចេកវិទ្យា និងការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា | សិក្សា និងពិនិត្យលទ្ធភាពចុះអនុស្សារណៈជាមួយដៃគូនានារួមមាន ស្ថាប័នរបស់រដ្ឋាភិបាល ដៃគូជាតិ និងអន្តរជាតិ ដើម្បីលើកស្ទួយប្រសិទ្ធភាពការងារសន្តិសុខបច្ចេកវិទ្យា និងការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា | ២០២៣-២០២៧ | ក.រ.ប.គ.ព<br>អ.ល<br>អ.ន.ប | |
| **៤. យុទ្ធសាស្ត្រស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យា** | | | | | |
| ៤.១ | រៀបចំគោលនយោបាយស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យា (ICT Research Development and Innovation = RDI) | សិក្សា និងចងក្រងឯកសារគោលនយោបាយស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យា ក្របខណ្ឌក្រសួងមហាផ្ទៃ អនុលោមតាមគោលនយោបាយជាតិស្ដីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០២០-២០៣០ | ២០២៤ | ក.រ.ប.គ.ព<br>អ.ល<br>ប.ន.ក<br>ក្រ.ប្រ.ន | |
| ៤.២ | កសាងប្រព័ន្ធគ្រប់គ្រងស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍ (RDI) និងយន្តការផ្ដល់មូលនិធិ | បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍ ស្រាវជ្រាវបឋម ស្រាវជ្រាវអនុវត្តការអភិវឌ្ឍដោយពិសោធន៍ បង្កើតកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍ នៅតាមបណ្ដាអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ | ២០២៥-២០២៧ | ក.រ.ប.គ.ព<br>អគ្គនាយកដ្ឋានទាំង ១២ | |
| **៥. យុទ្ធសាស្ត្រពង្រឹងគុណភាពការងារ និងសេវាសាធារណៈ** | | | | | |
| ៥.១ | រៀបចំគោលនយោបាយគ្រប់គ្រងការផ្ដល់សេវារបស់ក្រសួងមហាផ្ទៃ ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ | សិក្សា និងចងក្រងឯកសារគោលនយោបាយ បទដ្ឋាន លើការផ្ដល់សេវាដើម្បីបង្កើននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ បទដ្ឋាននេះយកលំនាំពី ITIL និងអនុលោមតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ | ២០២៤ | ក.រ.ប.គ.ព<br>អ.ល<br>ក្រ.ប្រ.ន | |
| ៥.២ | រៀបចំបទដ្ឋាន និងយន្តការនៃការអភិវឌ្ឍកម្មវិធីសូហ្វវែរ | សិក្សា និងចងក្រងឯកសារបទដ្ឋាន និងយន្តការនៃការអភិវឌ្ឍកម្មវិធីសូហ្វវែរ និងដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពចំណុះ | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>អ.ល | |
| ៥.៣ | អភិវឌ្ឍ និងតម្លើងកម្មវិធី API បម្រើដល់សមាហរណកម្មប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យារវាងក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធ | អភិវឌ្ឍ និងតម្លើងកម្មវិធី API បម្រើដល់សមាហរណកម្មប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យារវាងក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធ។ API Gateway នឹងធ្វើការតភ្ជាប់ជាមួយប្រព័ន្ធរបស់បណ្ដាអគ្គនាយកដ្ឋានចំណុះ និងដើរតួនាទីតភ្ជាប់បន្តទៅកាន់ក្រសួងស្ថាប័នថ្នាក់ជាតិនានា ក្នុងនោះរួមមានការតភ្ជាប់ជាមួយ CamDx និងសេវាច្រកចេញចូលតែមួយផងដែរ | ២០២៣-២០២៧ | ក.រ.ប.គ.ព<br>អ.ល | |

| ល.រ | សកម្មភាពគន្លឹះ | លទ្ធផលរំពឹងទុក | កាលបរិច្ឆេទ | អង្គភាព |ផ្សេងៗ |
|---|---|---|---|---|---|
| ៥.៤ | រៀបចំ និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្តសញ្ញាណកម្ម | ធ្វើការពិនិត្យ វាយតម្លៃ និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្តសញ្ញាណកម្ម ដើម្បីធានាបាននូវប្រសិទ្ធភាព ការតភ្ជាប់ និងគុណភាពក្នុងការផ្តល់សេវាសាធារណៈ | ២០២៤ | ក.រ.ប.គ.ព<br>អ.អ.ស | |
| ៥.៥ | រៀបចំ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្រានុកូលដ្ឋាន | ធ្វើការពិនិត្យ វាយតម្លៃ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្រានុកូលដ្ឋាន ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការតភ្ជាប់ និងគុណភាពក្នុងការផ្តល់សេវាសាធារណៈ | ២០២៤ | ក.រ.ប.គ.ព<br>អ.អ.ស | |
| ៥.៦ | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានជនអន្តោប្រវេសន៍ និងប្រព័ន្ធគ្រប់គ្រងទិដ្ឋាការ | ធ្វើការពិនិត្យ វាយតម្លៃ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានជនអន្តោប្រវេសន៍ និងប្រព័ន្ធគ្រប់គ្រងទិដ្ឋាការ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការតភ្ជាប់ និងគុណភាពក្នុងការផ្តល់សេវាសាធារណៈ | ២០២៤ | ក.រ.ប.គ.ព<br>អ.អ | |
| ៥.៧ | ពង្រឹងហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារទូទាត់សងប្រាក់សម្រាប់សេវាសាធារណៈក្របខណ្ឌក្រសួងមហាផ្ទៃ | ពិនិត្យ តម្លើង តភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារទូទាត់សងប្រាក់សម្រាប់សេវាសាធារណៈក្របខណ្ឌក្រសួងមហាផ្ទៃ | ២០២៥-២០២៦ | ក.រ.ប.គ.ព<br>ភ.ហ.រ | |
| ៥.៨ | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក | ធ្វើការពិនិត្យ វាយតម្លៃ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>អ.រ.ប | |
| ៥.៩ | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្សព្វផ្សាយ ប្រព័ន្ធតាមដាន ប្រមូល វិភាគព័ត៌មាន និងឆ្លើយតប | ធ្វើការពង្រឹងសមត្ថភាព និងតម្លើងប្រព័ន្ធផ្សព្វផ្សាយ តាមដាន ប្រមូល វិភាគព័ត៌មាន និងឆ្លើយតប ក្របខណ្ឌក្រសួងមហាផ្ទៃ | ២០២៣-២០២៧ | ក.រ.ប.គ.ព<br>និងអង្គភាពចំណុះក្រសួងមហាផ្ទៃ | |
| ៥.១០ | បំពាក់បំប៉នមន្ត្រីបច្ចេកទេសលើការអភិវឌ្ឍកម្មវិធីសូហ្វវែរបម្រើដល់ប្រព័ន្ធផ្តល់សេវាសាធារណៈសម្រាប់អង្គភាពចំណុះក្រសួងមហាផ្ទៃ | បំពាក់បំប៉នមន្ត្រីបច្ចេកទេសអំពីចំណេះដឹងកម្រិតខ្ពស់ក្នុងការអភិវឌ្ឍកម្មវិធីសូហ្វវែរ ដូចជាកម្មវិធី Desktop Web Mobile API និង Webservice ជាដើម | ២០២៣-២០២៧ | ក.រ.ប.គ.ព<br>ប.ស.ន.ប | |
| ៥.១១ | សិក្សា និងអនុវត្តគម្រោងទីក្រុងឆ្លាតវៃ នៅតាមបណ្តារាជធានី/ខេត្ត | រាជធានី/ខេត្ត នៃព្រះរាជាណាចក្រកម្ពុជានឹងប្រែក្លាយទៅជាទីក្រុង ដែលមានបរិស្ថានល្អ និងអាចធ្វើឱ្យកម្រិតជីវភាពរស់នៅរបស់ប្រជាជនក្នុងស្រុកកាន់តែមានភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរណ៍ | ២០២៣-២០២៧ | ក.រ.ប.គ.ព<br>អ.រ.ប | |

| ល.រ | សកម្មភាពគន្លឹះ | លទ្ធផលរំពឹងទុក | កាលបរិច្ឆេទ | អង្គភាព | ផ្សេងៗ |
|---|---|---|---|---|---|
| **៦. យុទ្ធសាស្ត្រអភិបាលកិច្ចបច្ចេកវិទ្យា** | | | | | |
| ៦.១ | រៀបចំគោលនយោបាយ បទដ្ឋានគតិយុត្ត គ្រប់គ្រងវិស័យបច្ចេកវិទ្យា ក្របខណ្ឌក្រសួងមហាផ្ទៃ | សិក្សា និងចងក្រងឯកសារគោលនយោបាយ បទដ្ឋានគតិយុត្តវិស័យបច្ចេកវិទ្យាយកលំនាំ COBIT 2019 Framework និងដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពចំណុះក្រសួង | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>អ.ល<br>ក្រ.ប្រ.ន | |
| ៦.២ | បង្កើតយន្តការ និងនីតិវិធីក្នុងការធ្វើអភិបាលកិច្ចប្រព័ន្ធបច្ចេកវិទ្យា ក្របខណ្ឌក្រសួងមហាផ្ទៃ | សិក្សា និងចងក្រងឯកសារគោលនយោបាយ បទដ្ឋានគតិយុត្ត និងនីតិវិធីអភិបាលកិច្ចប្រព័ន្ធបច្ចេកវិទ្យា និងដាក់ឱ្យអនុវត្តក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>អ.ល<br>ក្រ.ប្រ.ន<br>ស.ផ.ក | |
| ៦.៣ | បង្កើតនូវបទដ្ឋានឧបករណ៍បច្ចេកទេស និងកម្មវិធីសូហ្វវែរ | សិក្សា និងចងក្រងឯកសារគោលនយោបាយ បទដ្ឋានឧបករណ៍បច្ចេកទេស និងកម្មវិធីសូហ្វវែរ ក្របខណ្ឌក្រសួងមហាផ្ទៃ | ២០២៣-២០២៤ | ក.រ.ប.គ.ព<br>អ.ល | |
| ៦.៤ | ពិនិត្យ និងវាយតម្លៃការអនុវត្តលើយន្តការគោលនយោបាយ និងបទដ្ឋាននានាពាក់ព័ន្ធនឹងបច្ចេកវិទ្យា | ចុះពិនិត្យ និងវាយតម្លៃការអនុវត្តលើយន្តការគោលនយោបាយ និងបទដ្ឋាននានាពាក់ព័ន្ធនឹងបច្ចេកវិទ្យានៅតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ | ២០២៤-២០២៧ | ក.រ.ប.គ.ព<br>អ.ល | |

# ឧបសម្ព័ន្ធទី១៖ បច្ចុប្បន្នភាពប្រព័ន្ធបច្ចេកវិទ្យារបស់អគ្គនាយកដ្ឋាន
# ចំណុះក្រសួងមហាផ្ទៃ ឆ្នាំ២០២២

❖ **អគ្គលេខាធិការដ្ឋាន**

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ | On-Premise | កំពុងប្រើ |
| ០២ | ប្រព័ន្ធគ្រប់គ្រងឯកសារអេឡិចត្រូនិក (DMS) | On-Premise | កំពុងប្រើ |

➢ **តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់**

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | EZECOM, SINET, MPTC (នាយកដ្ឋានព័ត៌មានវិទ្យា) | ៥២០ Mbps | |
| ០២ | នាយកដ្ឋានកិច្ចការរដ្ឋបាល<br>(ប្រើប្រាស់អ៊ីនធើណេតរបស់អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ) | ២០ Mbps | |
| ០៣ | លេខាធិការដ្ឋានកិច្ចការទីប្រឹក្សា និងជំនួយការ<br>(ប្រើប្រាស់អ៊ីនធើណេតរបស់អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ) | ៥ Mbps | |
| ០៤ | នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ<br>(ប្រើប្រាស់អ៊ីនធើណេតរបស់អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ) | មិនមានទិន្នន័យ | |

❖ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ | មិនមានទិន្នន័យ | កំពុងប្រើ |
| ០២ | ប្រព័ន្ធគ្រប់គ្រងការងាររដ្ឋបាល (លិខិតចូល-ចេញ-កំណត់បង្ហាញ)<br>សេនាធិការដ្ឋាន | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៣ | ប្រព័ន្ធគ្រប់គ្រងបណ្ណសារដ្ឋាន | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៤ | ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណមន្ត្រីអង្គរក្ស | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៥ | ប្រព័ន្ធគ្រប់គ្រងបុគ្គលិក (សេនាធិការដ្ឋាន) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៦ | ប្រព័ន្ធគ្រប់គ្រងផ្លាកលេខយានយន្តនគរបាល | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៧ | ប្រព័ន្ធគ្រប់គ្រងផ្លាកលេខយានយន្តស៊ីវិល | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៨ | ប្រព័ន្ធត្រួតពិនិត្យយានយន្តល្មើសល្បឿន | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៩ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ | មិនមានទិន្នន័យ | កំពុងប្រើ |
| ១០ | ប្រព័ន្ធគ្រប់គ្រងបទល្មើសគ្រឿងញៀន | មិនមានទិន្នន័យ | កំពុងប្រើ |
| ១១ | ប្រព័ន្ធគ្រប់គ្រងបណ្ណសារដ្ឋានបទល្មើស | មិនមានទិន្នន័យ | កំពុងប្រើ |
| ១២ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ផាកពិន័យអន្តរកាល និងដកពិន្ទុ | មិនមានទិន្នន័យ | កំពុងប្រើ |
| ១៣ | ប្រព័ន្ធគ្រប់គ្រងបុគ្គលិកសន្តិសុខឯកជន | មិនមានទិន្នន័យ | កំពុងប្រើ |
| ១៤ | កម្មវិធីអន្តរាគមន៍របស់នគបាល | មិនមានទិន្នន័យ | កំពុងអភិវឌ្ឍន៍ |

➢ **តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់**

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | SI NET (ISP) | ៥០ Mbps | |
| ០២ | Metfone | ២៥ Mbps | |

❖ **អគ្គនាយកដ្ឋានរដ្ឋបាល**

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រព័ន្ធរក្សាទុកទិន្នន័យនាយកដ្ឋាន DoPa (ប្រើប្រាស់ផ្ទៃក្នុង ) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០២ | កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយ រាជធានី ខេត្ត | ម៉ាស៊ីនមេ (Server) របស់លេខាធិការដ្ឋាន គ.ជ.អ.ប | កំពុងប្រើ |
| ០៣ | Mobile App ឈ្មោះ OWSM Cambodia (Android, IOS) សម្រាប់ប្រជាពលរដ្ឋតាមដានចរន្តឯកសារការស្នើសុំសេវារបស់ខ្លួន | ម៉ាស៊ីនមេ (Server) របស់លេខាធិការដ្ឋាន គ.ជ.អ.ប | កំពុងប្រើ |
| ០៤ | ប្រព័ន្ធទូទាត់ថ្លៃសេវាតាមម៉ាស៊ីន KIOSK | ម៉ាស៊ីនមេ (Server) របស់លេខាធិការដ្ឋាន គ.ជ.អ.ប | កំពុងសាកល្បង |
| ០៥ | កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ | ម៉ាស៊ីនមេ (Server) របស់លេខាធិការដ្ឋាន គ.ជ.អ.ប | កំពុងប្រើ |
| ០៦ | ប្រព័ន្ធស្នើសុំ និងផ្តល់សេវាអនឡាញ ( Online ) | ម៉ាស៊ីនមេ (Server) របស់លេខាធិការដ្ឋាន គ.ជ.អ.ប | កំពុងកែសម្រួល |

➢ **តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់**

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | YCAM | ១០ Mbps | |
| ០២ | ទូរគមនាគមន៍កម្ពុជា Cam Net | ៥០ MB / ៥០ MB | |

❖ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រព័ន្ធគ្រប់គ្រងព្រំដែនកម្ពុជា (Personal Identification Secure Comparison and Evaluation System - PISCES) | On-Premise | កំពុងប្រើ |
| ០២ | ប្រព័ន្ធគ្រប់គ្រងព្រំដែនកម្ពុជា (Cambodia Border Management System - CBMS) | On-Premise | កំពុងប្រើ |
| ០៣ | ប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា (FPCS) | - On cloud (Database/Hosting)<br>- On-Premise (Backup Database) | កំពុងប្រើ |
| ០៤ | ប្រព័ន្ធទិន្នន័យបញ្ជីមុខសញ្ញា ( ALS ) | On-Premise | កំពុងប្រើ |
| ០៥ | ប្រព័ន្ធទិន្នន័យទិដ្ឋាការពេលមកដល់ (VOA) | On-Premise | កំពុងប្រើ |
| ០៦ | ប្រព័ន្ធទិន្នន័យពន្យារទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន (VES) | On-Premise | កំពុងប្រើ |
| ០៧ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនបរទេសអន្តោប្រវេសន៍ (IMS) | On-Premise | កំពុងប្រើ |

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០៨ | ប្រព័ន្ធគ្រប់គ្រងអ្នកដំណើរចេញ-ចូល ច្រកទ្វារភាគីនិងតំបន់ (Bilateral and Local Traveller Management System - BLTMS) | On-Cloud | កំពុងប្រើ |
| ០៩ | ប្រព័ន្ធគ្រប់គ្រងការងារអធិការកិច្ចពលករបរទេស ឬហត្ថពលកម្មបរទេស (Foreign Labor Inspection System - FLIS) | On-Cloud | កំពុងប្រើ |
| ១០ | ប្រព័ន្ធទិន្នន័យអ្នកដំណើរមុនពេលមកដល់ (Cambodia Arrival Card - CamAC) | - On-Premise (Sync Data from Cloud)<br>- On-Cloud (Hosting) | អភិវឌ្ឍន៍រួចរាល់ |
| ១១ | ប្រព័ន្ធគ្រប់គ្រងឯកសារឌីជីថល (Digital Document Management System - e-Doc) | On-Cloud | អភិវឌ្ឍន៍រួចរាល់ |
| ១២ | ប្រព័ន្ធគ្រប់គ្រងមណ្ឌលត្រៀមបណ្តេញចេញ (RCMS ) | - On cloud (Database/Hosting)<br>- On-Premise (Backup Database) | កំពុងអភិវឌ្ឍន៍ |
| ១៣ | ប្រព័ន្ធមជ្ឈមណ្ឌលកណ្តាលអន្តោប្រវេសន៍ ( IDAS ) | On-Premise | កំពុងអភិវឌ្ឍន៍ |
| ១៤ | ប្រព័ន្ធព័ត៌មានអ្នកដំណើរមុនពេលមកដល់ (Advance Passenger information System - APIS) | មិនមានទិន្នន័យ | ត្រៀមអភិវឌ្ឍន៍ |

➢ **តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់**

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | SI Net សម្រាប់ការងារការិយាល័យ | ៨០ Mbps | |
| ០២ | EZECOM ISP សម្រាប់ការិយាល័យកណ្តាល (HQ) | ១០០ Mbps | |
| ០៣ | EZECOM ISP បណ្តាច្រកទ្វារអន្តរជាតិនីមួយៗ | ១០ Mbps | |

❖ **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលអត្តសញ្ញាណកម្ម (Mobile Web ) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០២ | ប្រព័ន្ធព័ត៌មានអត្តសញ្ញាណកម្ម ( Mobile Web ) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៣ | ប្រព័ន្ធសេវាកម្មអត្តសញ្ញាណកម្ម ( Mobile Web ) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៤ | ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ( Web ) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៥ | ប្រព័ន្ធស្នូលអត្តសញ្ញាណកម្ម (Web ) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៦ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យសញ្ជាតិ ( Web ) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៧ | ប្រព័ន្ធគ្រប់គ្រងជនមាតុភូមិនិវត្តន៍ ( Window Application ) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៨ | ប្រព័ន្ធស្វែងរកព័ត៌មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ( Web ) | មិនមានទិន្នន័យ | កំពុងប្រើ |
| ០៩ | ប្រព័ន្ធបោះពុម្ពលិខិតធ្វើដំណើរសម្រាប់ពលករខ្មែរទៅធ្វើការនៅបរទេស (Web) | មិនមានទិន្នន័យ | កំពុងប្រើ |
| ១០ | ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅថ្នាក់ឃុំ/សង្កាត់ (Web) | មិនមានទិន្នន័យ | កំពុងប្រើ |
| ១១ | ប្រព័ន្ធស្វែងរកព័ត៌មានជនអន្តោប្រវេសន៍ វៀតណាម ICS (Web) | មិនមានទិន្នន័យ | កំពុងប្រើ |

➢ តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | EZECOM និង WICAM | ១៣០ Mbps | |

❖ **អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងហិរញ្ញវត្ថុ**

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រព័ន្ធគ្រប់គ្រងបុគ្គលិក (Web Application) | Pc, Peer to Peer Network | កំពុងប្រើ |
| ០២ | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ( FMIS ) | Pc, Peer to Peer Network | កំពុងប្រើ |
| ០៣ | តេឡេក្រាម ( Telegram App ) | Pc, Peer to Peer Network | កំពុងប្រើ |
| ០៤ | ប្រព័ន្ធគ្រប់គ្រងលិខិតរដ្ឋបាល | Pc, Peer to Peer Network | កំពុងប្រើ |
| ០៥ | ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ( SARMIS ) | Pc, Peer to Peer Network | កំពុងប្រើ |
| ០៦ | ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ( NRMIS ) | Pc, Peer to Peer Network | កំពុងប្រើ |
| ០៧ | ប្រព័ន្ធសូហ្វវែរ (Application Systems) កម្មវិធីស្រាវជ្រាវសម្ភារបច្ចេកទេស | មិនមានទិន្នន័យ | គ្រោងបង្កើត |
| ០៨ | ប្រព័ន្ធរក្សាទុកទិន្នន័យ ( Data Center / Sever Room ) | មិនមានទិន្នន័យ | គ្រោងបង្កើត |

➢ តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | ទូរគមនាគមន៍ (ន.ដ្ឋានរដ្ឋបាលរដ្ឋបាលសរុប) | ១០ Mbps | |
| ០២ | ទូរគមនាគមន៍ (ន.ផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្នែកសន្តិសុខសាធារណៈ) | ៣០ Mbps | |
| ០៣ | ទូរគមនាគមន៍ (ន.ផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្នែករដ្ឋបាលទូទៅ) | ២៩ Mbps | |
| ០៤ | សេវាទូរស័ព្ទផ្ទាល់ខ្លួន (ន.ភស្តុភារ និងសម្ភារបច្ចេកទេស) | ពុំបានបញ្ជាក់ | |
| ០៥ | OPEN NET (នាយកដ្ឋានផ្សព្វផ្សាយអប់រំ) | ៣០ Mbps | |
| ០៦ | EZECOM (នាយកដ្ឋានសុខាភិបាល) | ៥ Mbps | |
| ០៧ | ទូរគមនាគមន៍ (នាយកដ្ឋានស្ថាបនា និងវិស្វកម្ម) | ២០ Mbps | |
| ០៨ | SMART (នាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារបច្ចេកទេស) | ៦ Mbps | |
| ០៩ | ស្ថានីយវិទ្យុ និងទូរទស្សន៍មហាផ្ទៃ | ១៦០ Mbps | |

❖ **អគ្គនាយកដ្ឋានពន្ធនាគារ**

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ការបញ្ជូនឯកសារតាមប្រព័ន្ធតេលេក្រាម ( Telegram ) | On-Cloud | កំពុងប្រើ |
| ០២ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីពន្ធនាគារ | On-Cloud (Database/Hosting) | កំពុងប្រើ |
| ០៣ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនជាប់ឃុំ | On-Cloud (Database/Hosting) | កំពុងប្រើ |
| ០៤ | ប្រព័ន្ធគ្រប់គ្រប់គ្រងទិន្នន័យភស្តុភា និងហិរញ្ញវត្ថុ ( MIS ) | មិនមានទិន្នន័យ | ត្រៀមបង្កើត |

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០៥ | ប្រព័ន្ធ Video Conference | មិនមានទិន្នន័យ | ត្រៀមបង្កើត |
| ០៦ | ប្រព័ន្ធគ្រប់គ្រងចរន្តឯកសាររដ្ឋបាល | មិនមានទិន្នន័យ | កំពុងស្នើសុំ |
| ០៧ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំកែប្រែជនជាប់ឃុំ | Offline Tablet | កំពុងបង្កើត |
| ០៨ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តុះបណ្តាលទណ្ឌិត | On-Cloud ( Database/Hosting ) | កំពុងស្នើសុំ |

➢ តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | OPENNET | ១០ Mbps | |

❖ **បណ្ឌិត្យសភាននគរបាលកម្ពុជា**

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រព័ន្ធសិក្សាឌីជីថល | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |
| ០២ | ប្រព័ន្ធគ្រប់គ្រងគ្រូនគរបាលជាតិ | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |
| ០៣ | ប្រព័ន្ធគ្រប់គ្រងអ្នកសិក្សា | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |
| ០៤ | ប្រព័ន្ធគ្រប់គ្រងមន្ត្រីនគរបាលនៃបណ្ឌិត្យសភានគរបាល | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |
| ០៥ | ប្រព័ន្ធគ្រប់គ្រងកម្មវិធីអប់រំ | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |
| ០៦ | ប្រព័ន្ធគ្រប់គ្រងការផ្តល់សេវា | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |
| ០៧ | មជ្ឈមណ្ឌលទិន្នន័យ | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |
| ០៨ | ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសន្តិសុខបច្ចេកវិទ្យា | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |
| ០៩ | ប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |
| ១០ | ប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ | ម៉ាស៊ីនមេ ប.ន.ក ( Server ) | កំពុងរៀបផែនការឌីជីថល |

➢ តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | EZECOM និង Metfone | ៦០ Mbps | |

❖ **អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង**

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រព័ន្ធគ្រប់គ្រងលិខិតរដ្ឋបាល | ពុំបានបញ្ជាក់ | គ្រោងបង្កើត |

➢ តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | ទូរគមនាគមន៍កម្ពុជា | ១០ Mb | |

❖ ក្រុមប្រឹក្សានីតិកម្ម

➢ តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រើប្រាស់សេវាអ៊ីនធឺណិត ទូរស័ព្ទ ( Mobile Hotspot ) SMART | ៤ - ៤.៥ G | |
| ០២ | ប្រើប្រាស់សេវាអ៊ីនធឺណិត ទូរស័ព្ទ ( Mobile Hotspot ) CELLCARD | ៤ - ៤.៥ G | |

❖ អគ្គាធិការដ្ឋាន

➢ តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រើប្រាស់សេវាអ៊ីនធឺណិត ទូរស័ព្ទ ( Mobile Hotspot ) SMART | ប្រហែល ៥ - ១០ Mbps | |

❖ សាលាជាតិរដ្ឋបាលមូលដ្ឋាន

| ល.រ | ឈ្មោះប្រព័ន្ធ | ទីតាំងផ្ទុកប្រព័ន្ធ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រព័ន្ធគ្រប់គ្រងឯកសារ Notion (ផ្ទៃក្នុង) | Free Cloud Server | កំពុងប្រើ |
| ០២ | ប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាល | On-Cloud | កំពុងសាកល្បង |
| ០៣ | ការចុះឈ្មោះសិក្ខាកាម (Google Form) | On-Cloud | កំពុងប្រើ |
| ០៤ | តេឡេក្រាម ( Telegram App ) | Pc, Peer to Peer Network | កំពុងប្រើ |
| ០៥ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យអភិបាលកិច្ចមូលដ្ឋាន | ម៉ាស៊ីនមេក្រសួងមហាផ្ទៃ | គ្រោងរៀបចំ |
| ០៦ | ប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ | ម៉ាស៊ីនមេក្រសួងមហាផ្ទៃ | គ្រោងរៀបចំ |
| ០៧ | Digital Platform សម្រាប់ការបណ្តុះបណ្តាល | ម៉ាស៊ីនមេក្រសួងមហាផ្ទៃ | គ្រោងរៀបចំ |
| ០៨ | ប្រព័ន្ធគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ | ម៉ាស៊ីនមេក្រសួងមហាផ្ទៃ | គ្រោងរៀបចំ |
| ០៩ | ប្រព័ន្ធគ្រប់គ្រងការងារសិក្សា | ម៉ាស៊ីនមេក្រសួងមហាផ្ទៃ | គ្រោងរៀបចំ |
| ១០ | មជ្ឈមណ្ឌលព័ត៌មានវិទ្យា និងរក្សាទុកទិន្នន័យ | ម៉ាស៊ីនមេក្រសួងមហាផ្ទៃ | គ្រោងរៀបចំ |

➢ តារាងសេវាកម្មអ៊ីនធឺណិតដែលអង្គភាពប្រើប្រាស់

| ល.រ | ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត | ទំហំប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|
| ០១ | ប្រើប្រាស់សេវាអ៊ីនធឺណិតមេគង្គណេត | 30 Mbps | កំពុងប្រើ |
| ០២ | ទូរគមនាគមន៍កម្ពុជា | ៨ Mbps | មិនដំណើការ |

# ឧបសម្ព័ន្ធទី២៖ សេចក្ដីសម្រេច ស្ដីពីការបង្កើតក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ ១៦៤៦ ស.ស.រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សេចក្ដីសម្រេច**

**ស្ដីពី**

**ការបង្កើតក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

**សម្រេច**

**ប្រការ១ ._**

ត្រូវបានបង្កើត ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្ដម | **សក់ សេដ្ឋា** | រដ្ឋលេខាធិការប្រចាំការ | ប្រធាន |
| ២. | ឯកឧត្ដម | **ហ៊ុយ ឲណ្ណៈ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្ដម នាយឧត្ដមសេនីយ៍ | **ឆោំ ឥទ្ធិ** | អគ្គលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |

១

៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហោ សំអាត** អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា សមាជិក

៥. ឯកឧត្តម **ឆាន់ ចន្ទសុភក្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

៦. ឯកឧត្តម ឧត្តមសេនីយ៍ឯក **លឹម ផាន់សារៈ** អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ សមាជិក

៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក **សុខ ឆាសនា** អគ្គនាយករង និងជាប្រធាននាយកដ្ឋានជនបរទេសមិនមែនអន្តោប្រវេសន៍និងបច្ចេកវិទ្យា នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សមាជិក

៨. ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ **សោ ពន្លក** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារ សមាជិក

៩. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឆន ឡាឌី** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន សមាជិក

១០. ឯកឧត្តម ឧត្តមសេនីយ៍ទោ **អ៊ុកខាយ បញ្ញារ៉ា** អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិក

១១. ឯកឧត្តម **ហួច លេងឌីន** អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក

១២. លោកឧត្តមសេនីយ៍ត្រី **ឈុន ធណ្ណា** ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា-នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិក

១៣. លោកឧត្តមសេនីយ៍ទោ **ហាយ មករា** អនុប្រធាននាយកដ្ឋានស៊ើបការណ៍ខាងក្រៅ និងបច្ចេកទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៤. លោកឧត្តមសេនីយ៍ត្រី **ស៊ុយ ឈីម** នាយករងវិទ្យាស្ថានព័ត៌មានវិទ្យានិងភាសាបរទេស-នៃបណ្ឌិត្យសភានគរបាលកម្ពុជា សមាជិក

១៥. លោកវរសេនីយ៍ឯក **ងំ ធីណា** សមាជិកក្រុមប្រឹក្សានីតិកម្ម សមាជិក

**ប្រការ២ ._**

ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ លើការងាររដ្ឋាភិបាលឌីជីថលក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងគ្រប់គ្រងគម្រោងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៅតាមបណ្តាអគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួង
- សហការជាមួយដៃគូពាក់ព័ន្ធ ទីប្រឹក្សា និងអ្នកជំនាញតាមការចាំបាច់ ដើម្បីរៀបចំកសាងផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងការបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពធនធានមនុស្ស
- គ្រប់គ្រងការធ្វើសមាហរណកម្មតភ្ជាប់រវាងប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន របស់ក្រសួងមហាផ្ទៃ ជាមួយប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា

២

- គ្រប់គ្រងការធ្វើបច្ចុប្បន្នភាព វាយតម្លៃគុណភាពប្រព័ន្ធ និងសម្ភារៈបច្ចេកទេស បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឲ្យសមស្របតាមស្ថានភាពរីកចម្រើននៃបច្ចេកវិទ្យាពិភពលោក បម្រើដល់ការងារជំនាញ និងការងារផ្តល់សេវាសាធារណៈឲ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដើម្បីធានាដល់ការងារអនុវត្តប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ការងាររដ្ឋាភិបាលឌីជីថល ពលរដ្ឋឌីជីថល និងធុរកិច្ចឌីជីថល ក្របខ័ណ្ឌក្រសួងមហាផ្ទៃ
- រៀបចំរបាយការណ៍អំពីលទ្ធផលការងារតាមដំណាក់កាលនីមួយៗ ជូនរដ្ឋមន្ត្រីដើម្បីជូនជ្រាប ឬ/និងស្នើសុំមតិដឹកនាំតាមការចាំបាច់ ។

**ប្រការ៣ ._**

ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលដឹកនាំដោយ នាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ។

**ប្រការ៤ ._**

លេខាធិការដ្ឋាន នៃក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សិក្សា រៀបចំ តាមដាន ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងអាទិភាពបច្ចេកវិទ្យាឌីជីថលនានាតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ និងរាយការណ៍ជូនក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ ពិនិត្យ និងសម្រេច
- គ្រប់គ្រង តាមដាន ធ្វើបច្ចុប្បន្នភាពកិច្ចការងារពាក់ព័ន្ធនឹង រដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចឌីជីថល សង្គមឌីជីថល វិទ្យាសាស្ត្រ បច្ចេកវិទ្យា ឬនវានុវត្តន៍នានារបស់ក្រសួងមហាផ្ទៃ ជូនក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ
- គ្រប់គ្រង និងតាមដានការអនុវត្តផែនការសកម្មភាពគម្រោង កិច្ចសន្យាផ្គត់ផ្គង់គម្រោង ការធានាគុណភាពសុវត្ថិភាព និងគ្រប់គ្រងហានិភ័យពាក់ព័ន្ធការងារអនុវត្តតាមផែនការយុទ្ធសាស្ត្រ
- សហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារអនុវត្តគម្រោងតាមផែនការសកម្មភាព ដែលបានអនុម័តដោយក្រសួងមហាផ្ទៃ ដើម្បីធានាបានការអនុវត្តគម្រោងទទួលបានជោគជ័យ និងប្រសិទ្ធភាពខ្ពស់
- សម្របសម្រួលក្នុងការរៀបចំគោលនយោបាយបច្ចេកវិទ្យាឌីជីថល នីតិវិធីអនុវត្តការងារ និងការងារគ្រប់គ្រងការផ្លាស់ប្តូរ (Change Management) ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- រៀបចំផែនការបណ្តុះបណ្តាល និងកសាងសមត្ថភាពដើម្បីទ្រទ្រង់ដល់ដំណើរការអនុវត្តគម្រោង និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលប្រកបដោយប្រសិទ្ធភាព និងចីរភាព
- គ្រប់គ្រងការងារសមាហរណកម្មតភ្ជាប់ប្រព័ន្ធបណ្តាញហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធសន្តិសុខព័ត៌មាន
- តាមដានការអនុវត្តកម្មវិធីថែទាំឧបករណ៍សម្ភារៈបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន តាមប្រតិទិនកំណត់ និង/ឬតាមតម្រូវការបច្ចេកទេសរបស់អង្គភាពចំណុះក្រសួងមហាផ្ទៃ ដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ។

៣

**ប្រការ៥ ._**

– អនុប្រធាន និងសមាជិក នៃក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ ត្រូវចូលរួមកិច្ចប្រជុំ និងបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានក្រុមការងារ

– ក្រុមការងារអាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធផ្សេងទៀត ឱ្យចូលរួមប្រជុំក្នុងករណីចាំបាច់

– អនុប្រធាន និងសមាជិក នៃក្រុមការងារលេខាធិការដ្ឋាន ត្រូវចូលរួមកិច្ចប្រជុំ និងបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានលេខាធិការដ្ឋាន

– ប្រធានលេខាធិការដ្ឋានអាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធផ្សេងទៀត ឱ្យចូលរួមប្រជុំក្នុងករណីចាំបាច់

– ប្រធានលេខាធិការដ្ឋាន មានសិទ្ធិចេញសេចក្តីសម្រេចក្នុងការបង្កើតផ្នែកការងារតូចៗតាមការចាំបាច់ ដើម្បីជំរុញដល់ការអនុវត្តតាមគម្រោងឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ។

**ប្រការ៦ ._**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ប្រធាននាយកដ្ឋាន-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ០៦ កើត ខែប.សាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
(ដើម្បីជូនជ្រាប)
-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៧៖ សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារនៃលេខាធិការដ្ឋាន ចំណុះក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
**ក្រុមការងាររដ្ឋាភិបាលឌីជីថល**
**បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន**
លេខ: ០៣៩ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតក្រុមការងារនៃលេខាធិការដ្ឋាន ចំណុះក្រុមការងាររដ្ឋាភិបាលឌីជីថល**
**បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ**

**រដ្ឋលេខាធិការប្រចាំការ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល**
**ឌីជីថលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ១៦០ សសរ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុករៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល និងសេចក្តីព្រាងក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថលរបស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ០១០ បទ.សសរ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញសេចក្តីសម្រេចលេខ ១៦២៦ សសរ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ
- យោងតាមតម្រូវការការងារចាំបាច់

# **សម្រេច**

**ប្រការ១** ._

ត្រូវបានបង្កើតក្រុមការងារនៃលេខាធិការដ្ឋាន ចំណុះក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ ដែលមានសមាសភាពដូចខាងក្រោម ៖

១.ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហោ សំអាត** អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា ប្រធាន

២.លោកឧត្តមសេនីយ៍ទោ **អ៊ុម មករា** អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា អនុប្រធាន

៣.លោកឧត្តមសេនីយ៍ទោ **គីម សិរីវុឌ្ឍ** អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា អនុប្រធាន

៤.លោកឧត្តមសេនីយ៍ទោ **ម៉ៅ គន្ធា** អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា អនុប្រធាន

៥.លោកឧត្តមសេនីយ៍ទោ **អ៊ុច ចាន់សនា** អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា អនុប្រធាន

៦.លោកឧត្តមសេនីយ៍ទោ **ស្រ្តីយ៍ ដារ៉ាច់** អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា អនុប្រធាន

៧.លោកឧត្តមសេនីយ៍ទោ **សៀន សឿង** អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា អនុប្រធាន

៨.លោកឧត្តមសេនីយ៍ទោ **ឈាង តារិទ្ធ** អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធាន

៩.លោកឧត្តមសេនីយ៍ទោ **តាគ ឆារិទ្ធ** អនុប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធាន

១០.លោកឧត្តមសេនីយ៍ទោ **ឆាង សុឃាង** អនុប្រធាននាយកដ្ឋានជនបរទេសមិនមែនអន្តោប្រវេសន៍ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អនុប្រធាន

១១.លោកឧត្តមសេនីយ៍ទោ **ស៊ុំ ជាពេញចិត្ត** អនុប្រធាននាយកដ្ឋានជនបរទេសមិនមែនអន្តោប្រវេសន៍ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អនុប្រធាន

១២.លោក **ហៀម យូន** អនុប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានរដ្ឋបាល អនុប្រធាន

១៣.លោកវរសេនីយ៍ទោ **គង សុធីរៈ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អនុប្រធាន

១៤.លោកវរសេនីយ៍ឯក **ណុប ចាន់ធី** នាយការិយាល័យរដ្ឋបាលសរុប នៃនាយកដ្ឋានព័ត៌មានវិទ្យា អគ្គលេខាធិការដ្ឋាន សមាជិក

១៥.លោកវរសេនីយ៍ឯក **លី ធណ្ឌី** នាយការិយាល័យបណ្តុះបណ្តាល នៃនាយកដ្ឋានព័ត៌មានវិទ្យា អគ្គលេខាធិការដ្ឋាន សមាជិក

១៦.លោកវរសេនីយ៍ឯក **ជួន ណារិទ្ធ** នាយការិយាល័យសារព័ត៌មាន និងគ្រប់គ្រងព័ត៌មានវិទ្យា នៃនាយកដ្ឋានព័ត៌មានវិទ្យា អគ្គលេខាធិការដ្ឋាន សមាជិក

| | | | |
|---|---|---|---|
| ១៧.លោកវរសេនីយ៍ឯក | **ម៉ាញ សាយ័ន្តសុម៉ាលី** | នាយការិយាល័យអភិបាលកិច្ចព័ត៌មានវិទ្យា និងគមនាគមន៍ នៃនាយកដ្ឋានព័ត៌មានវិទ្យា អគ្គលេខាធិការដ្ឋាន | សមាជិក |
| ១៨.លោកវរសេនីយ៍ឯក | **អ៊ិត តុលា** | នាយការិយាល័យសហប្រតិបត្តិការទប់ស្កាត់បទល្មើសព័ត៌មានវិទ្យា នៃនាយកដ្ឋានព័ត៌មានវិទ្យា អគ្គលេខាធិការដ្ឋាន | សមាជិក |
| ១៩.លោកវរសេនីយ៍ឯក | **ទ៉ិត សុគន្ធារិទ្ធ** | នាយការិយាល័យគ្រប់គ្រងបណ្តាញគមនាគមន៍ព័ត៌មានវិទ្យា នៃនាយកដ្ឋានព័ត៌មានវិទ្យា អគ្គលេខាធិការដ្ឋាន | សមាជិក |
| ២០.លោកវរសេនីយ៍ឯក | **មុំ សុខបញ្ញា** | នាយការិយាល័យអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ស្តីទី នៃនាយកដ្ឋានព័ត៌មានវិទ្យា អគ្គលេខាធិការដ្ឋាន | សមាជិក |
| ២១.លោក | **ប៊ូន ចំរើន** | ប្រធានការិយាល័យកិច្ចការច្រកចេញចូលតែមួយ នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ២២.លោកវរសេនីយ៍ទោ | **អ៊ុំ ឆាយម៉េង** | នាយការិយាល័យបណ្តាញព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក។ |

**ប្រការ២ ._**

ក្រុមការងារនៃលេខាធិការដ្ឋាន ចំណុះក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ ត្រូវអនុវត្តតាមភារកិច្ចដូចមានចែងក្នុងប្រការ៤ នៃសេចក្តីសម្រេចលេខ ១៦២៦ សសរ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងមហាផ្ទៃ ។

**ប្រការ៣ ._**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានកសុ្តភានិងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គាធិការ នៃអគ្គាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ.......... ខែ.......... ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី.....០៤.....ខែ.....កុម្ភៈ.....ឆ្នាំ២០២២

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**និងជាប្រធានក្រុមការងាររដ្ឋាភិបាលឌីជីថល**

**បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងមហាផ្ទៃ**

**សក់ សេដ្ឋា**

កន្លែងទទួល ៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-ខុទ្ទកាល័យសម្តេចក្រឡាហោម

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (ដើម្បីជូនជ្រាប)

-ឯកសារ កាលប្បវត្តិ

# ពន្យល់ពាក្យគន្លឹះ

**ផែនការយុទ្ធសាស្ត្រ** ៖ សំដៅដល់គម្រោងកម្មវិធីការងារ ដែលមានលក្ខណៈជាផែនទីបង្ហាញផ្លូវរយៈពេលវែង ក្នុងនោះផ្តោតសំខាន់ទៅលើការកែទម្រង់ប្រព័ន្ធការងារឱ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់។

**អារម្ភកថា** ៖ ជាការសម្តែងអារម្មណ៍ផ្ទាល់របស់អ្នកនិពន្ធទៅកាន់អ្នកអាន ក្នុងនោះអាចជាការពន្យល់អំពីគោលបំណងនៃការសរសេរអត្ថបទ ឬវិធីសាស្ត្រក្នុងការអានអត្ថបទឱ្យងាយយល់។

**បច្ចេកវិទ្យាព័ត៌មាន** ៖ បច្ចេកទេសតាមបែបវិទ្យាសាស្ត្រ ដែលប្រើសម្រាប់បង្កើត ទទួល រក្សាទុក ប្រតិបត្តិ និងចែករំលែកព័ត៌មានតាមគ្រឿងអេឡិចត្រូនិកដោយរាប់បញ្ចូលទាំងកុំព្យូទ័រ ទូរស័ព្ទ វិទ្យុ និងទូរទស្សន៍ជាដើម។

**ឌីជីថល** ៖ ដែលទាក់ទងនឹងគ្រឿងដែលតំណាងឱ្យទិន្នន័យ។

**ចក្ខុវិស័យ** ៖ ការសន្និដ្ឋានទុក ឬការប្រមើលមើលទៅថ្ងៃមុខ ដោយផ្អែកលើមូលដ្ឋាននៃបទពិសោធន៍ដែលកើតមាននៅក្នុងអតីតកាល និងការវិវត្តន៍ក្នុងពេលបច្ចុប្បន្ន។ ចក្ខុវិស័យមានលក្ខណៈវិទ្យាសាស្ត្រ និងប្រាកដនិយម។

**គោលបំណង** ៖ អ្វីៗដែលប៉ង ឬសង្ឃឹមថានឹងធ្វើឱ្យសម្រេចក្នុងក្របខ័ណ្ឌចក្ខុវិស័យណាមួយ។ គោលបំណង មានលក្ខណៈអរូបី។

**គោលដៅ** ៖ ជាសមាសភាព ឬបែបផែននៃសកម្មភាពការងារដែលគាំទ្រឱ្យសម្រេចគោលបំណង។ គោលដៅមានលក្ខណៈវិទ្យាសាស្ត្រ និងប្រាកដនិយម។

**យុទ្ធសាស្ត្រ** ៖ ក្បួន ឬសិល្បៈក្នុងការអនុវត្តឱ្យសម្រេចគោលដៅដែលបានកំណត់។ បង្កើតយុទ្ធសាស្ត្រត្រូវតែមានភ្ជាប់ផែនការសកម្មភាព ទើបមានលទ្ធផល។

**បរិយាបន្ន** ៖ ការរួមបញ្ចូលគ្នានៃការផ្តល់សេវា ការប្រើសេវានានា នៅតាមគ្រឹះស្ថានសិក្សាសម្រាប់មនុស្សគ្រប់រូបដោយមិនគិតពីពិការភាព ឋានៈ យេនឌ័រ ពណ៌សម្បុរ សាសនា ជាតិសាសន៍ ស្ថានភាព និងជីវភាពគ្រួសារ។

**បរិការណ៍** ៖ ការណ៍ទាំងឡាយដែលកើតមុន និងក្រោយព្រឹត្តិការណ៍មួយ។ ពាក្យនេះប្រើខុសពីបរិបទដែលសំដៅដល់ខ្លឹមសារណាមួយដែលត្រូវលើកឡើងនៅពីមុខ ឬពីក្រោយសេចក្តីមួយ។ ក្នុងន័យសេដ្ឋកិច្ច «បរិការណ៍» ប្រើសំដៅបង្ហាញការណ៍ណាមួយដែលកើតឡើងនៅជុំវិញព្រឹត្តិការណ៍មួយ។

**ទស្សនាទាន** ៖ មូលដ្ឋានគំនិតយល់ដឹងអំពីអ្វីមួយឬគោលការណ៍ណាមួយដូចជា ប្រជាជនដែលមានវប្បធម៌ប្លែកៗគ្នា មានទស្សនាទានខុសៗគ្នា។

**បដិវត្តន៍** ៖ ការវិលត្រឡប់ ការប្រែប្រួល ការកែប្រែ ឬផ្លាស់ប្តូរ។

**បរិវត្តន៍** ៖ ដំណើរការផ្លាស់ប្តូរ ឬបំប្លែងអ្វីមួយទៅជាអ្វីមួយផ្សេងទៀត។

| | | |
|---|---|---|
| **ផែនការសកម្មភាព** | ៖ | គម្រោងកិច្ចការដែលត្រូវអនុវត្តជាដំណាក់កាលៗ ក្នុងនោះអាចទាក់ទងនឹងការបង្កើតយន្តការ ការបង្កើតក្របខណ្ឌគតិយុត្ត ការអនុវត្តគម្រោងសាកល្បង។ |
| **អភិវឌ្ឍ** | ៖ | ចម្រើនក្រៃលែង លូតលាស់រីកចម្រើន។ |
| **វិវត្តន៍** | ៖ | ការផ្លាស់ប្តូរ ការប្រែប្រួល។ |
| **កាលានុវត្តភាព** | ៖ | ភាពសមស្រប ភាពត្រូវតាមកាលៈទេសៈ។ |
| **និម្មាបនកម្ម** | ៖ | អំពើ ឬការបង្កើតអ្វីមួយដោយឫទ្ធិ ការបង្កើត ឬតាក់តែងនូវវត្ថុផ្សេងៗឱ្យល្អចើតឆាយដូចជានិម្មិត។ |
| **ការ្យ** | ៖ | ផលដែលកើតមកពីស្នាដៃជាង ឬស្នាដៃសិល្បករ។ |
| **តម្លាភាព** | ៖ | បរិយាកាសនៃការបើកទូលាយដល់ការចូលរួម ការតាមដាន ការពិនិត្យ និងការផ្តល់យោបល់គ្រប់ជ្រុងជ្រោយ ក៏ដូចជាការប្រកួតប្រជែងដោយសមធម៌។ |
| **សនិទានភាព** | ៖ | សេចក្តីពន្យល់អំពីមូលហេតុ ឬហេតុផលចម្បងៗដែលនាំឱ្យមានការរៀបចំ និងអនុវត្តកម្មវិធី គម្រោង សកម្មភាព ឬវិធានណាមួយ។ |
| **លទ្ធផលរំពឹងទុក** | ៖ | សំដៅដល់សកម្មភាពអាទិភាពសំខាន់ៗដែលត្រូវសម្រេចឲ្យបាន។ |
| **នវានុវត្ត** | ៖ | សំដៅដល់គំនិតច្នៃប្រឌិតបង្កើតនូវវិធីសាស្ត្រ ឬនីតិវិធីថ្មីៗ ដែលមានប្រយោជន៍។ |
| **លទ្ធកម្ម** | ៖ | ការទិញ ឬការរកបាននូវទំនិញ សំណង់ សេវាកម្មសាធារណៈ ទីប្រឹក្សាតាមរយៈវិធីសាស្ត្រដែលមានចែងច្បាប់។ |
| **គុណផល** | ៖ | សំដៅដល់ការសម្រេចលទ្ធផលការងាររបស់មន្ត្រីស្របតាមផែនការ ឬលទ្ធផលរំពឹងទុកដែលបានកំណត់ ដោយប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពខ្ពស់។ |
| **ប្រសិទ្ធផល** | ៖ | សំដៅដល់លទ្ធផលចុងក្រោយ ឬជាគុណភាពនៃលទ្ធផលដែលមានឥទ្ធិពល និង/ឬផ្តល់ផលប៉ះពាល់រយៈពេលវែង។ |
| **ផលិតផល** | ៖ | សំដៅដល់ការចាត់ចែង និងប្រើប្រាស់ទាំងធនធានមនុស្ស ហិរញ្ញវត្ថុ និងធនធានសម្ភារៈឱ្យត្រូវតាមជំនាញ មុខតំណែង គុណវុឌ្ឍិ ពេលវេលា ទីកន្លែង និងប្រកបដោយភាពសន្សំសំចៃ ឬប្រសិទ្ធភាពចំណាយដែលនាំឱ្យផលិតបានលទ្ធផលខ្ពស់ ឬច្រើនជាងមុន។ |
| **សមធម៌** | ៖ | សំដៅដល់ការអនុវត្តដោយស្មើភាព ផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ មិនរើសអើង មិនប្រកាន់បក្ខពួក និងគោរពតាមគោលការណ៍ច្បាប់។ |
| **គុណវុឌ្ឍិ** | ៖ | ជាបណ្តុំសមត្ថភាព ដែលឆ្លើយតបទៅនឹងតួនាទី និងផ្នែកសំខាន់ៗនៅកន្លែងធ្វើការ។ |
| **គុណាធិប្បតេយ្យ** | ៖ | សំដៅដល់ការតែងតាំង ឬ/និង ផ្តល់នូវតួនាទី ភារកិច្ច ឬការផ្តល់នូវលាភការ្យផ្សេងៗដល់មន្ត្រីរាជការដែលបានសាងគុណសម្បត្តិជូនអង្គភាព ឬស្ថាប័នណាមួយដោយពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន។ |

**សក្ដានុពល** ៖ សមត្ថភាពសម្រេចអ្វីមួយដោយធនធានទាំងនៅក្នុង និងក្រៅខ្លួន លើសពីអ្នកដទៃ។

**បុរេសកម្ម** ៖ សំដៅដល់ការរៀបចំ ចាត់ចែង គ្រប់គ្រងបាននូវស្ថានការណ៍ដែលអាចនឹងកើតឡើង។

**យន្តការ** ៖ សំដៅដល់ប្រព័ន្ធ ឬចង្វាក់ការងារដែលមានទម្រង់បែបបទច្បាស់លាស់។

**នីតិសម្បទា** ៖ សំដៅដល់ការបរិបូរណ៍ដោយច្បាប់ ការមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់។

**តួនាទី** ៖ ជានីតិសម្បទាអចិន្ត្រៃយ៍របស់បុគ្គល ឬអង្គភាព ដែលប្រធានស្ថាប័នប្រគល់ឱ្យ។

**បេសកកម្ម** ៖ ជាភារកិច្ច ឬជាបន្ទុកដែលអង្គភាព ឬបុគ្គលត្រូវបំពេញក្រោមវង្វង់អំណាចដែលច្បាប់ ឬថ្នាក់លើប្រគល់ឱ្យ ដោយមានកំណត់នូវពេលវេលា និងទីកន្លែងច្បាស់លាស់។

**គោលនយោបាយ** ៖ ដំណើរ ឬគោលការណ៍នៃសកម្មភាពដែលបានអនុម័ត ឬស្នើឡើងដោយក្រសួង ស្ថាប័ន គណបក្ស ក្រុមហ៊ុន ឬបុគ្គលណាមួយ។

**លទ្ធផលរំពឹងទុក** ៖ សំដៅដល់លទ្ធផលសំខាន់ៗដែលកើតចេញពីការអនុវត្តសកម្មភាពមួយ ឬច្រើន ៕

